ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងអប់រំ យុវជន និងកីឡា

# របាយការណ៍សង្ខេប

# កម្មវិធីអន្តរជាតិស្តីពីរទ្វាយតម្លៃលទ្ធផលសិក្សារបស់សិស្ស ឆ្នាំ២០២៥ របស់ប្រទេសកម្ពុជា

## (PISA 2025 FOR CAMBODIA)

អំណាន

គណិតវិទ្យា

វិទ្យាសាស្ត្រ

ខែកញ្ញា ឆ្នាំ២០២៦

របាយការណ៍សង្ខេបនេះ ត្រូវបានរៀបចំឡើងដោយក្រុមការងារបច្ចេកទេសរបស់ក្រសួងអប់រំ យុវជន និងកីឡានៃព្រះរាជាណាចក្រកម្ពុជា។ របាយការណ៍នេះត្រូវបានបោះពុម្ពផ្សាយដោយក្រសួងអប់រំ យុវជន និងកីឡា។

**ក្រុមដឹកនាំ៖** ឯកឧត្តម អ៊ុង ជិនណា និងលោកសាស្ត្រាចារ្យ ហេង គ្រេង

**ក្រុមអ្នកនិពន្ធ៖** លោកសាស្ត្រាចារ្យ ហេង គ្រេង, លោកបណ្ឌិត តុល បញ្ញា, លោក សរ សារិន និងលោក ជួង ចន្ថា

**ក្រុមសម្របសម្រួល និងពិនិត្យកែសម្រួល៖** ឯកឧត្តម អ៊ុង ជិនណា និងលោកសាស្ត្រាចារ្យ ហេង គ្រេង

**ក្រុមរចនា៖** លោកសាស្ត្រាចារ្យ ហេង គ្រេង, លោក សរ សារិន និងលោកបណ្ឌិត តុល បញ្ញា

**សូមយោងឯកសារនេះដោយសរសេរថា៖**
អ.យ.ក (២០២៦). *របាយការណ៍សង្ខេប* ៖ កម្មវិធីអន្តរជាតិស្តីពីការវាយតម្លៃលទ្ធផលសិក្សារបស់សិស្សឆ្នាំ ២០២៥ របស់ប្រទេសកម្ពុជា (PISA 2025 for Cambodia). ភ្នំពេញ: អយក.

© អ.យ.ក. ២០២៦

លោកអ្នកអាចថតចម្លង ឬបោះពុម្ពឯកសារនេះសម្រាប់ការប្រើប្រាស់ផ្ទាល់ខ្លួនផ្សេងៗដូចជាឯកសារតម្កល់ បទបង្ហាញ ប្លុក គេហទំព័រ និងឯកសារបង្រៀន ប៉ុន្តែត្រូវបញ្ជាក់ថា ក្រសួងអប់រំ យុវជន និងកីឡា ជាអ្នកកសាងឯកសារ និងរក្សាសិទ្ធិគ្រប់យ៉ាង។

# បុព្វកថា

ប្រទេសកម្ពុជាបានអនុវត្តកំណែទម្រង់វិស័យអប់រំស៊ីជម្រៅ ក្នុងរយៈពេលមួយទសវត្សចុងក្រោយនេះ ដោយចាប់ផ្តើមពីការអភិវឌ្ឍសមត្ថភាពគ្រូបង្រៀន កម្មវិធីសិក្សា និងសម្ភារសិក្សា រហូតឈានដល់ការកែលម្អអភិបាលកិច្ចសាលារៀន វង្វាយតម្លៃការសិក្សា និងគណនេយ្យភាព ដែលកំណែទម្រង់ទាំងនេះបានផ្តោតលើលទ្ធផលសិក្សារបស់សិស្សជាចំណុចអាទិភាព។

ជាមួយគ្នានេះ ព្រះរាជាណាចក្រកម្ពុជាបានចូលរួមអនុវត្តកម្មវិធីអន្តរជាតិស្តីពីវង្វាយតម្លៃលទ្ធផលសិក្សារបស់សិស្ស (PISA) ជាផ្លូវការវគ្គទី១ នៅឆ្នាំ២០២២ ជាមួយបណ្តា ៨១ ប្រទេស និងវគ្គទី២ នៅឆ្នាំ២០២៥ ជាមួយបណ្តា ៩១ ប្រទេស។ កម្មវិធី PISA វាយតម្លៃលើសមត្ថភាពរបស់សិស្សអាយុ១៥ឆ្នាំ ផ្នែកអំណាន គណិតវិទ្យា និងវិទ្យាសាស្ត្រ ធៀបនឹងស្តង់ដាអប់រំកម្រិតអន្តរជាតិ ព្រមទាំងអាចឆ្លើយតបនឹងសមត្ថភាពមូលដ្ឋានរបស់សិស្សកម្រិតមធ្យមសិក្សានៃគោលដៅអប់រំសកល (**SDG4.1.1c**) ផងដែរ។ គោលបំណងនៃការចូលរួមក្នុងកម្មវិធីនេះ គឺដើម្បីឆ្លុះបញ្ចាំងពីការត្រៀមខ្លួនរួចជាស្រេចរបស់សិស្សអាយុ១៥ឆ្នាំ ក្នុងការយកចំណេះដឹង និងជំនាញ ទៅបន្តការសិក្សានៅកម្រិតថ្នាក់បន្ទាប់ ព្រមទាំងដោះស្រាយបញ្ហាប្រឈមនានាក្នុងជីវិតប្រចាំថ្ងៃ។

លទ្ធផល **PISA-2025** បង្ហាញថា សមត្ថភាពរបស់សិស្សកម្ពុជាអាយុ១៥ឆ្នាំ មានការរីកចម្រើនគួរឱ្យស្ញប់ស្ញែងដែលត្រូវបានកត់សម្គាល់ក្នុងកម្រិតអន្តរជាតិ។ សមិទ្ធផលនេះ គឺជាជោគជ័យជាប្រវត្តិសាស្ត្រមួយដែលស័ក្តិសមនឹងទទួលបានការយកចិត្តទុកដាក់ក្នុងកម្រិតអន្តរជាតិ ដោយសារសមិទ្ធផលនេះបានបង្ហាញពីផលសម្រេច ដែលកើតចេញពីការប្តេជ្ញាចិត្តយ៉ាងមុតមាំរបស់គ្រប់ភាគីពាក់ព័ន្ធ និងការបន្តដំណើរលើផ្លូវយ៉ាងត្រឹមត្រូវបំផុតនៃការអនុវត្តកំណែទម្រង់វិស័យអប់រំ។

ក្រសួងអប់រំ យុវជន និងកីឡា សូមថ្លែងអំណរគុណដល់ថ្នាក់ដឹកនាំ និងមន្ត្រីអប់រំគ្រប់លំដាប់ថ្នាក់ ព្រមទាំងគ្រប់ភាគីពាក់ព័ន្ធ និងប្តេជ្ញាប្រើប្រាស់លទ្ធផលដែលទទួលបានពីកម្មវិធី **PISA-2025** ជាមូលដ្ឋាន ដើម្បីបន្តកែលម្អគោលនយោបាយអប់រំ យុទ្ធសាស្ត្រអប់រំ កម្មវិធីសិក្សា ការអភិវឌ្ឍគ្រូបង្រៀន ការបង្រៀននិងរៀន និងអភិបាលកិច្ចសាលារៀន ជាពិសេសធានាឱ្យបាននូវការត្រៀមខ្លួនរួចជាស្រេចរបស់ប្រព័ន្ធអប់រំកម្ពុជាសម្រាប់កម្មវិធី **PISA-2029**។

ថ្ងៃអង្គារ ១១រោច ខែភទ្របទ ឆ្នាំមមី អដ្ឋស័ក ពុទ្ធសករាជ ២៥៧០

រាជធានីភ្នំពេញ ថ្ងៃទី ៨ ខែកញ្ញា ឆ្នាំ២០២៦

**ឧបនាយករដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា**

**បណ្ឌិតសភាចារ្យ ហង់ជួន ណារ៉ុន**

# ១. សេចក្ដីផ្ដើម

## ១.១. ទិដ្ឋភាពទូទៅនៃកម្មវិធី PISA

កម្មវិធីអន្តរជាតិស្ដីពីវង្វាយតម្លៃលទ្ធផលសិក្សារបស់សិស្ស (Programme for International Student Assessment – PISA) ជាកម្មវិធីវង្វាយតម្លៃអន្តរជាតិមួយ ដែលរៀបចំឡើងដោយអង្គការសម្រាប់កិច្ចសហប្រតិបត្តិការ និងអភិវឌ្ឍន៍សេដ្ឋកិច្ច (Organization for Economic Co-operation and Development – OECD) រៀងរាល់បីឆ្នាំម្ដង ដើម្បីវាយតម្លៃចំណេះដឹង និងបំណិនរបស់សិស្សអាយុ ១៥ឆ្នាំ កម្រិតពិភពលោក។ ជំនួសឱ្យការផ្ដោតជាចម្បងលើសមត្ថភាពរបស់សិស្សក្នុងការចងចាំខ្លឹមសារមេរៀន កម្មវិធី PISA វាយតម្លៃថាតើសិស្សអាចអនុវត្តចំណេះដឹង និងបំណិនរបស់ខ្លួនទៅក្នុងស្ថានភាពជាក់ស្ដែងក្នុងជីវិតប្រចាំថ្ងៃបានយ៉ាងមានប្រសិទ្ធភាពកម្រិតណា អាចដោះស្រាយបញ្ហា គិតស៊ីជម្រៅ និងប្រើប្រាស់អ្វីដែលបានរៀនក្នុងបរិបទ ឬស្ថានភាពដែលមិនធ្លាប់ជួបប្រទះពីមុនបានកម្រិតណា។

កម្មវិធី PISA ត្រូវបានបង្កើតឡើងក្នុងឆ្នាំ ១៩៩៧ ហើយការវាយតម្លៃលើកដំបូងត្រូវបានអនុវត្តនៅឆ្នាំ ២០០០ ដោយមានប្រទេស និងតំបន់សេដ្ឋកិច្ចចំនួន ៣២ ចូលរួម។ កម្មវិធី PISA វាយតម្លៃលើសមត្ថភាពបីសំខាន់ៗ រួមមានអំណាន គណិតវិទ្យា និងវិទ្យាសាស្ត្រ។ បន្ថែមពីលើការវាស់វែងលទ្ធផលសិក្សារបស់សិស្ស កម្មវិធី PISA ក៏ប្រមូលព័ត៌មានអំពីសាវតារបស់សិស្ស បទពិសោធន៍រៀនសូត្រ ឥរិយាបថ និងទស្សនៈរបស់សិស្ស ព្រមទាំងបរិយាកាសសាលារៀនផងដែរ។ ព័ត៌មានទាំងនេះអនុញ្ញាតឱ្យប្រទេស និងតំបន់សេដ្ឋកិច្ចដែលចូលរួម អាចពិនិត្យមើលមិនត្រឹមតែចំណេះដឹងរបស់សិស្សប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងអាចសិក្សាអំពីកត្តាដែលពាក់ព័ន្ធនឹងលទ្ធផលសិក្សារបស់សិស្សផងដែរ។

កម្មវិធី PISA ឆ្នាំ២០២៥ ជាវដ្តទី៩ នៃកម្មវិធី PISA ដែលមានប្រទេស និងតំបន់សេដ្ឋកិច្ចចំនួន ៩១ ចូលរួម។ ការវាយតម្លៃនេះនៅតែបន្តផ្ដោតលើអំណាន គណិតវិទ្យា និងវិទ្យាសាស្ត្រ ព្រមទាំងពិនិត្យលើសមត្ថភាពចងចាំ និងអនុវត្តចំណេះដឹង ព្រមទាំងអាចពង្រីក ឬទាញសេចក្ដីសន្និដ្ឋានពីអ្វីដែលខ្លួនបានរៀន នៅពេលប្រឈមនឹងបញ្ហា និងស្ថានភាពដែលមិនធ្លាប់ជួបប្រទះពីមុន ទាំងនៅក្នុង និងក្រៅបរិយាកាសសាលារៀន។ ប្រទេស និងតំបន់សេដ្ឋកិច្ចដែលចូលរួមក្នុងកម្មវិធី PISA ឆ្នាំ២០២៥ ជាលើកដំបូង រួមមាន អាមេនី, អេក្វាទ័រ, អេហ្ស៊ីប, កេនយ៉ា, តំបន់ឃឺឌីស្ថាននៃប្រទេសអ៊ីរ៉ាក់, កៀហ្ស៊ីស៊ីស្ថាន, ម៉ូរីស, រវ៉ាន់ដា, តាហ្ស៊ីគីស្ថាន, និងសំប៊ី។

កម្ពុជាបានចូលរួមក្នុងកម្មវិធី PISA ពេញលេញជាលើកទីពីរ បន្ទាប់ពីបានចូលរួមក្នុងកម្មវិធី PISA សម្រាប់ប្រទេសកំពុងអភិវឌ្ឍន៍ (PISA for Development – PISA-D) នៅឆ្នាំ២០១៧[1] និងកម្មវិធី PISA ពេញលេញ ឆ្នាំ២០២២។ ការវាយតម្លៃដែលបានអនុវត្តកន្លងមកនេះ បានផ្តល់បទពិសោធន៍សំខាន់ៗដល់កម្ពុជា និងបានរួមចំណែកពង្រឹងសមត្ថភាពរបស់ប្រទេសក្នុងការចូលរួមក្នុងការវាយតម្លៃទ្រង់ទ្រាយធំកម្រិតអន្តរជាតិ។

## *ខ្លឹមសារ*

កម្មវិធី PISA ឆ្នាំ២០២៥ ផ្តោតលើមុខវិជ្ជាវិទ្យាសាស្ត្រ អំណាន គណិតវិទ្យា និងការដោះស្រាយបញ្ហាដោយប្រើកុំព្យូទ័រ។ ក្នុងវដ្តនីមួយៗនៃកម្មវិធី PISA មុខវិជ្ជាមួយក្នុងចំណោមមុខវិជ្ជាស្នូលទាំងបីគឺ វិទ្យាសាស្ត្រ អំណាន និងគណិតវិទ្យា ត្រូវបានវាយតម្លៃយ៉ាងលម្អិត។ ក្នុងឆ្នាំ២០២៥ វិទ្យាសាស្ត្រជាមុខវិជ្ជាត្រូវបានផ្តោតជាចម្បង ដូចគ្នានឹងឆ្នាំ២០០៦ និង២០១៥។ អំណានត្រូវបានផ្តោតជាចម្បងនៅឆ្នាំ២០០០, ២០០៩ និង ២០១៨ ចំណែកគណិតវិទ្យាគឺនៅឆ្នាំ២០០៣, ២០១២ និង២០២២។

## *វង្វាយតម្លៃ*

កម្មវិធី PISA ឆ្នាំ២០២៥ នៅតែរក្សាទម្រង់វង្វាយតម្លៃដោយប្រើប្រាស់សៀវភៅតេស្ត ដែលរួមបញ្ចូលតែសំណួរតេស្តសម្រាប់តាមដាននិន្នាការ (trend items) ក្នុងមុខវិជ្ជាវិទ្យាសាស្ត្រ អំណាន និងគណិតវិទ្យា។ វង្វាយតម្លៃដោយប្រើប្រាស់សៀវភៅតេស្តនេះត្រូវបានអនុវត្តនៅក្នុងប្រទេស និងតំបន់សេដ្ឋកិច្ចចំនួន ៦ រួមមាន កម្ពុជា, តំបន់ឌូសានបេ (តាហ្ស៊ីគីស្ថាន), តំបន់ឃឺឌីស្ថាន (អ៊ីរ៉ាក់), ម៉ូរ៉ូស, វៀតណាម, និងសំប៊ី។

សំណួរតេស្តមានទម្រង់ជាសំណួរពហុជ្រើសរើស និងសរសេរចម្លើយដែលតម្រូវឱ្យសិស្សបង្កើតចម្លើយដោយខ្លួនឯង។ សំណួរទាំងនេះត្រូវបានរៀបចំជាក្រុម ដោយផ្អែកលើអត្ថបទ ឬសេចក្តីពិពណ៌នាដែលបង្ហាញអំពីស្ថានភាពជាក់ស្តែងក្នុងជីវិតប្រចាំថ្ងៃ។

## *កម្រងសំណួរ*

សិស្សត្រូវបំពេញកម្រងសំណួរអំពីសាវតារបស់ខ្លួន ដែលចំណាយពេលប្រមាណ ៣៥ នាទី។ កម្រងសំណួរនេះមានគោលបំណងប្រមូលព័ត៌មានអំពីឥរិយាបថ ទំនោរ និងជំនឿរបស់សិស្ស អំពីគ្រួសារ និងផ្ទះសម្បែងរបស់ពួកគេ ព្រមទាំងបទពិសោធន៍នៅសាលារៀន និងបទពិសោធន៍រៀនសូត្រ។ នាយកសាលារៀនបំពេញកម្រងសំណួរសាលារៀនដែលផ្តោតលើការងារគ្រប់គ្រង និងការរៀបចំសាលារៀន ព្រមទាំងបរិយាកាសរៀនសូត្រ។ ប្រទេស និង

[1] នៅក្នុងការពិពណ៌នាខាងក្រោម ព័ត៌មាននៃការវាយតម្លៃ PISA-D ឆ្នាំ២០១៧ ត្រូវបានជំនួសដោយ PISA ឆ្នាំ២០១៨ ដោយសារតែទិន្នន័យ PISA-D ឆ្នាំ២០១៧ របស់ប្រទេសកម្ពុជា ត្រូវបានបញ្ចូលទៅក្នុងទិន្នន័យអន្តរជាតិនៃ PISA ឆ្នាំ២០១៨ រួចរាល់ហើយ។

តំបន់សេដ្ឋកិច្ចដែលចូលរួម ក៏អាចជ្រើសរើសបន្ថែមកម្រងសំណួរជាជម្រើសបន្ថែមសម្រាប់សិស្សផងដែរ ដែលរួមមានកម្រងសំណួរស្ដីពីភាពស្ទាត់ជំនាញ និងភាពស៊ាំរបស់សិស្សក្នុងការប្រើប្រាស់កុំព្យូទ័រ។

ប្រទេស និងតំបន់សេដ្ឋកិច្ចមួយចំនួន ក៏ប្រើប្រាស់កម្រងសំណួរបន្ថែម ដើម្បីប្រមូលព័ត៌មានឱ្យបានកាន់តែទូលំទូលាយ។ កម្រងសំណួរទាំងនេះរួមមាន៖ កម្រងសំណួរគ្រូបង្រៀន ដែលសួរអំពីសាវតារបស់គ្រូបង្រៀន និងការអនុវត្តការបង្រៀនរបស់ពួកគាត់ និងកម្រងសំណួរមាតាបិតា ដែលសួរព័ត៌មានអំពីទស្សនៈរបស់ពួកគាត់ចំពោះសាលារៀន និងការសិក្សារបស់កូនៗ ព្រមទាំងការចូលរួមរបស់ពួកគាត់នៅក្នុងការអប់រំ និងការសិក្សារបស់កូន។

## ១.២. វិធីសាស្រ្តវាយតម្លៃ

### ១.២.១. វិធីសាស្រ្តជ្រើសរើសសំណាក

ការជ្រើសរើសសំណាកអនុវត្តតាមវិធីសាស្រ្ត "ការជ្រើសរើសសំណាកដោយចៃដន្យពីរដំណាក់កាល (Two-stage random sampling)"។ ដំណាក់កាលទី១ ជាដំណាក់កាលជ្រើសរើសសំណាកសាលារៀនពីសាលារៀនប្រជាករទូទាំងប្រទេស និងដំណាក់កាលទី២ ជាដំណាក់កាលជ្រើសរើសសិស្សចេញពីសិស្សដែលមានអាយុ ១៥ឆ្នាំទាំងអស់ នៅក្នុងសាលារៀនសំណាកនីមួយៗ។ វិធីសាស្រ្តនេះធានាថា សំណាកដែលបានជ្រើសរើសមានភាពតំណាងឱ្យសិស្សអាយុ ១៥ឆ្នាំទាំងអស់នៅទូទាំងប្រទេស។

### ការជ្រើសរើសសាលារៀន

ចំពោះដំណាក់កាលទី១ កម្ពុជាប្រើប្រាស់សំណុំអថេរ Implicit ចំនួនពីរ រួមមាន ទីតាំងសាលារៀន (ប្រជុំជន និង ជនបទ) និងតំបន់ភូមិសាស្រ្ត (ភ្នំពេញ, ទំនាប, បឹងទន្លេសាប, ខ្ពង់រាប, និងឆ្នេរសមុទ្រ)។ អថេរទាំងពីរនេះបង្កើតបានគុណលក្ខណៈសាលារៀន (Stratum) ចំនួន ៩ រួមមាន ប្រជុំជន-ភ្នំពេញ, ប្រជុំជន-ទំនាប, ប្រជុំជន-បឹងទន្លេសាប, ប្រជុំជន-ខ្ពង់រាប, ប្រជុំជន-ឆ្នេរសមុទ្រ, ជនបទ-ទំនាប, ជនបទ-បឹងទន្លេសាប, ជនបទ-ខ្ពង់រាបនិងជនបទ-ឆ្នេរសមុទ្រ (ពុំមានសាលារៀនស្ថិតនៅជនបទ-ភ្នំពេញ)។

កម្ពុជាមានសាលារៀនប្រជាករសរុបចំនួន ២ ១៨៦ ដែលមានសិស្សអាយុ ១៥ ឆ្នាំ មានលក្ខណៈសម្បត្តិគ្រប់គ្រាន់សម្រាប់ចូលរួមក្នុងកម្មវិធី PISA ឆ្នាំ២០២៥។ ក្នុងចំណោមសាលារៀនទាំងនេះ សាលារៀនចំនួន ១៨៦ ត្រូវបានជ្រើសរើសដោយចៃដន្យសម្រាប់ការធ្វើតេស្ត។ ភាគរយសាលារៀនសំណាកតាមគុណលក្ខណៈទាំង៩ ត្រូវស្មើឬប្រហាក់ប្រហែលភាគរយសាលារៀនប្រជាករ។ សាលារៀនត្រូវបានជ្រើសរើសដោយប្រើវិធីសាស្រ្តប្រូបាប៊ីលីតេសមាមាត្រទៅនឹងទំហំ (Probability Proportional to Size – PPS) ស្របតាមស្តង់ដាបច្ចេកទេសស្តីពីការជ្រើសរើសសំណាករបស់អង្គការ OECD។ វិធីសាស្រ្តនេះជួយធានាថា សាលារៀនដែលមានចំនួនសិស្សអាយុ ១៥ឆ្នាំច្រើន មានឱកាសជ្រើសរើសជាសាលារៀនសំណាកខ្ពស់ជាង តែធានាបាននូវភាពតំណាងសមស្របតាម

តំបន់ភូមិសាស្ត្រ និងទីតាំងប្រជុំជន-ជនបទ។ ជាបន្ថែម វិធីសាស្ត្រនេះបានជួយធានាឱ្យការប៉ាន់ប្រមាណលទ្ធផលសិក្សារបស់សិស្សមាន ភាពជឿជាក់ និងអាចប្រៀបធៀបបានជាអន្តរជាតិ។

*តារាងទី1: ចំនួនសាលារៀនសំណាកទៅតាមតំបន់ ភូមិសាស្ត្រ ប្រភេទសាលារៀន និងការគ្រប់គ្រងសាលារៀន*

| លក្ខណៈសាលារៀន | PISA 2022 | | PISA 2025 | |
|---|---|---|---|---|
| | ចំនួន | ភាគរយ(%) | ចំនួន | ភាគរយ (%) |
| តំបន់ | | | | |
| ប្រជុំជន | 47 | 25.7 | 49 | 26.3 |
| ជនបទ | 136 | 74.3 | 137 | 73.7 |
| ភូមិសាស្ត្រ | | | | |
| ភ្នំពេញ * | | | 23 | 12.4 |
| ទំនាប | 86 | 47.0 | 67 | 36.0 |
| បឹងទន្លេសាប | 56 | 30.6 | 56 | 30.1 |
| ខ្ពង់រាប | 26 | 14.2 | 27 | 14.5 |
| មាត់សមុទ្រ | 15 | 8.2 | 13 | 7.0 |
| ប្រភេទសាលារៀន | | | | |
| អនុវិទ្យាល័យ ៧ ដល់ ៩ | 90 | 49.2 | 88 | 47.3 |
| វិទ្យាល័យ ៧ ដល់ ១២ | 89 | 48.6 | 94 | 50.5 |
| វិទ្យាល័យ ១០ ដល់ ១២ | 4 | 2.2 | 4 | 2.2 |
| ការគ្រប់គ្រងសាលារៀន | | | | |
| សាធារណៈ | 172 | 93.9 | 172 | 92.5 |
| ឯកជន | 11 | 6.1 | 14 | 7.5 |
| ចំនួនសរុប | 183 | | 186 | |

** រាជធានីភ្នំពេញ ត្រូវបានបំបែកចេញពីតំបន់ភូមិសាស្ត្រទំនាប នៅក្នុងកម្មវិធី PISA ឆ្នាំ២០២៥*

## *ការជ្រើសរើសសិស្ស*

ដំណាក់កាលទី២ ជាការជ្រើសរើសសិស្សសំណាក។ បន្ទាប់ពីជ្រើសរើសសាលារៀនសំណាកចំនួន ១៨៦ រួចរាល់ សាលារៀនសំណាកត្រូវរៀបចំបញ្ជីឈ្មោះសិស្ស (Student list) ដោយរាយឈ្មោះសិស្សទាំងអស់ដែលមានថ្ងៃខែឆ្នាំកំណើត ចន្លោះពីថ្ងៃទី០១ ខែមីនា ឆ្នាំ២០០៩ ដល់ ថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០១០។ ដោយផ្អែកលើបញ្ជីឈ្មោះសិស្សទាំងនេះ ក្រុមការងារបច្ចេកទេសបានជ្រើសរើសសិស្សសំណាក និងបង្កើតបញ្ជីតាមដានសិស្ស (Student Tracking Form) សម្រាប់សាលារៀនសំណាកទាំងអស់។

ការជ្រើសរើសសិស្សសំណាកត្រូវបានអនុវត្តតាមនីតិវិធីស្តង់ដាដូចខាងក្រោម៖

- ប្រសិនបើសាលារៀនសំណាកមានសិស្សអាយុ ១៥ឆ្នាំ តិចជាង ៣៥នាក់ នោះសិស្សទាំងអស់ត្រូវបានជ្រើសរើស។
- ប្រសិនបើសាលារៀនសំណាកមានសិស្សអាយុ ១៥ឆ្នាំ ច្រើនជាង ៣៥នាក់ នោះកម្មវិធីជ្រើសរើសយកតែ ៣៥ នាក់ដោយចៃដន្យ។

វិធីសាស្ត្រជ្រើសរើសសំណាកពីរដំណាក់កាលនេះ ធានាថាសំណាករបស់កម្មវិធី PISA មានភាពតំណាងឱ្យប្រជាករនៃសិស្សអាយុ ១៥ឆ្នាំ តែរក្សាទំហំការវាយតម្លៃនៅក្នុងសាលារៀននីមួយៗឱ្យសមស្រប និងអាចគ្រប់គ្រងបាន។

ចំពោះកម្មវិធី PISA ឆ្នាំ២០២៥ កម្ពុជាបានជ្រើសរើសសិស្សចំនួន ៥ ៥៧២ នាក់ ពីសាលារៀនសំណាកចំនួន ១៨៦ សាលា។ ក្នុងចំណោមសិស្សទាំងនេះ មានសិស្សចំនួន ៥ ៤៦៤ នាក់ បានចូលរួមធ្វើតេស្តយ៉ាងហោចណាស់ពីរមុខវិជ្ជាក្នុងចំណោមមុខវិជ្ជាទាំងបីរួមមាន គណិតវិទ្យា អំណាន ឬវិទ្យាសាស្ត្រ។

*តារាងទី 2: ចំនួនសិស្សដែលបានចូលរួមធ្វើតេស្តទៅតាមកម្រិតថ្នាក់ យេនឌ័រ តំបន់ ភូមិសាស្ត្រ និងការគ្រប់គ្រងសាលារៀន*

| លក្ខណៈសិស្ស | PISA 2022 | | PISA 2025 | |
|---|---|---|---|---|
| | ចំនួន | ភាគរយ(%) | ចំនួន | ភាគរយ (%) |
| កម្រិតថ្នាក់ | | | | |
| 7 | 238 | 4.5 | 224 | 3.2 |
| 8 | 612 | 11.6 | 644 | 8.9 |
| 9 | 1499 | 28.4 | 2166 | 29.4 |
| 10 | 2228 | 42.2 | 1949 | 46.5 |
| 11 | 660 | 12.5 | 456 | 11.4 |
| 12 | 42 | 0.8 | 25 | 0.7 |
| យេនឌ័រ | | | | |
| ស្រី | 2812 | 53.3 | 2969 | 54.3 |
| ប្រុស | 2467 | 46.7 | 2495 | 45.7 |
| តំបន់ | | | | |
| ប្រជុំជន | 1438 | 27.2 | 1546 | 28.3 |
| ជនបទ | 3841 | 72.8 | 3918 | 71.7 |
| ភូមិសាស្ត្រ | | | | |
| ភ្នំពេញ * | | | 762 | 13.9 |

| | | | | |
|---|---|---|---|---|
| ទំនាប | 2530 | 47.9 | 1955 | 35.8 |
| បឹងទន្លេសាប | 1667 | 31.6 | 1645 | 30.1 |
| ខ្ពង់រាប | 718 | 13.6 | 795 | 14.5 |
| មាត់សមុទ្រ | 364 | 6.9 | 307 | 5.6 |
| ការគ្រប់គ្រងសាលារៀន | | | | |
| សាធារណៈ | 4960 | 94.0 | 5101 | 93.4 |
| ឯកជន | 319 | 6.0 | 363 | 6.6 |
| ចំនួនធ្វើតេស្តសរុប | 5279 | | 5464 | |

** រាជធានីភ្នំពេញ ត្រូវបានបំបែកចេញពីតំបន់ភូមិសាស្ត្រទំនាប នៅក្នុងកម្មវិធី PISA ឆ្នាំ២០២៥*

### ១.២.២. ការប្រមូលទិន្នន័យ

ការប្រមូលទិន្នន័យផ្លូវការសម្រាប់កម្មវិធី PISA ឆ្នាំ២០២៥ បានអនុវត្តចាប់ពីថ្ងៃទី២៣ ដល់ថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០២៥ នៅសាលារៀនសំណាកចំនួន ១៨៦។ លទ្ធផលនៃការប្រមូលទិន្នន័យមានដូចខាងក្រោម៖

- សាលារៀន ១៨៦ បានចូលរួម ដែលស្មើនឹងអត្រាចូលរួមរបស់សាលារៀន ១០០%។
- នាយកសាលារៀន ១៨៦នាក់ បានបំពេញកម្រងសំណួរសម្រាប់សាលារៀន ដែលស្មើនឹងអត្រាចូលរួម ១០០%។
- ក្នុងចំណោមសិស្សសំណាក ៥ ៥៧២នាក់ មានសិស្ស ៥ ៤៦៤នាក់ បានចូលរួមធ្វើតេស្ត ដែលក្នុងនោះ មានសិស្សស្រី ២ ៩៩៥ នាក់ ហើយមានសិស្ស ១០៨ នាក់ អវត្តមាន។
- អត្រាចូលរួមធ្វើតេស្តរបស់សិស្សស្មើនឹង ៩៨.១%។

អត្រាចូលរួមខ្ពស់របស់សាលារៀន និងសិស្ស បង្ហាញពីការអនុវត្តការវាយតម្លៃ PISA ឆ្នាំ២០២៥ នៅកម្ពុជា ប្រកបដោយប្រសិទ្ធភាព និងផ្តល់មូលដ្ឋានដ៏រឹងមាំសម្រាប់ការបង្កើតលទ្ធផលដែលមានភាពជឿជាក់ និងមានភាពតំណាងឱ្យសិស្សនៅទូទាំងប្រទេស។

### ១.២.៣. ការវិភាគទិន្នន័យ និងសរសេររបាយការណ៍

កម្មវិធី PISA រាយការណ៍អំពីលទ្ធផលសិក្សារបស់សិស្សលើមុខវិជ្ជាគណិតវិទ្យា អំណាន និងវិទ្យាសាស្ត្រ ដោយប្រើប្រាស់ពិន្ទុមាត្រដ្ឋាន (scaled scores) ដែលកំណត់សមត្ថភាពរបស់សិស្សនៅលើរង្វាស់មាត្រដ្ឋានរួមមួយ។ វិធីសាស្ត្រនេះអនុញ្ញាតឱ្យមានការប្រៀបធៀបលទ្ធផលសិក្សារបស់សិស្សប្រកបដោយអត្ថន័យរវាងប្រទេស និងតំបន់សេដ្ឋកិច្ចផ្សេងៗ ព្រមទាំងអនុញ្ញាតឱ្យប្រទេសនានាតាមដាននិន្នាការនៃលទ្ធផលសិក្សាតាមវដ្ត PISA ជាបន្តបន្ទាប់។

បន្ថែមពីលើពិន្ទុមធ្យម កម្មវិធី PISA ក៏រាយការណ៍អំពីភាគរយសិស្សដែលស្ថិតនៅក្នុងកម្រិតសមត្ថភាពនីមួយៗផងដែរ។ សមត្ថភាពរបស់សិស្សត្រូវបានពិពណ៌នានៅក្នុងកម្រិតសមត្ថភាពចំនួន ៦ ដោយ កម្រិតទី២ (Level 2) ជាទូទៅត្រូវបានចាត់ទុកថាជាកម្រិតមូលដ្ឋាន។ សិស្សដែលស្ថិតនៅកម្រិតទី២ បង្ហាញថា ពួកគេមានសមត្ថភាពអនុវត្តចំណេះដឹង និងបំណិនរបស់ខ្លួនក្នុងមុខវិជ្ជាគណិតវិទ្យា អំណាន និងវិទ្យាសាស្ត្រ នៅក្នុងជីវភាពប្រចាំថ្ងៃ និងស្ថានភាពជាក់ស្តែងក្នុងជីវិត។

កម្មវិធី PISA ក៏ផ្តល់ការយកចិត្តទុកដាក់យ៉ាងខ្លាំងផងដែរចំពោះសមធម៌ក្នុងការអប់រំ ដោយពិនិត្យមើលភាពខុសគ្នានៃលទ្ធផលសិក្សារបស់សិស្ស ដែលពាក់ព័ន្ធនឹងស្ថានភាពសេដ្ឋកិច្ច-សង្គម យេនឌ័រ លក្ខណៈរបស់សាលារៀន ព្រមទាំងកត្តាផ្សេងៗទៀតពាក់ព័ន្ធនឹងសិស្ស និងគ្រួសារ។ លើសពីនេះ ព័ត៌មានពាក់ព័ន្ធនឹងសាលារៀន គ្រូបង្រៀន សិស្ស និងមាតាបិតា ត្រូវបានវិភាគដើម្បីស្វែងយល់ឱ្យកាន់តែច្បាស់អំពីបរិយាកាសសិក្សា និងកត្តាដែលពាក់ព័ន្ធនឹងលទ្ធផលសិក្សារបស់សិស្ស។

# ២. លទ្ធផលរបស់កម្ពុជានៅក្នុងកម្មវិធី PISA ឆ្នាំ២០២៥

## ២.១. ភាគរយសិស្សអាយុ ១៥ឆ្នាំ នៅកម្ពុជា ដែលកំពុងសិក្សានៅសាលារៀន

ទិន្នន័យកម្មវិធី PISA បង្ហាញថា កម្ពុជាបានពង្រីកវិសាលភាពនៃការគ្របដណ្ដប់របស់កម្មវិធី PISA គួរឱ្យកត់សម្គាល់ ដោយភាគរយសិស្សអាយុ ១៥ឆ្នាំ កើនឡើងពី ២៨.១% នៃយុវជនអាយុ ១៥ឆ្នាំទូទាំងប្រទេសក្នុងឆ្នាំ ២០១៨ ដល់ ៣៦.៣% ក្នុងឆ្នាំ២០២២ និង ៤៣.៨% ក្នុងឆ្នាំ២០២៥។ ការកើនឡើង ១៥.៧% រវាងឆ្នាំ២០១៨ និង២០២៥ នេះ ឆ្លុះបញ្ចាំងពីការរីកចម្រើនយ៉ាងខ្លាំងនៃភាគរយសិស្សអាយុ ១៥ឆ្នាំ ដែលកំពុងស្ថិតនៅក្នុងប្រព័ន្ធអប់រំ និងកំពុងរៀននៅកម្រិតមធ្យមសិក្សា។ ជាលទ្ធផល កម្មវិធី PISA ឆ្នាំ២០២៥ បានឆ្លុះបញ្ចាំងអំពីលទ្ធផលសិក្សារបស់សិស្សអាយុ ១៥ឆ្នាំ នៅកម្ពុជាជិតពាក់កណ្ដាល ដែលធ្វើឱ្យការវាយតម្លៃនេះកាន់តែមានភាពតំណាងឱ្យក្រុមសិស្សវ័យដូចគ្នានៅទូទាំងប្រទេស។ ការកើនឡើងនូវអត្រាគ្របដណ្ដប់នេះ ជាសមិទ្ធផលកម្រិតប្រព័ន្ធអប់រំដ៏សំខាន់មួយ ដែលឆ្លុះបញ្ចាំងពីការទទួលបានឱកាសសិក្សា និងការរក្សាសិស្សឱ្យបន្តរៀនសូត្រនៅកម្រិតមធ្យមសិក្សាកាន់តែច្រើន។

*រូបទី 1: សន្ទស្សន៍គ្របដណ្ដប់នៃសិស្សអាយុ ១៥ឆ្នាំ នៅកម្ពុជា ដែលកំពុងសិក្សានៅក្នុងសាលារៀន*




## ២.២. ភាគរយសិស្សអាយុ ១៥ឆ្នាំ តាមកម្រិតថ្នាក់នីមួយៗ

ចន្លោះឆ្នាំ២០១៨ និង ២០២៥ ប្រទេសកម្ពុជាសម្រេចបាននូវវឌ្ឍនភាពយ៉ាងខ្លាំង ក្នុងការកែលម្អភាពសមស្របរវាងអាយុ និងកម្រិតថ្នាក់របស់សិស្សអាយុ ១៥ឆ្នាំ។ ភាគរយសិស្សដែលរៀននៅថ្នាក់ទី១០ បានកើនឡើងពី ៣៧.៨% នៅឆ្នាំ២០១៨ ទៅ ៤២.២% នៅឆ្នាំ២០២២ និងរហូតដល់ ៤៦.៥% នៅឆ្នាំ២០២៥ ខណៈដែលភាគរយសិស្សនៅថ្នាក់ទី៩ បានកើនឡើងពី ២២.៧% ក្នុងឆ្នាំ២០១៨ ទៅ ២៩.៤% ក្នុងឆ្នាំ២០២៥។ ស្របគ្នានេះដែរ ភាគរយសិស្សអាយុ ១៥ឆ្នាំ ដែលនៅបន្តរៀននៅកម្រិតថ្នាក់ទាបៗ បានធ្លាក់ចុះយ៉ាងច្រើន ដោយថ្នាក់ទី៧ បានធ្លាក់ចុះពី ៥.៨% នៅឆ្នាំ២០១៨ មកត្រឹម ៣.២% នៅឆ្នាំ២០២៥ និងថ្នាក់ទី៨ បានធ្លាក់ចុះពី ១១.៤% នៅឆ្នាំ

២០១៨ មកត្រឹម ៨.៩% នៅឆ្នាំ២០២៥។ ការប្រែប្រួលទាំងនេះបង្ហាញថា សិស្សកម្ពុជាកាន់តែច្រើនកំពុងរៀននៅកម្រិតថ្នាក់ស្របនឹងអាយុរបស់ពួកគេ ដែលឆ្លុះបញ្ចាំងពីការកែលម្អលើការទទួលបានឱកាសសិក្សា ការរក្សាសិស្សឱ្យនៅបន្តរៀនសូត្រ និងការកាត់បន្ថយអត្រាត្រួតថ្នាក់ ដែលជាកត្តាគន្លឹះនៃកំណែទម្រង់វិស័យអប់រំ។

*រូបទី 2: ភាគរយសិស្សអាយុ ១៥ឆ្នាំ តាមកម្រិតថ្នាក់សិក្សានៅកម្ពុជា*




កម្ពុជាបានរក្សាភាគរយសិស្សអាយុ ១៥ឆ្នាំ ក្នុងកម្រិតមួយខ្ពស់បង្គួរឱ្យរៀនស្របតាមអាយុ (រៀននៅថ្នាក់ទី១០ និងកម្រិតថ្នាក់ខ្ពស់ជាងនេះ) និងបានកាត់បន្ថយជាបណ្តើរៗនូវចំនួនសិស្សដែលចូលរៀនយឺត។ ភាគរយសិស្សដែលរៀនស្របតាមអាយុ បានថយចុះមួយរយៈពេលខ្លីពី ៦០.២% ក្នុងឆ្នាំ២០១៨ មកត្រឹម ៥៥.៥% ក្នុងឆ្នាំ២០២២ តែកើនឡើងវិញដល់ ៥៨.៥% ក្នុងឆ្នាំ២០២៥។ ផ្ទុយទៅវិញ ភាគរយសិស្សដែលរៀននៅកម្រិតថ្នាក់ទាបជាងអាយុកំណត់ (ថ្នាក់ទី៧ ដល់ ទី៩) បានកើនឡើងពី ៣៩.៨% ទៅ ៤៤.៥% ចន្លោះឆ្នាំ២០១៨ និង ២០២២ ហើយបន្ទាប់មកបានប្រសើរឡើងវិញមកត្រឹម ៤១.៥% ក្នុងឆ្នាំ២០២៥។ សរុបមក ក្នុងឆ្នាំ២០២៥ សិស្សកម្ពុជាអាយុ ១៥ឆ្នាំ ប្រហែល ៦ នាក់ ក្នុងចំណោម ១០នាក់ បានរៀននៅថ្នាក់ទី១០ ឬកម្រិតថ្នាក់ខ្ពស់ជាងនេះ ដែលបង្ហាញពីវឌ្ឍនភាពជាបន្តបន្ទាប់ក្នុងការរៀនត្រូវថ្នាក់តាមអាយុ និងផ្តល់នូវមូលដ្ឋានគ្រឹះកាន់តែរឹងមាំ និងមានភាពតំណាងគ្រប់ជ្រុងជ្រោយ សម្រាប់ការបកស្រាយលទ្ធផល PISA ឆ្នាំ២០២៥ របស់កម្ពុជា។

*រូបទី 3: ភាគរយសិស្សដែលរៀនយឺតជាងអាយុកំណត់ និងសិស្សដែលរៀនស្របតាមអាយុកំណត់*




## ២.៣. លទ្ធផលនៃការសិក្សារបស់សិស្សកម្ពុជាក្នុងកម្មវិធី PISA

### ២.៣.១. លទ្ធផលគិតជាពិន្ទុ (Scaled Score)

ពិន្ទុជាមធ្យមរបស់បណ្តាប្រទេស OECD មាននិន្នាការថយចុះ។ លទ្ធផលក្នុងកម្មវិធី PISA ឆ្នាំ២០២៥ បានថយចុះទាបជាងវដ្តមុនៗលើគ្រប់មុខវិជ្ជា លើកលែងតែមុខវិជ្ជាវិទ្យាសាស្ត្រមិនសូវថយចុះខ្លាំង។

*រូបទី 4: និន្នាការលទ្ធផលតាមពេលវេលាលើមុខវិជ្ជាវិទ្យាសាស្ត្រ អំណាន និងគណិតវិទ្យា*




ខណៈពេលលទ្ធផលទូទៅរបស់ PISA មាននិន្នាការថយចុះ លទ្ធផលរបស់សិស្សកម្ពុជាបានកើនឡើងប្រកបដោយចីរភាព និងគួរឱ្យស្ញប់ស្ញែងលើមុខវិជ្ជាទាំងបី បើប្រៀបនឹងវដ្តមុនៗ។ លទ្ធផលផ្នែកអំណានបានកើន

ឡើងពី ៣២១ពិន្ទុ នៅឆ្នាំ២០១៨ ទៅ ៣២៩ពិន្ទុ នៅឆ្នាំ ២០២២ និងដល់ ៣៤៧ពិន្ទុ នៅឆ្នាំ ២០២៥ (កើនឡើង ២៦ពិន្ទុ ធៀបនឹងឆ្នាំ២០១៨)។ មុខវិជ្ជាគណិតវិទ្យាបានកើនឡើងពី ៣២៥ពិន្ទុ នៅឆ្នាំ២០១៨ ទៅ ៣៣៦ពិន្ទុ នៅឆ្នាំ២០២២ និងដល់ ៣៦៦ពិន្ទុ នៅឆ្នាំ២០២៥ (កើនឡើង ៤១ពិន្ទុ ធៀបនឹងឆ្នាំ២០១៨) ចំណែកឯមុខវិជ្ជាវិទ្យាសាស្ត្របានកើនឡើងពី ៣៣០ពិន្ទុ នៅឆ្នាំ២០១៨ ទៅ ៣៤៧ពិន្ទុ នៅឆ្នាំ២០២២ និងដល់ ៣៨២ពិន្ទុ នៅឆ្នាំ ២០២៥ (កើនឡើង ៥២ពិន្ទុ ធៀបនឹងឆ្នាំ២០១៨)

កំណើនពិន្ទុមានការកើនយ៉ាងខ្លាំងរវាងឆ្នាំ២០២២ និង ២០២៥ ក្នុងនោះ អំណាន កើន ១៨ពិន្ទុ (៨ ពិន្ទុប៉ុណ្ណោះ រវាងឆ្នាំ ២០១៨ និង ២០២២), គណិតវិទ្យាកើន ៣០ពិន្ទុ (១១ ពិន្ទុប៉ុណ្ណោះរវាងឆ្នាំ២០១៨ និង ២០២២) និងវិទ្យាសាស្ត្រកើន ៣៥ពិន្ទុ (១៧ ពិន្ទុប៉ុណ្ណោះរវាងឆ្នាំ២០១៨ និង ២០២២)។ ការកើនឡើងខ្ពស់បែបនេះបានបង្ហាញថា កម្ពុជាមិនត្រឹមតែរក្សាបាននូវវឌ្ឍនភាពប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងបានបំប្លែងកំណែទម្រង់វិស័យអប់រំ ឱ្យទៅជាការកែលម្អលទ្ធផលសិក្សារបស់សិស្ស ដោយមានសន្ទុះខ្លាំង ជាពិសេសមុខវិជ្ជាវិទ្យាសាស្ត្រ។

កម្ពុជាជាប្រទេសលេចធ្លោមួយក្នុងចំណោមប្រទេសដែលមានការកើនឡើងពិន្ទុដ៏ច្រើនរវាងឆ្នាំ២០២២ និង ២០២៥ ក្នុងនោះកម្ពុជាមានចំណាត់ថ្នាក់លេខ២ ក្នុងចំណោមប្រទេសដែលមានកំណើនពិន្ទុវិទ្យាសាស្ត្រខ្ពស់ បន្ទាប់ពីប្រទេសហុងគ្រី (កើន ៣៨ពិន្ទុ)។ កម្ពុជាមានចំណាត់ថ្នាក់លេខ១ ក្នុងចំណោមប្រទេសដែលមានកំណើនពិន្ទុគណិតវិទ្យាខ្ពស់ និងស្ថិតក្នុងចំណោមប្រទេសដែលមានកំណើនពិន្ទុអំណាន ប្រហាក់ប្រហែលនឹងប្រទេសហ្វីលីពីន (កើន ២០ពិន្ទុ) និងប្រទេសហ្សកដានី (កើន ២០ពិន្ទុ)។

អង្គការ OECD បានកំណត់ស្តង់ដាប្រៀបធៀបថា ២០ ពិន្ទុ ក្នុងកម្មវិធី PISA ប្រហាក់ប្រហែលនឹងចំណេះដឹងក្នុងមួយឆ្នាំសិក្សា សម្រាប់សិស្សអាយុ ១៥ឆ្នាំ[2] ដូចនេះកំណើនពិន្ទុរបស់កម្ពុជា លើមុខវិជ្ជាវិទ្យាសាស្ត្រប្រហាក់ប្រហែលនឹង ១.៨ ឆ្នាំសិក្សា, អំណានប្រហាក់ប្រហែលនឹង ០.៩ ឆ្នាំសិក្សា, និង គណិតវិទ្យាប្រហាក់ប្រហែលនឹង ១.៥ ឆ្នាំសិក្សា។

លទ្ធផលកម្មវិធី PISA ឆ្នាំ២០២៥ ផ្តល់នូវភស្តុតាងយ៉ាងច្បាស់លាស់ និងគួរឱ្យជឿជាក់ថាប្រព័ន្ធអប់រំរបស់កម្ពុជាកំពុងមានការវិវត្តយ៉ាងលឿន ឬអាចនិយាយបានថា កំណែទម្រង់អប់រំនាពេលកន្លងមក និងពេលបច្ចុប្បន្ន ដូចជា ការពង្រីកវិសាលភាពនៃការទទួលបានការអប់រំ, ការពង្រឹងការបង្រៀននិងរៀន , ការលើកកម្ពស់អភិបាលកិច្ចសាលារៀន, និងការលើកកម្ពស់លទ្ធផលសិក្សារបស់សិស្ស កំពុងតែធ្វើឱ្យសមិទ្ធផលសិក្សារបស់សិស្សមានកំណើន និងអាចវាស់វែងបាន។

[2] Changes in performance and equity in education between 2018 and 2022: PISA 2022 Results (Volume I) | OECD

*រូបទី 5: លទ្ធផល PISA របស់កម្ពុជាតាមវដ្តនីមួយៗ*




កម្ពុជាសម្រេចបានលើសសូចនាករសមិទ្ធកម្មគន្លឹះលើវិស័យអប់រំ ដែលបានកំណត់នៅក្នុងយុទ្ធសាស្ត្របញ្ចកោណ ដំណាក់កាលទី១ ដោយកំណត់យកកំណើន ១០ ពិន្ទុ ទាំងលើអំណាន គណិតវិទ្យា និងវិទ្យាសាស្ត្រ នៃកម្មវិធី PISA ត្រឹមឆ្នាំ២០២៨ ប៉ុន្តែត្រឹមឆ្នាំ២០២៥ ប៉ុណ្ណោះ កម្ពុជាសម្រេចបានកំណើន ២៦ពិន្ទុ លើអំណាន, ៤១ ពិន្ទុលើគណិតវិទ្យា, និង ៥២ ពិន្ទុលើវិទ្យាសាស្ត្រ ប្រៀបធៀបទៅនឹងលទ្ធផល PISA-D ដែលជាការសម្រេចបានលើសគោលដៅឆ្នាំ២០២៨ យ៉ាងច្រើន និងមុនកាលកំណត់។

លទ្ធផលទាំងនេះបង្ហាញពីសមិទ្ធផលដ៏ល្អមួយសម្រាប់របៀបវារៈកំណែទម្រង់វិស័យអប់រំនៅកម្ពុជា។ បញ្ហាប្រឈមនៅពេលនេះ គឺត្រូវពង្រឹងសមិទ្ធផលទាំងនេះឱ្យបានរឹងមាំ ធានាថាការកែលម្អត្រូវបានរក្សាឱ្យមាននិរន្តរភាពនៅគ្រប់ក្រុមសិស្សនិងគ្រប់តំបន់ ព្រមទាំងពន្លឿនវឌ្ឍនភាពឆ្ពោះទៅរកកម្រិតសមត្ថភាពកាន់តែខ្ពស់ និងបំណិនមូលដ្ឋានកាន់តែរឹងមាំ។

ទោះជាយ៉ាងណាក៏ដោយ បើប្រៀបធៀបទៅនឹងមធ្យមភាគរបស់ OECD ឆ្នាំ២០២៥ ដែលមាន ៤៦៦ពិន្ទុ លើផ្នែកអំណាន, ៤៦៩ពិន្ទុ លើគណិតវិទ្យា និង ៤៨៦ពិន្ទុ លើវិទ្យាសាស្ត្រ កម្ពុជាទទួលបានពិន្ទុទាបជាង OECD ចំនួន ១១៩ពិន្ទុ, ១០៣ ពិន្ទុ និង ១០៤ពិន្ទុ រៀងគ្នា។ លទ្ធផលទាំងនេះបង្ហាញថា កម្ពុជាបានឈានចូលដល់ដំណាក់កាលនៃការកែលម្អការរៀនសូត្រយ៉ាងឆាប់រហ័ស ប៉ុន្តែត្រូវបន្តពង្រឹងមូលដ្ឋានគ្រឹះនៅបឋមសិក្សា កែលម្អគុណភាពនៃការបង្រៀន ពង្រីកការសិក្សាផ្តោតលើសមត្ថភាព និងផ្តល់ការគាំទ្រចំគោលដៅសិស្សរៀនយឺត ដើម្បីបង្រួមគម្លាតដែលនៅសល់នេះបន្ថែមទៀត និងឈានទៅរកលទ្ធផលដូចប្រទេសសមាជិក OECD។

*រូបទី6: លទ្ធផលកម្ពុជាប្រៀបធៀបទៅនឹងមធ្យមភាគរបស់ប្រទេសសមាជិកអង្គការ OECD*




| មុខវិជ្ជា | ប្រទេសកម្ពុជា 2025 | មធ្យម OECD | គម្លាត (មធ្យម OECD -កម្ពុជា) |
|---|---|---|---|
| អំណាន | 347 | 466 | 119 |
| គណិតវិទ្យា | 366 | 469 | 103 |
| វិទ្យាសាស្ត្រ | 382 | 486 | 104 |

លទ្ធផលរបស់កម្ពុជាទាំងបីមុខវិជ្ជាស្ថិតនៅក្រោមមធ្យមភាគរបស់ OECD ។ គម្លាតធំជាងគេគឺលើផ្នែកអំណាន (១១៩ ពិន្ទុ), វិទ្យាសាស្ត្រ (១០៤ ពិន្ទុ) និងគណិតវិទ្យា (១០៣ ពិន្ទុ)។

រវាងឆ្នាំ ២០២២ និង ២០២៥ កម្ពុជាទទួលបានកំណើន ១៨ពិន្ទុ លើអំណាន, ៣០ពិន្ទុ លើគណិតវិទ្យា, និង ៣៥ពិន្ទុ លើវិទ្យាសាស្ត្រ។ ក្នុងល្បឿននេះ មុខវិជ្ជាគណិតវិទ្យា និងវិទ្យាសាស្ត្រត្រូវបានចាត់ទុកថាជាមុខវិជ្ជាដែលមានសក្តានុពល ដើម្បីឈានទៅសម្រេចបានកម្រិតមធ្យមភាគរបស់ OECD នាពេលបច្ចុប្បន្ន ក្នុងរយៈពេលប្រហែលពី ៣ ទៅ ៤ វដ្តនៃកម្មវិធី PISA។ ទោះជាយ៉ាងណាក៏ដោយ អំណានតម្រូវឱ្យមានល្បឿននៃកំណើនពិន្ទុលឿនជាងមុន គឺប្រហែល ៣០ ទៅ ៤០ ពិន្ទុក្នុងមួយវដ្ត។ ដើម្បីសម្រេចតាមគោលដៅនេះ គឺត្រូវមានការវិនិយោគប្រកបដោយចីរភាពលើមូលដ្ឋានគ្រឹះនៅបឋមសិក្សា ការបង្រៀនមានគុណភាពខ្ពស់ ការបង្រៀនផ្តោតលើសមត្ថភាព និងការគាំទ្រចំគោលដៅសម្រាប់សិស្សរៀនយឺត។

*រូបទី 7: កំណើនពិន្ទុដែលត្រូវការក្នុងមួយវដ្តនៃកម្មវិធី PISA ដើម្បីឈានទៅដល់កម្រិតមធ្យមភាគរបស់ OECD*

## ដំណើររបស់កម្ពុជាទៅរកមធ្យមភាគ OECD

*ដោយសន្មតថាមានកំណើន ៣០ ពិន្ទុ ក្នុងមួយវដ្ត PISA ( ១ វដ្ត មានរយៈពេល ៤ ឆ្នាំ)*

កំណើន ៣០ ពិន្ទុក្នុងមួយវដ្ត PISA ជាប្រចាំ កម្ពុជាអាចនឹងអាចឈានទៅដល់កម្រិតមធ្យមភាគបច្ចុប្បន្ន របស់ OECD ក្នុងរយៈពេលប្រហែល **៤ វដ្តនៃកម្មវិធី PISA**។

| មុខវិជ្ជា | ពិន្ទុកម្ពុជា នៅឆ្នាំ២០២៥ | មធ្យមភាគ OECD ឆ្នាំ២០២៥ | គម្លាត (ពិន្ទុ) | ចំនួនវដ្តដែលត្រូវការ (ប្រហែល) | ត្រឹមឆ្នាំណាដែលឈានទៅដល់កម្រិតមធ្យមភាគរបស់ OECD* |
|---|---|---|---|---|---|
| អំណាន | 347 | 466 | 119 | 4.0 វដ្ត | ត្រឹមឆ្នាំ2041 (បន្ទាប់ 4 វដ្ត) |
| គណិតវិទ្យា | 366 | 469 | 103 | 3.4 វដ្ត | ត្រឹមឆ្នាំ2038 (បន្ទាប់ 3.4 វដ្ត) |
| វិទ្យាសាស្ត្រ | 382 | 486 | 104 | 3.5 វដ្ត | ត្រឹមឆ្នាំ2039 (បន្ទាប់ 3.5 វដ្ត) |

**ផ្អែកលើកម្មវិធី PISA ២០២៥។ ការព្យាករណ៍នេះសន្មតថាមធ្យមភាគរបស់ OECD នៅតែរក្សានៅកម្រិតបច្ចុប្បន្ន។*

*ចំណាំ៖ ការគណនានេះផ្អែកលើពិន្ទុ PISA ឆ្នាំ២០២៥។ វដ្ត PISA នីមួយៗស្មើ ៤ ឆ្នាំ។*

ក្នុងចំណោមប្រទេសចំនួន ៩១ ដែលបានចូលរួមអនុវត្ត PISA ឆ្នាំ ២០២៥ លទ្ធផលសិក្សារបស់សិស្សកម្ពុជាស្ថិតក្នុងលំដាប់លេខរៀង៖ ៧៥ ខាងផ្នែកវិទ្យាសាស្ត្រ, ៨១ ខាងផ្នែកអំណាន និង៧៧ ខាងផ្នែកគណិតវិទ្យា។

ក្នុងចំណោមប្រទេសអាស៊ាន ខាងផ្នែកវិទ្យាសាស្ត្រ សិស្សកម្ពុជាមានពិន្ទុខ្ពស់ជាងហ្វីលីពីន និងផ្នែកគណិតវិទ្យា សិស្សកម្ពុជាមានពិន្ទុខ្ពស់ជាងប្រទេសឥណ្ឌូនេស៊ី។

*រូបទី៨: លទ្ធផលអំណានរបស់ប្រទេសមានពិន្ទុខ្ពស់បំផុត៥, បណ្ដាប្រទេសអាស៊ាន, និងប្រទេសមានពិន្ទុក្រោមកម្ពុជា*



*រូបទី១: លទ្ធផលគណិតវិទ្យារបស់ប្រទេសមានពិន្ទុខ្ពស់បំផុត៥, បណ្តាប្រទេសអាស៊ាន, និងប្រទេសមានពិន្ទុក្រោមកម្ពុជា*



*រូបទី 10: លទ្ធផលវិទ្យាសាស្ត្ររបស់ប្រទេសមានពិន្ទុខ្ពស់បំផុត៥, បណ្តាប្រទេសអាស៊ាន, និងប្រទេសមានពិន្ទុក្រោមកម្ពុជា*



### ២.៣.២ លទ្ធផលតាមកម្រិតសមត្ថភាពសិស្ស

*កម្រិតសមត្ថភាពសិស្សលើមុខវិជ្ជាវិទ្យាសាស្ត្រ*

លទ្ធផលមុខវិជ្ជាវិទ្យាសាស្ត្ររបស់កម្ពុជា បង្ហាញពីការរីកចម្រើនខ្លាំងជាងគេបំផុតក្នុងចំណោមមុខវិជ្ជាទាំងបីនៅក្នុងកម្មវិធី PISA រវាងឆ្នាំ២០១៨ និង ២០២៥ ដោយមានការកើនឡើងយ៉ាងខ្លាំងរវាងឆ្នាំ២០២២ និង ២០២៥។

សិស្សស្ថិតនៅក្រោមកម្រិត១ក គឺជាសិស្សដែលមានការយល់ដឹងក្រោមកម្រិតមូលដ្ឋាន លើមុខវិជ្ជាវិទ្យាសាស្ត្រ បានធ្លាក់ចុះពី ៥២.៦% ក្នុងឆ្នាំ២០១៨ មកត្រឹម ៤០.១% ក្នុងឆ្នាំ២០២២ និងនៅសល់ត្រឹម ២៣.២% ក្នុងឆ្នាំ ២០២៥។

សិស្សស្ថិតនៅកម្រិត១ក គឺជាសិស្សដែលមានការយល់ដឹងកម្រិតមូលដ្ឋាន ប៉ុន្តែមិនទាន់ឈានដល់កម្រិតសមត្ថភាពអប្បបរមានៅឡើយ បានកើនឡើងពី ៤២.៣% ក្នុងឆ្នាំ២០១៨ ទៅ ៤៩.៥% ក្នុងឆ្នាំ២០២២ និងថយមកត្រឹម ៤៤.៣% វិញ ក្នុងឆ្នាំ២០២៥។ ការប្រែប្រួលនេះបង្ហាញថារវាងឆ្នាំ២០២២ និង ២០២៥ សិស្សមួយចំនួនធំបានវិវត្តលឿនឆ្លងផុតពីកម្រិត ១ក ឈានចូលទៅកាន់កម្រិតសមត្ថភាពដែលខ្ពស់ជាងនេះ។

សិស្សសម្រេចបានកម្រិត ២ ឬខ្ពស់ជាងនេះ ដែលជាស្តង់ដាប្រៀបធៀបសមត្ថភាពអប្បបរមារបស់កម្មវិធី PISA បានកើនឡើងយ៉ាងគំហុកពី ៥.២% ក្នុងឆ្នាំ២០១៨ ទៅ ១០.៤% ក្នុងឆ្នាំ២០២២ និងដល់ ៣២.៦% ក្នុងឆ្នាំ ២០២៥។ ការកើនឡើងខ្លាំងបើធៀបនឹងឆ្នាំ២០២២ គឺ ២២.២% បើធៀបនឹងឆ្នាំ២០១៨ គឺ ២៧.៤% មានន័យថា ចំនួនសិស្សដែលសម្រេចបានកម្រិតសមត្ថភាពអប្បបរមា បានកើនឡើងជាង ៦ ដង។

សិស្សឆ្នើម ដែលជាសិស្សសម្រេចបានលទ្ធផលខ្ពស់ជាងកម្រិត ២ មាន ៥.៦% ក្នុងឆ្នាំ២០២៥។ ក្រុមសិស្សឆ្នើមទាំងនោះ បង្ហាញអំពីវឌ្ឍនភាពរបស់សិស្សកម្ពុជាលើមុខវិជ្ជាវិទ្យាសាស្ត្រ ដែលមានសមត្ថភាពលើកម្រិតសមត្ថភាពអប្បបរមា មានន័យថាសិស្សកាន់តែច្រើនចាប់ផ្តើមមានចំណេះដឹងវិទ្យាសាស្ត្រ និងបំណិនផ្តល់ហេតុផលកាន់តែខ្ពស់។

*រូបទី 11: កម្រិតសមត្ថភាពសិស្សលើមុខវិជ្ជាវិទ្យាសាស្ត្រ*




## *កម្រិតសមត្ថភាពសិស្សលើមុខវិជ្ជាគណិតវិទ្យា*

លទ្ធផលមុខវិជ្ជាគណិតវិទ្យារបស់កម្ពុជា ត្រូវបានកែលម្អយ៉ាងច្រើននៅគ្រប់កម្រិតសមត្ថភាពទាំងអស់រវាងឆ្នាំ២០១៨ និង ២០២៥ ជាពិសេសរវាងឆ្នាំ២០២២ និង ២០២៥។

សិស្សស្ថិតនៅក្រោមកម្រិត ១ក គឺជាសិស្សដែលមានបំណិនគណិតវិទ្យាក្រោមកម្រិតមូលដ្ឋាន បានថយចុះពី ៦៦.៨% ក្នុងឆ្នាំ២០១៨ មក ៦១.៩% ក្នុងឆ្នាំ២០២២ និងដល់ ៤៥.៤% ក្នុងឆ្នាំ២០២៥ (ថយ ២១.៤% រវាងឆ្នាំ២០១៨ និង២០២៥, ថយ ១៦.៥% រវាងឆ្នាំ២០២២ និង២០២៥)។

សិស្សស្ថិតនៅកម្រិត១ក គឺជាសិស្សដែលមានបំណិនគណិតវិទ្យាកម្រិតមូលដ្ឋាន ប៉ុន្តែមិនទាន់ឈានដល់កម្រិតសមត្ថភាពអប្បបរមានៅឡើយ បានកើនឡើងពី ២៣.៣% ក្នុងឆ្នាំ២០១៨ ទៅ ២៦.១% ក្នុងឆ្នាំ២០២២ និងដល់ ៣៦.៦% ក្នុងឆ្នាំ២០២៥។ កំណើនដ៏ធំរវាងឆ្នាំ២០២២ និង ២០២៥ (កើន ១០.៥ %) បង្ហាញថាមានសិស្សមួយចំនួនធំបានឆ្លងចេញពីកម្រិតសមត្ថភាពទាបបំផុត។

សិស្សសម្រេចបានកម្រិត ២ ឬខ្ពស់ជាងនេះ ដែលជាស្តង់ដាប្រៀបធៀបសមត្ថភាពអប្បបរមារបស់កម្មវិធី PISA បានកើនឡើងពី ៩.៩% ក្នុងឆ្នាំ២០១៨ ដល់ ១២.០% ក្នុងឆ្នាំ២០២២ និង ១៨.០% ក្នុងឆ្នាំ២០២៥។

កំណើនភាគរយសិស្សបានកើនឡើង ៦.០% រវាងឆ្នាំ២០២២ និងឆ្នាំ២០២៥ និង ៨.១% រវាងឆ្នាំ២០១៨ និងឆ្នាំ ២០២៥ មានន័យថាចំនួនសិស្សដែលសម្រេចបានសមត្ថភាពគណិតវិទ្យាអប្បបរមាបានកើនឡើងប្រហែល២ ដង។

សិស្សឆ្នើម ដែលជាសិស្សសម្រេចបានលទ្ធផលខ្ពស់ជាងកម្រិត ២ មាន ២.៧% ក្នុងឆ្នាំ២០២៥។ ប្រការនេះបង្ហាញថាការកែលម្អគឺមានទាំងលើក្រុមសិស្សដែលមានសមត្ថភាពទាប និងក្រុមសិស្សឆ្នើម។

*រូបទី 12: កម្រិតសមត្ថភាពសិស្សលើមុខវិជ្ជាគណិតវិទ្យា*




## *កម្រិតសមត្ថភាពសិស្សលើផ្នែកអំណាន*

សមត្ថភាពអំណានរបស់សិស្សកម្ពុជាមានការប្រែប្រួលជាវិជ្ជមាននៅគ្រប់កម្រិតសមត្ថភាពចាប់ពីឆ្នាំ ២០១៨ ដល់ឆ្នាំ ២០២៥ ជាពិសេសមានកំណើនខ្លាំងរវាងឆ្នាំ២០២២ និងឆ្នាំ២០២៥។

សិស្សស្ថិតនៅក្រោមកម្រិត១ក គឺជាសិស្សដែលមានបំណិនអំណានក្រោមកម្រិតមូលដ្ឋាន បានថយចុះយ៉ាងច្រើនពី ៥៧.៦% ក្នុងឆ្នាំ២០១៨ មក ៥៣.៤% ក្នុងឆ្នាំ២០២២ និងមកត្រឹម ៣៨.១% ក្នុងឆ្នាំ២០២៥ (ថយ ១៩.៥% រវាងឆ្នាំ២០១៨ និង២០២៥)។

សិស្សស្ថិតនៅកម្រិត១ក គឺជាសិស្សដែលមានបំណិនអំណានកម្រិតមូលដ្ឋាន ប៉ុន្តែមិនទាន់ឈានដល់កម្រិតសមត្ថភាពអប្បបរមានៅឡើយ បានកើនឡើងពី ៣៤.៩% ក្នុងឆ្នាំ២០១៨ ដល់ ៣៨.៧% ក្នុងឆ្នាំ២០២២

និង ៤៨.៥% ក្នុងឆ្នាំ២០២៥។ កំណើនដ៏ធំរវាងឆ្នាំ២០២២ និង ២០២៥ (កើន ៩.៩ %) បង្ហាញពីសមត្ថភាពរបស់សិស្សបានប្រែប្រួលជាវិជ្ជមានចេញពីកម្រិតសមត្ថភាពទាបបំផុត។

សិស្សសម្រេចបានកម្រិត ២ ឬខ្ពស់ជាងនេះ ដែលជាស្តង់ដាប្រៀបធៀបសមត្ថភាពអប្បបរមារបស់កម្មវិធី PISA បានកើនឡើងពី ៧.៥% ក្នុងឆ្នាំ២០១៨ ដល់ ៧.៩% ក្នុងឆ្នាំ២០២២ និងដល់ ១៣.៣% ក្នុងឆ្នាំ២០២៥។ ទោះបីជាមានការកើនឡើងតិចតួចរវាងឆ្នាំ២០១៨ និងឆ្នាំ២០២២ ក៏ដោយ ប៉ុន្តែភាគរយសិស្សបានកើនឡើង ៥.៤% រវាងឆ្នាំ២០២២ និងឆ្នាំ២០២៥ និងប្រហែលពីរដង បើធៀបនឹងឆ្នាំ២០១៨។

*រូបទី 13: កម្រិតសមត្ថភាពសិស្សលើផ្នែកអំណាន*




**ចំណុចសំខាន់ៗ**

ចាប់ពីឆ្នាំ២០១៨ ដល់ឆ្នាំ២០២៥ ភាគរយសិស្សដែលនៅទាបជាងកម្រិត ១ក បានថយចុះយ៉ាងខ្លាំងពី ៥៧.៦% មកត្រឹម ៣៨.១% ចំណែកឯសិស្សស្ថិតនៅកម្រិត ១ក បានកើនឡើងពី ៣៤.៩% ទៅ ៤៨.៥%។ អ្វីដែលសំខាន់បំផុតនោះ ភាគរយសិស្សដែលសម្រេចបានកម្រិត ២ ឬខ្ពស់ជាងនេះ បានកើនឡើងជិតទ្វេដង គឺពី ៧.៥% ទៅ ១៣.៣%។ លទ្ធផលនេះឆ្លុះបញ្ចាំងពីការរីកចម្រើនយ៉ាងខ្លាំងលើសមត្ថភាពអំណាន។

## ២.៤. ការប្រៀបធៀបសមធម៌

### ២.៤.១. លទ្ធផលតាមយេនឌ័រ

នៅកម្ពុជា សិស្សស្រីនៅតែបន្តទទួលបានលទ្ធផលខ្ពស់ជាងសិស្សប្រុសលើផ្នែកអំណាន និងវិទ្យាសាស្ត្រ លើកលែងតែពិន្ទុគណិតវិទ្យាដែលស្ទើរតែស្មើគ្នា។ ចំពោះអំណាន សិស្សស្រីមានពិន្ទុខ្ពស់ជាងសិស្សប្រុស ១៧ពិន្ទុ ក្នុងឆ្នាំ២០១៨, ២០ពិន្ទុ ក្នុងឆ្នាំ២០២២ និង ១៧ពិន្ទុ ក្នុងឆ្នាំ២០២៥ ដែលបង្ហាញពីគម្លាតនៅតែបន្តមាន ប៉ុន្តែបានថយចុះបន្តិចបើធៀបនឹងឆ្នាំ២០២២។ ចំពោះវិទ្យាសាស្ត្រ គម្លាតនេះបានកើនឡើងពី ៤ពិន្ទុ ក្នុងឆ្នាំ២០១៨ ដល់ ៩

ពិន្ទុ ក្នុងឆ្នាំ២០២២ និង ១៤ពិន្ទុ ក្នុងឆ្នាំ២០២៥ ដែលឆ្លុះបញ្ចាំងពីការកែលម្អកាន់តែខ្លាំងក្នុងចំណោមសិស្សស្រី។ ផ្ទុយទៅវិញ លទ្ធផលមុខវិជ្ជាគណិតវិទ្យារបស់សិស្សស្រីដែលខ្ពស់ជាងសិស្សប្រុស ៤ពិន្ទុ ក្នុងឆ្នាំ២០២២ បានថយចុះមកត្រឹម ២ពិន្ទុ ក្នុងឆ្នាំ២០២៥ ដែលបញ្ជាក់ថាកម្ពុជាសម្រេចបានសមភាពយេនឌ័រក្នុងមុខវិជ្ជាគណិតវិទ្យា។

លទ្ធផលទាំងនេះបានលើកទឹកចិត្តយ៉ាងខ្លាំងដល់កម្ពុជា៖ ការកែលម្អយ៉ាងឆាប់រហ័សពីឆ្នាំ២០២២ ដល់ឆ្នាំ ២០២៥ បានផ្តល់ផលប្រយោជន៍ដល់ទាំងសិស្សប្រុស និងសិស្សស្រី ជាពិសេសលទ្ធផលសិក្សាមុខវិជ្ជាគណិតវិទ្យាបង្ហាញថា គម្លាតយេនឌ័រត្រូវបានកាត់បន្ថយយ៉ាងច្រើន។ អាទិភាពបន្ទាប់ កម្ពុជាត្រូវរក្សាកំណើននៃការរីកចម្រើនយ៉ាងឆាប់រហ័សនេះ ព្រមទាំងដោះស្រាយគម្លាតដែលនៅសេសសល់ ដូចជា ពិន្ទុផ្នែកអំណានរបស់សិស្សស្រីដែលខ្ពស់ជាងសិស្សប្រុស និងគម្លាតលទ្ធផលសិក្សាមុខវិជ្ជាវិទ្យាសាស្ត្រដែលកំពុងកើនឡើង។ យុទ្ធសាស្ត្រជាក់លាក់គឺពង្រឹងការអាន និងការរៀនមុខវិជ្ជាវិទ្យាសាស្ត្ររបស់សិស្សប្រុស ព្រមទាំងរក្សាលទ្ធផលល្អរបស់សិស្សស្រី និងធានាឱ្យមានឱកាសសិក្សាស្មើគ្នាសម្រាប់សិស្សទាំងពីរភេទ ដែលអាចជួយឱ្យកម្ពុជាសម្រេចបានលទ្ធផលសិក្សាកាន់តែខ្ពស់ និងមានសមធម៌ជាងមុន។

*រូបទី 14: គម្លាតយេនឌ័រ*




## ២.៤.២. លទ្ធផលតាមទីតាំងសាលារៀន

លទ្ធផល PISA របស់កម្ពុជាបង្ហាញពីការកាត់បន្ថយយ៉ាងច្បាស់លាស់ និងប្រកបដោយចីរភាពនៃគម្លាតសិក្សារវាងសិស្សមកពីប្រជុំជន និងជនបទ លើមុខវិជ្ជាទាំងបី ដែលបញ្ជាក់ថា ការកែលម្អកំពុងកើតនិងកើនឡើងមិនត្រឹមតែលើសាលារៀនក្នុងតំបន់ប្រជុំជននោះទេ។ ចាប់ពីឆ្នាំ២០១៨ ដល់ឆ្នាំ២០២៥ គម្លាតពិន្ទុលើផ្នែកអំណានបានថយចុះពី ៤២ពិន្ទុ មក ១៧ពិន្ទុ, គណិតវិទ្យាពី ៥១ពិន្ទុ មក ២១ពិន្ទុ និងវិទ្យាសាស្ត្រពី ២៨ពិន្ទុ មក ១៩ពិន្ទុ។

ការកែលម្អដែលគួរឱ្យកត់សម្គាល់បំផុតបានកើតឡើងលើមុខវិជ្ជាគណិតវិទ្យា ដែលគម្លាតត្រូវបានកាត់បន្ថយចំនួន ៣០ពិន្ទុ ចំណែកឯផ្នែកអំណានបានកាត់បន្ថយ ២៥ពិន្ទុ។ អ្វីដែលសំខាន់នោះគឺសិស្សនៅជនបទបាន

រីកចម្រើនយ៉ាងខ្លាំងក្នុងអំឡុងពេលនេះ៖ លទ្ធផលផ្នែកអំណានរបស់សិស្សនៅជនបទ បានកើនឡើងពី ៣១០ពិន្ទុ ដល់ ៣៤២ពិន្ទុ, គណិតវិទ្យាពី ៣១១ពិន្ទុ ដល់ ៣៦០ពិន្ទុ, និងវិទ្យាសាស្ត្រពី ៣២៣ពិន្ទុ ដល់ ៣៧៦ពិន្ទុ។ ត្រឹមឆ្នាំ ២០២៥ គម្លាតពិន្ទុនៅឆ្នាំមុនដែលនៅសល់ បានរួមតូចជាងមុន ជាពិសេសលើផ្នែកអំណាន និងគណិតវិទ្យា។

លទ្ធផលទាំងនេះបង្ហាញថា កំណែទម្រង់នាពេលថ្មីៗនេះរបស់កម្ពុជា កំពុងជួយកាត់បន្ថយភាពខុសគ្នារវាងទីតាំងភូមិសាស្ត្រសាលារៀនទាក់ទងនឹងឱកាសសិក្សា និងលទ្ធផលសិក្សារបស់សិស្ស ដែលអាចនិយាយបានថា សិស្សនៅជនបទទទួលបានលទ្ធផលល្អដូចសិស្សនៅប្រជុំជនដែរ។ វឌ្ឍនភាពនេះបង្ហាញពីការរីកចម្រើនគួរឱ្យកត់សម្គាល់ ទោះបីជាកម្ពុជាមានស្ថានភាពខុសគ្នាខ្លាំងរវាងតំបន់ប្រជុំជន និងជនបទ ទាក់ទងនឹងធនធានសាលារៀន និងលក្ខខណ្ឌសិក្សាក៏ដោយ។ បញ្ហាប្រឈមនៅពេលនេះ គឺត្រូវធ្វើយ៉ាងណាដើម្បីរក្សាកំណើននេះ និងបន្តវិនិយោគលើសាលារៀននៅជនបទ ដើម្បីកាត់បន្ថយគម្លាតសិក្សា។

*រូបទី 15: គម្លាតរវាងប្រជុំជន និងជនបទ*




### ២.៤.៣. លទ្ធផលតាមប្រភេទសាលារៀន

លទ្ធផល PISA ចាប់ពីឆ្នាំ២០១៨ ដល់ឆ្នាំ២០២៥ បង្ហាញពីការប្រែប្រួលជាវិជ្ជមានលើលទ្ធផលសិក្សារបស់សិស្សនៅសាលារៀនសាធារណៈ ដោយមានកំណើនយ៉ាងច្រើនលើមុខវិជ្ជាទាំងបី។ រវាងឆ្នាំ២០១៨ និងឆ្នាំ២០២៥ សិស្សនៅសាលារៀនសាធារណៈបានកើន ២៥ពិន្ទុ លើផ្នែកអំណាន (ពី ៣១៩ពិន្ទុ ដល់ ៣៤៤ពិន្ទុ), ៣៩ពិន្ទុ លើមុខវិជ្ជាគណិតវិទ្យា (ពី ៣២៣ពិន្ទុ ដល់ ៣៦២ពិន្ទុ) និង ៤៩ ពិន្ទុ លើមុខវិជ្ជាវិទ្យាសាស្ត្រ (ពី ៣២៩ពិន្ទុ ដល់ ៣៧៨ពិន្ទុ)។

ក្នុងពេលជាមួយគ្នានេះ សាលារៀនឯកជននៅតែបន្តទទួលបានលទ្ធផលសិក្សាកើនឡើង ដោយទទួលបាន ៣៧៧ពិន្ទុ លើផ្នែកអំណាន, ៤១០ពិន្ទុ លើមុខវិជ្ជាគណិតវិទ្យា, និង ៤២១ពិន្ទុ លើមុខវិជ្ជាវិទ្យាសាស្ត្រ ក្នុងឆ្នាំ ២០២៥។ ទោះជាយ៉ាងនេះក្តី គម្លាតលទ្ធផលសិក្សារវាងសាលារៀនសាធារណៈ និងសាលារៀនឯកជន បានប្រែប្រួលយ៉ាងខ្លាំងពីមួយវដ្តទៅមួយវដ្ត។ ជាឧទាហរណ៍ ចំពោះមុខវិជ្ជាគណិតវិទ្យា គម្លាតនេះបានកើនឡើងពី ៦៩ពិន្ទុ ក្នុងឆ្នាំ២០១៨ ដល់ ៧៥ពិន្ទុ ក្នុងឆ្នាំ ២០២២ ប៉ុន្តែបានរួមតូចយ៉ាងខ្លាំងមកត្រឹម ៤៨ ពិន្ទុវិញ ក្នុងឆ្នាំ២០២៥។ ចំពោះមុខវិជ្ជាវិទ្យាសាស្ត្រ គម្លាតនេះបានរួមតូចពី ៤០ពិន្ទុ ក្នុងឆ្នាំ២០១៨ មក ៣៩ពិន្ទុ ក្នុងឆ្នាំ២០២២ និង ៤៣ពិន្ទុ ក្នុងឆ្នាំ២០២៥ ចំណែកឯអំណាន គម្លាតបានរួមតូចពី ៥៩ពិន្ទុ ក្នុងឆ្នាំ២០១៨ មក ៤១ពិន្ទុ ក្នុងឆ្នាំ២០២២ និង ៣៣ពិន្ទុ ក្នុងឆ្នាំ២០២៥។

*រូបទី 16: លទ្ធផលតាមប្រភេទសាលារៀន*




## ២.៤.៤. លទ្ធផលតាមស្ថានភាពសេដ្ឋកិច្ច-សង្គម

លទ្ធផល PISA របស់កម្ពុជា ចាប់ពីឆ្នាំ២០១៨ ដល់ឆ្នាំ២០២៥ មានអត្ថន័យធំធេងណាស់ បើប្រៀបធៀបទៅនឹងការអភិវឌ្ឍសេដ្ឋកិច្ចរបស់ប្រទេស និងការផ្តល់ធនធានសម្រាប់ប្រព័ន្ធអប់រំ។ ក្នុងនាមជាប្រទេសដែលមានប្រាក់ចំណូលមធ្យមកម្រិតទាប និងមានផលិតផលក្នុងស្រុកសរុប (GDP) សម្រាប់មនុស្សម្នាក់ៗប្រមាណ ២ ៨៧២ ដុល្លារអាមេរិក ក្នុងឆ្នាំ២០២៥ កម្ពុជាសម្រេចបាននូវការរីកចម្រើនគួរឱ្យកត់សម្គាល់លើការសិក្សារបស់សិស្ស ទោះបីជាធនធាននៅមានកម្រិតក៏ដោយ។ រវាងឆ្នាំ២០១៨ និងឆ្នាំ២០២៥ សិស្សមកពីគ្រួសារមានជីវភាពទាប ទទួលបានកំណើន ៥៨ពិន្ទុ លើមុខវិជ្ជាវិទ្យាសាស្ត្រ, ៥៤ពិន្ទុ លើមុខវិជ្ជាគណិតវិទ្យា, និង ៣៤ពិន្ទុ លើផ្នែកអំណាន ចំណែកឯសិស្សមកពីគ្រួសារមានជីវភាពខ្ពស់ ទទួលបានកំណើន ៧០ពិន្ទុ, ៥៤ពិន្ទុ និង ៣៧ពិន្ទុ រៀងគ្នា។

កំណើន បានកើតឡើងក្នុងរយៈពេលដ៏ខ្លី និងបានបង្ហាញយ៉ាងច្បាស់ថា វឌ្ឍនភាពរបស់កម្ពុជាបានកើតឡើងលើក្រុមគោលដៅទាំងអស់ ដោយមិនគ្រាន់តែលើក្រុមសិស្សមកពីគ្រួសារមានជីវភាពខ្ពស់នោះទេ។

ទំហំកំណើនពិន្ទុរបស់ក្រុមសិស្សមានជីវភាពទាប គឺជាសញ្ញាលើកទឹកចិត្តយ៉ាងខ្លាំង។ ពិន្ទុរបស់សិស្សមកពីគ្រួសារមានជីវភាពទាបបានកើនពី ៣២៣ ដល់ ៣៨១ លើមុខវិជ្ជាវិទ្យាសាស្ត្រ, ពី ៣០៨ ដល់ ៣៦២ លើមុខវិជ្ជាគណិតវិទ្យា, និងពី ៣១០ ដល់ ៣៤៤ លើផ្នែកអំណាន។ លទ្ធផលមុខវិជ្ជាវិទ្យាសាស្ត្រមានកំណើនលេចធ្លោជាងគេ គឺ ៥៨ពិន្ទុ ចំពោះក្រុមសិស្សមកពីគ្រួសារមានជីវភាពទាប។ មុខវិជ្ជាគណិតវិទ្យាក៏បង្ហាញចំណុចគួរឱ្យកត់សម្គាល់ផងដែរ ដោយសារក្រុមសិស្សមកពីគ្រួសារមានជីវភាពខ្ពស់ និងទាប ទទួលបានកំណើន ៥៤ពិន្ទុ ដូចគ្នា រវាងឆ្នាំ២០១៨ និងឆ្នាំ២០២៥។ លទ្ធផលទាំងនេះផ្តល់នូវភស្តុតាងយ៉ាងរឹងមាំថា ការរីកចម្រើនក្នុងវិស័យអប់រំនាពេលថ្មីៗនេះរបស់កម្ពុជា កំពុងគ្របដណ្តប់ដល់សិស្សគ្រប់ស្ថានភាពសេដ្ឋកិច្ច-សង្គម។

ទន្ទឹមនឹងនេះដែរ លទ្ធផលទាំងនេះបានបង្ហាញពីសក្តានុពលរបស់កម្ពុជាដែលមិនធ្លាប់មានពីមុនមក ដូចជា មានក្រុមសិស្សមួយចំនួនទទួលបានពិន្ទុ ៤០០ ឬខ្ពស់ជាងនេះរួចទៅហើយ។ ជាក់ស្តែង ក្រុមសិស្សមកពីគ្រួសារមានជីវភាពខ្ពស់ទទួលបាន ៤១៤ពិន្ទុ លើមុខវិជ្ជាវិទ្យាសាស្ត្រ និង ៤០៧ពិន្ទុ លើមុខវិជ្ជាគណិតវិទ្យា។ នេះមិនមែនជាស្តង់ដាខាងក្រៅ ឬគ្រាន់តែជាទ្រឹស្តីនោះឡើយ ប៉ុន្តែវាគឺជាកម្រិតសមត្ថភាពរបស់សិស្សកម្ពុជាពិតប្រាកដ។ ដូចនេះបញ្ហាប្រឈម មិនមែនស្ថិតនៅលើសំណួរដែលថា តើសិស្សកម្ពុជាអាចសម្រេចនូវលទ្ធផលខ្ពស់ជាងនេះបានឬយ៉ាងណានោះទេ ប៉ុន្តែគួរពិចារណាថា តើកម្ពុជាអាចពង្រីកវិសាលភាពនៃលក្ខខណ្ឌគាំទ្រដោយរបៀបណា ដើម្បីឱ្យក្រុមសិស្សកាន់តែច្រើនជាងមុន ជាពិសេសសិស្សមានជីវភាពទាប ទទួលបានពិន្ទុ ៤០០ ឬខ្ពស់ជាងនេះ។ ប្រការនេះផ្តល់នូវអំណះអំណាងសម្រាប់ការផ្លាស់ប្តូរពី "ឧត្តមភាពលើផ្នែកតូចៗ" ទៅជា "ឧត្តមភាពលើប្រព័ន្ធទាំងមូល"។

ទោះជាយ៉ាងណាក៏ដោយ លទ្ធផលទាំងនេះមិនត្រូវបានបកស្រាយជាភស្តុតាងដែលបង្ហាញថា កម្ពុជាអាចសម្រេចបានវឌ្ឍនភាពនាពេលអនាគត ដោយមិនចាំបាច់មានការវិនិយោគបន្ថែមនោះទេ។ ផ្ទុយទៅវិញ លទ្ធផលទាំងនេះបានផ្តល់អំណះអំណាងយ៉ាងរឹងមាំ សម្រាប់បង្កើនការវិនិយោគ និងពង្រឹងប្រសិទ្ធភាពការវិនិយោគ។ កម្ពុជាបានបង្ហាញឱ្យឃើញថា ការកែទម្រង់របស់ខ្លួនអាចបង្កើតបាននូវផលត្រឡប់មកវិញយ៉ាងគាប់ប្រសើរ។ ជំហានបន្ទាប់ កម្ពុជាត្រូវពង្រីកវិសាលភាពនៃកំណែទម្រង់ ផ្តល់ធនធានកាន់តែច្រើន និងកំណត់គោលដៅកាន់តែច្បាស់លាស់។ នៅពេលសេដ្ឋកិច្ចបន្តអភិវឌ្ឍ ការកើនឡើងនៃការវិនិយោគលើគ្រូបង្រៀន គុណភាពនៃការបង្រៀន ការអប់រំកម្រិតមធ្យមសិក្សា បរិស្ថានសិក្សា ការដឹកនាំសាលារៀន និងការគាំទ្រចំគោលដៅសម្រាប់ក្រុមសិស្សងាយរងគ្រោះ នឹងក្លាយជាកត្តាចាំបាច់បំផុត ដើម្បីរក្សាកំណើន និងបង្កើនល្បឿននៃការអភិវឌ្ឍឱ្យកាន់តែឆាប់រហ័ស។

ទិដ្ឋភាពនៃសមធម៌តម្រូវឱ្យមានការយកចិត្តទុកដាក់ជាពិសេស។ ទោះបីជាក្រុមសិស្សទាំងពីរមានពិន្ទុកើនឡើងយ៉ាងខ្លាំងក៏ដោយ តែគម្លាតរវាងក្រុមសិស្សមានជីវភាពខ្ពស់ និងទាប បានកើនឡើងពី -១ ដល់ ៣៣ពិន្ទុ លើមុខវិជ្ជាវិទ្យាសាស្ត្រ, ពី ១៤ពិន្ទុ ដល់ ៣២ពិន្ទុ លើផ្នែកអំណាន, និងពី ២៤ពិន្ទុ ដល់ ៤៥ពិន្ទុ លើមុខវិជ្ជាគណិតវិទ្យា រវាងឆ្នាំ២០២២ និងឆ្នាំ២០២៥។ គម្លាតដែលកើនឡើងជាងមុននេះ មិនមែនមានន័យថាសិស្សមានជីវភាពទាប

កំពុងរៀនខ្សោយជាងមុននោះទេ តាមពិតពួកគេកំពុងមានកំណើនពិន្ទុយ៉ាងច្រើន។ ប៉ុន្តែលទ្ធផលក៏បង្ហាញថា ក្រុមសិស្សមានជីវភាពខ្ពស់មានភាពរីកចម្រើនលឿនជាងមុន។ មុខវិជ្ជាគណិតវិទ្យាមានបញ្ហាប្រឈមផ្នែកសមធម៌ជាងគេ ដោយមានគម្លាតរហូតដល់ ៤៥ពិន្ទុ ក្នុងឆ្នាំ២០២៥ ទោះបីជាក្រុមសិស្សមានជីវភាពទាប សម្រេចបាននូវកំណើនយ៉ាងច្រើនរហូតដល់ ៥៤ពិន្ទុ ចាប់តាំងពីឆ្នាំ២០១៨ ។

*រូបទី 17: គម្លាតលទ្ធផលសិក្សារវាងសិស្សមកពីគ្រួសារមានជីវភាពខ្ពស់ និងគ្រួសារមានជីវភាពទាប*




តាមរយៈការវិភាគនេះ មានទិដ្ឋភាពគោលនយោបាយសំខាន់ៗចំនួនពីរ៖ កម្ពុជាត្រូវតែរក្សាកំណើន និងបង្កើនសន្ទុះនៃការរៀនសូត្រ ព្រមទាំងធ្វើឱ្យការរីកចម្រើននៅដំណាក់កាលបន្ទាប់កាន់តែមានសមធម៌ជាងមុន។ កម្ពុជាបានបង្ហាញឱ្យឃើញថា ខ្លួនអាចសម្រេចបាននូវលទ្ធផលល្អប្រសើរ ជាមួយនឹងធនធានមានកម្រិត។ បច្ចុប្បន្ននេះ កម្ពុជាមានឱកាសក្នុងការប្រើប្រាស់កំណើនសេដ្ឋកិច្ច និងកំណើនវិនិយោគលើវិស័យអប់រំ ដើម្បីសម្រេចបាននូវសមិទ្ធផលកាន់តែច្រើនក្នុងវិសាលភាពកាន់តែធំ។ វត្ថុបំណងចម្បងគឺធ្វើឱ្យសិស្សដែលទទួលពិន្ទុ ៤០០ ឬខ្ពស់ជាងនេះ មានចំនួនកាន់តែច្រើនក្នុងប្រព័ន្ធអប់រំ។

## ២.៤.៥. សិស្សមានភាពធន់នឹងការសិក្សា

លទ្ធផល PISA ពីឆ្នាំ២០១៨ ដល់ ២០២៥ របស់កម្ពុជាបង្ហាញថា កម្ពុជាមិនត្រឹមតែទទួលបានលទ្ធផលសិក្សាល្អប្រសើរប៉ុណ្ណោះទេ ថែមទាំងកំពុងបង្កើនភាគរយសិស្សដែលមានជីវភាពទាបតែអាចសម្រេចបានជោគជ័យក្នុងការសិក្សា ទោះបីជាមានរបាំងសេដ្ឋកិច្ច-សង្គមក៏ដោយ។

ភាគរយសិស្សដែលមានភាពធន់នឹងការសិក្សា (សិស្សពូកែដែលមកពីគ្រួសារមានជីវភាពទាប) បានកើនឡើងគ្រប់មុខវិជ្ជា ចាប់ពីឆ្នាំ២០១៨ ដល់ឆ្នាំ២០២៥ ដោយផ្នែកអំណានបានកើនឡើងពី ១៤.៩% ដល់ ២១.៣%, គណិតវិទ្យាបានកើនឡើងពី ១៣.០% ដល់ ១៨.៧%, និងមុខវិជ្ជាវិទ្យាសាស្ត្របានកើនឡើងពី ១៥.៩% ដល់ ២២.៤%។

ត្រឹមឆ្នាំ២០២៥ សិស្សកម្ពុជាច្រើនជាង ១នាក់ ក្នុងចំណោម ៥នាក់ ជាសិស្សដែលមានភាពធន់លើមុខវិជ្ជាវិទ្យាសាស្ត្រ និងអំណាន ដែលបង្ហាញថាសិស្សដែលមានជីវភាពទាបក៏អាចសម្រេចបានលទ្ធផលសិក្សាល្អប្រសើរដែរ។

វឌ្ឍនភាពនេះពិតមានអត្ថន័យធំធេងណាស់ ដោយសារការវិភាគលើក្រុមសិស្សមានភាពធន់នេះ មិនត្រឹមតែឆ្លុះបញ្ចាំងលើលទ្ធផលសិក្សារបស់ពួកគេប៉ុណ្ណោះទេ ប៉ុន្តែក៏ឆ្លុះបញ្ចាំងពីភាពប្រសើរឡើងរបស់ប្រព័ន្ធអប់រំកម្ពុជាក្នុងការគាំទ្រសិស្សដែលមានជីវភាពទាបអាចជម្នះរាល់ការលំបាកផ្សេងៗ និងតស៊ូក្នុងការសិក្សា។ ការកើនឡើងនៃសិស្សដែលមានភាពធន់នេះ បង្ហាញថាការកែលម្អលើការបង្រៀន គុណភាពសាលារៀន ឱកាសសិក្សា និងការគាំទ្រសិស្ស បាននិងកំពុងផ្តល់ឱកាសឱ្យសិស្សងាយរងគ្រោះទទួលបានជោគជ័យក្នុងការសិក្សា។

*រូបទី 18: ភាគរយសិស្សមានភាពធន់នឹងការសិក្សា*



# ៣. ចំណាយលើវិស័យអប់រំ និងលទ្ធផលសិក្សារបស់សិស្ស

## ៣.១. លទ្ធផលមុខវិជ្ជាវិទ្យាសាស្ត្រ និងការចំណាយសរុបលើការអប់រំ

ការប្រៀបធៀបរវាងលទ្ធផលសិក្សាមុខវិជ្ជាវិទ្យាសាស្ត្រ និងការចំណាយសរុបលើវិស័យអប់រំ បង្ហាញពីកម្រិតប្រសិទ្ធភាពគួរឱ្យកត់សម្គាល់នៃការវិនិយោគលើវិស័យអប់រំនៅកម្ពុជា។ កម្ពុជាទទួលបានពិន្ទុមធ្យមភាគមុខវិជ្ជាវិទ្យាសាស្ត្រ ៣៨២ពិន្ទុ ដោយមានការចំណាយសរុបចំនួន ៥ ២៩៤ ដុល្លារ[3] ពោលគឺសម្រេចបានលទ្ធផលសិក្សាមុខវិជ្ជាវិទ្យាសាស្ត្រខ្ពស់ជាងប្រព័ន្ធអប់រំនៃប្រទេសមួយចំនួនដែលមានការចំណាយលើការអប់រំខ្ពស់ជាង រួមមាន ប្រទេសហ្វីលីពីន (៣៧៣ពិន្ទុ, ការចំណាយ ១២ ៨៤៥), ម៉ាសេដ្វានខាងជើង (៣៧៨ ពិន្ទុ, ការចំណាយ ៨ ៨៣៣), ក្វាតេម៉ាឡា (៣៥១ពិន្ទុ, ការចំណាយ ១០ ៤១៨) និងសាធារណរដ្ឋដូមីនីក (៣៦១ ពិន្ទុ; ការចំណាយ ៤៨ ៩៩៦)។ បន្ថែមពីនេះ កម្ពុជាក៏ទទួលបានលទ្ធផលប្រហាក់ប្រហែលទៅនឹងប្រទេសឥណ្ឌូនេស៊ីផងដែរ (៣៨៩ពិន្ទុ) ដោយកម្ពុជាប្រើប្រាស់ការចំណាយសរុបលើវិស័យអប់រំត្រឹមតែ ៥ ២៩៤ ប៉ុណ្ណោះ ប្រៀបធៀបនឹងឥណ្ឌូនេស៊ីដែលមានការចំណាយរហូតដល់ ១៩ ៧០០ ពោលគឺមានភាពខុសគ្នា ១៤ ៤០៦ ឬទាបជាងប្រមាណ ៧៣% នៃការចំណាយសរុប។ ចំណុចនេះបង្ហាញថា ការចំណាយខ្ពស់តែមួយមុខមិនជានាំឱ្យលទ្ធផលសិក្សាកើនឡើងខ្ពស់ដោយស្វ័យប្រវត្តិនោះទេ ប៉ុន្តែអាស្រ័យលើប្រសិទ្ធភាពនៃការចំណាយ។ លទ្ធផលខាងលើក៏បង្ហាញដែលថា កម្ពុជាមានមូលដ្ឋានគ្រឹះដ៏រឹងមាំក្នុងការបន្តពង្រឹងប្រសិទ្ធភាពនៃការវិនិយោគលើវិស័យអប់រំរបស់ខ្លួនឱ្យកាន់តែល្អប្រសើរថែមទៀត។

ក្នុងពេលជាមួយគ្នានេះដែរ កម្ពុជានៅមានឱកាសច្រើនទៀតដើម្បីធ្វើឱ្យលទ្ធផលប្រសើរឡើង តាមរយៈការវិនិយោគបន្ថែម និងចំគោលដៅ។ ពិន្ទុមុខវិជ្ជាវិទ្យាសាស្ត្ររបស់កម្ពុជាស្មើនឹង ៣៨២ ស្ថិតនៅក្រោមប្រទេសម៉ាឡេស៊ី (៤១៩ពិន្ទុ), ថៃ (៤៣២ពិន្ទុ) និងវៀតណាម (៤៤៣ពិន្ទុ) ដោយមានគម្លាត ៣៧ពិន្ទុ, ៥០ពិន្ទុ និង ៦១ ពិន្ទុ រៀងគ្នា។ ប៉ុន្តែគួរកត់សម្គាល់ថា ប្រព័ន្ធអប់រំក្នុងតំបន់អាស៊ានដែលមានលទ្ធផលសិក្សាខ្ពស់ជាងកម្ពុជាទាំងនេះ ក៏មានការចំណាយសរុបលើវិស័យអប់រំខ្ពស់ជាងឆ្ងាយផងដែរ ដូចជា ម៉ាឡេស៊ី (៥៦ ០៣១) និងវៀតណាម[4] (ប្រមាណ ១៣ ៨០០) ជាដើម ដែលចំណុចនេះបានរំលេចឱ្យឃើញទាំងគម្លាតនៃលទ្ធផលសិក្សារបស់សិស្សកម្ពុជាធៀបនឹងបណ្ដាប្រទេសអាស៊ាន និងឱកាសសម្រាប់កម្ពុជាក្នុងការកែលម្អលទ្ធផលសិក្សា តាមរយៈការវិនិយោគកាន់តែច្រើន និងចំគោលដៅ។

## ៣.២. ភាគរយនៃការចំណាយលើវិស័យអប់រំធៀបនឹងផលិតផលក្នុងស្រុកសរុប (GDP)

ការវិភាគលើស្ថានភាពសេដ្ឋកិច្ចរបស់កម្ពុជា ធ្វើឱ្យលទ្ធផល PISA កម្ពុជា កាន់តែមានភាពស្មុគស្មាញ។ កម្ពុជាបានចំណាយលើការអប់រំតិចជាងខ្លាំងធៀបនឹងបណ្ដាប្រទេសជាសមាជិក OECD ជាច្រើន ដោយសារកម្ពុជាមានផលិតផលក្នុងស្រុកសរុប (GDP) មធ្យមភាគក្នុងម្នាក់ៗប្រហែល ២ ៨៧០ ដុល្លារអាមេរិក (ប្រមាណ ៨

---

[3] ការចំណាយសរុបក្នុងសិស្សម្នាក់ៗ ចាប់ពីអាយុ ៦ ឆ្នាំ ដល់ ១៥ ឆ្នាំ (គិតជា USD, PPP)

[4] PISA 2022 Results (Volume I and II) - Country Notes: Viet Nam | OECD

៦៥០ ដុល្លារអាមេរិក តាមអំណាចទិញ (PPP)) និងការចំណាយលើវិស័យអប់រំសាធារណៈមានប្រមាណ ២.១៨% នៃ GDP ប៉ុណ្ណោះ។ បើប្រៀបធៀបជាមួយតំបន់អាស៊ានទាំងមូល ដែលការចំណាយលើវិស័យអប់រំជាទូទៅមានប្រមាណ ២.៨–៣.០% នៃ GDP នោះ កម្រិតនៃការវិនិយោគរបស់កម្ពុជានៅតែមានកម្រិតទាបខ្លាំង។ ដោយឡែក GDP ក្នុងមនុស្សម្នាក់ នៃបណ្ដាប្រទេសជាសមាជិក OECD មានកម្រិតខ្ពស់ គឺចន្លោះពី ៤០ ០០០ ទៅ ៥០ ០០០ ដុល្លារអាមេរិក និងការចំណាយលើវិស័យអប់រំជាមធ្យមភាគប្រមាណជា ៤.៩% នៃ GDP[5]។ ជាមួយនឹងទំហំថវិកានេះធ្វើឱ្យសមត្ថភាពវិនិយោគលើការអប់រំ និងការសិក្សារបស់សិស្សនៅតាមបណ្ដាប្រទេសទាំងនោះមានទំហំធំ។ ប្រការនេះបង្ហាញថាកម្ពុជាសម្រេចបានលទ្ធផលប្រសើរដោយប្រើប្រាស់ធនធានតិច និងមានឱកាសដ៏ល្អក្នុងការបង្កើនលទ្ធផលសិក្សារបស់សិស្សនៅពេលដែលសេដ្ឋកិច្ចកម្ពុជាមានការកើនឡើង។

*រូបទី 19: ការចំណាយលើវិស័យអប់រំ និងលទ្ធផលមុខវិជ្ជាវិទ្យាសាស្ត្រ*




ដូចនេះលទ្ធផលខាងលើបានបង្ហាញជាសារនយោបាយគន្លឹះថា *"កម្ពុជាត្រូវចំណាយមានប្រសិទ្ធភាព និងបង្កើនការវិនិយោគលើវិស័យអប់រំជាលំដាប់"*។ កម្ពុជាគប្បីរក្សាប្រសិទ្ធភាពនៃការចំណាយរបស់ខ្លួន ព្រមទាំង

[5] [Data | OECD]

បង្កើនការវិនិយោគជាបន្តបន្ទាប់ និងផ្តោតលើការប្រើប្រាស់ធនធានបន្ថែមទៅលើអន្តរាគមន៍ដែលមានផលជះខ្ពស់ ដូចជា គុណភាពគ្រូបង្រៀន, ម៉ោងសិក្សា, ការរៀនវិទ្យាសាស្ត្រផ្អែកលើការរិះរកនិងផ្តោតលើការ អនុវត្តជាក់ស្តែង, វង្វាយតម្លៃតាមដំណាក់កាល, សម្ភារសិក្សាដែលមានគុណភាព, ភាពជាអ្នកដឹកនាំសាលារៀនដែលមានប្រសិទ្ធភាព និងការគាំទ្រចំគោលដៅសម្រាប់សិស្សដែលជួបការលំបាក។

នៅពេលដែលសេដ្ឋកិច្ចកម្ពុជាកើនឡើង អ្វីដែលសំខាន់គឺការបង្កើនការវិនិយោគលើវិស័យអប់រំជាយុទ្ធសាស្ត្រឱ្យឈានទៅដល់កម្រិតអាស៊ាន ដើម្បីអាចជួយឱ្យកម្ពុជាមានកំណើនលទ្ធផលសិក្សាកាន់តែឆាប់រហ័ស។ គោលបំណងមិនមែនគ្រាន់តែបង្កើនការចំណាយនោះទេ ប៉ុន្តែការវិនិយោគបន្ថែមត្រូវមានយុទ្ធសាស្ត្រដែលអាចធ្វើឱ្យលទ្ធផលសិក្សាកើនឡើង ជាពិសេសអំណាន ជាមួយនឹងការក្សាបាននូវលទ្ធផលមុខវិជ្ជាគណិតវិទ្យា និងវិទ្យាសាស្ត្រ ដែលកម្ពុជាបានទទួលលទ្ធផលល្អប្រសើររួចហើយ។

# ៤. សាលារៀនដែលមានបរិយាកាសសិក្សាអំណោយផលនៅកម្ពុជា

## ៤.១. លក្ខណៈពិសេសនៃសាលារៀនដែលមានលទ្ធផលខ្ពស់

### ៤.១.១. ស្ថានភាពសិស្ស

សាលារៀនដែលមានលទ្ធផលខ្ពស់ ជាសាលារៀនដែលមានអត្រាសិស្សឡើងថ្នាក់ខ្ពស់។ ក្នុងចំណោមសាលារៀនចំនួន ៣៤ សិស្ស ៨០.២% មិនដែលធ្លាប់រៀនត្រួតថ្នាក់ទេ បើធៀបនឹងមធ្យមភាគទិន្នន័យ PISA របស់កម្ពុជា ៧២% រីឯសិស្សប្រមាណ ១៩.៨% ប៉ុណ្ណោះធ្លាប់ត្រួតថ្នាក់យ៉ាងហោចណាស់ម្តង បើប្រៀបធៀបនឹងមធ្យមភាគទិន្នន័យ PISA របស់កម្ពុជា ២៨%។ ចំណុចនេះបង្ហាញថា សិស្សនៅក្នុងសាលារៀនដែលមានលទ្ធផលខ្ពស់ ជាសិស្សមិនសូវរៀនត្រួតថ្នាក់។

ដូចគ្នានេះដែរ សិស្សនៅក្នុងសាលារៀនដែលមានលទ្ធផលខ្ពស់ ភាគច្រើនជាសិស្សរៀននៅកម្រិតថ្នាក់ស្របតាមអាយុ គឺនៅថ្នាក់ទី១០ ដែលមានរហូតដល់ ៦០.៥% នៃសិស្សសរុប បើធៀបនឹងមធ្យមភាគទិន្នន័យ PISA របស់កម្ពុជា ៤៦.៥%។ ផ្ទុយមកវិញ សាលារៀនដែលមានលទ្ធផលខ្ពស់ មានសិស្សដែលរៀនមិនត្រូវកម្រិតថ្នាក់តិច រួមមាន៖ ថ្នាក់ទី៧ (១.១% បើធៀបនឹង ៣.២% មធ្យមភាគទិន្នន័យ PISA របស់កម្ពុជា), ថ្នាក់ទី៨ (៤.៨% បើធៀបនឹង ៨.៩%), និងថ្នាក់ទី៩ (២១.០% បើធៀបនឹង ២៩.៤%)។

ទិន្នន័យក៏បានបង្ហាញផងដែរថា សិស្ស ៧៣% កំពុងសិក្សាស្របតាមកម្រិតថ្នាក់ ឬលឿនជាងកម្រិតថ្នាក់ដែលបានរំពឹងទុក ដែលចំនួននេះគឺខ្ពស់ជាងមធ្យមភាគទិន្នន័យ PISA របស់កម្ពុជា (៥៨,៥%)។ សិស្សត្រឹមតែ ២១% ប៉ុណ្ណោះដែលរៀនយឺតជាងកម្រិតថ្នាក់ ១ឆ្នាំ និង ៦% រៀនយឺតជាងចាប់ពី ២ឆ្នាំឡើងទៅ។ ទិន្នន័យទាំងនេះបានបង្ហាញថាសិស្សនៅក្នុងសាលារៀនដែលមានលទ្ធផលខ្ពស់ជាសិស្សមិនសូវរៀនត្រួតថ្នាក់។

ការវិភាគស្ថានភាពសិស្សខាងលើនេះ ឆ្លុះបញ្ចាំងពីការកើនឡើង និងការរក្សាសិស្សឱ្យរៀនបន្តទៅមុខរហូតដល់កម្រិតមធ្យមសិក្សាទុតិយភូមិ (វិទ្យាល័យ) នៅតាមសាលារៀនដែលមានលទ្ធផលល្អ។ ចំនួនសិស្សថ្នាក់ទី១០ ច្រើន បូករួម នឹងភាគរយសិស្សដែលរៀនស្របកម្រិតថ្នាក់ខ្ពស់ និងអត្រារៀនត្រួតថ្នាក់ទាបបានបង្ហាញថា សាលារៀនទាំងនេះអាចមានប្រសិទ្ធភាពជាង ក្នុងការជួយគាំទ្រសិស្សឱ្យរៀនបន្តទៅមុខ។

### ៤.១.២. ទីតាំងសាលារៀន និងទំហំសាលារៀន

ទិន្នន័យកម្រិតសាលារៀនបានបង្ហាញថា លទ្ធផលល្អអាស្រ័យតិចតួចលើទីតាំងសាលារៀន ឬទំហំសាលារៀន ប៉ុន្តែវាអាស្រ័យលើប្រសិទ្ធភាពនៃការដឹកនាំសាលារៀន និងរបៀបដែលសាលារៀនរៀបចំការបង្រៀន និងការរៀន។ សាលារៀនដែលមានលទ្ធផលល្អ មាននៅតាមបណ្តារាជធានី ខេត្តផ្សេងៗគ្នា រួមមាន រាជធានីភ្នំពេញ កណ្តាល កំពង់ចាម កំពង់ធំ តាកែវ សៀមរាប ក្រចេះ និងមណ្ឌលគិរី។ ភាពចម្រុះនៃទីតាំង

សាលារៀននេះ រួមទាំងខេត្តនៅជនបទ បានបង្ហាញយ៉ាងច្បាស់ថាលទ្ធផល សិក្សាល្អមិនអាស្រ័យលើទីតាំងសាលារៀននោះទេ។

សាលារៀនដែលមានលទ្ធផលល្អ មានទាំងសាលារៀនតូចនិងធំ ព្រមទាំងស្ថិតនៅក្នុងតំបន់ប្រជុំជន និងជនបទ។ ភាពខុសគ្នាបន្តិចបន្តួចនៃលទ្ធផលសិក្សារវាងសាលារៀននៅប្រជុំជន និងនៅជនបទ បង្ហាញឱ្យឃើញបន្ថែមទៀតថា ទីតាំងសាលារៀន និងចំនួនសិស្ស មិនមែនជាកត្តាកំណត់លើលទ្ធផលនៃការសិក្សានោះឡើយ។

ផ្ទុយទៅវិញ សាលារៀនដែលមានលទ្ធផលល្អ តែងតែមានលក្ខណៈសម្បត្តិរួមដូចគ្នា៖ ការកំណត់អាទិភាពច្បាស់លាស់ ភាពជាអ្នកដឹកនាំផ្ដោតលើការបង្រៀន ការប្រើប្រាស់ម៉ោងរៀនប្រកបដោយប្រសិទ្ធភាព ការតាមដានវឌ្ឍនភាពសិស្សជាប្រចាំ ការផ្ដល់ការគាំទ្រចំគោលដៅដល់សិស្សដែលជួបការលំបាកក្នុងការរៀនសូត្រ កិច្ចសហការរវាងគ្រូបង្រៀន និងការផ្ដល់ឱកាសរៀនសូត្របន្ថែមក្រៅពីការបង្រៀនតាមម៉ោងសិក្សាធម្មតា។ នៅពេលដែលសលារៀនមានដូចខាងលើ ដូចជានៅខេត្តបាត់ដំបង កំពង់ធំ ក្រចេះ និងសូម្បីតែខេត្តមណ្ឌលគិរីដែលនៅដាច់ស្រយាល ក៏អាចទទួលបានលទ្ធផលល្អ ដូចគ្នានឹងសាលារៀននៅតាមទីប្រជុំជនធំៗ ដូចជា រាជធានីភ្នំពេញ និងខេត្តកណ្ដាល ឬសាលារៀនឯកជនមួយចំនួនផងដែរ។

សរុបមក ភ័ស្តុតាងទាំងនេះបានបង្ហាញថា សាលារៀនដែលមានលទ្ធផលល្អ មិនមែនអាស្រ័យលើចំណុចល្អតែមួយមុខនោះទេ ប៉ុន្តែវាអាស្រ័យលើការរួមបញ្ចូលគ្នានៃការអនុវត្តជាក់ស្តែងនានាដែលជួយគាំទ្រពង្រឹងគ្នាទៅវិញទៅមក ដូចជា ភាពជាអ្នកដឹកនាំសាលារៀនដ៏រឹងមាំ និងការបង្រៀននិងការរៀនប្រកបដោយប្រសិទ្ធភាព ដែលជាកត្តាស្នូលក្នុងការប្រែក្លាយធនធានដែលមាន ឱ្យទៅជាលទ្ធផលសិក្សាកាន់តែប្រសើរឡើង។

## ៤.២. បរិយាកាសសិក្សានៅតាមសាលារៀនដែលមានលទ្ធផលល្អ

### ៤.២.១. បទពិសោធន៍របស់នាយកសាលារៀន

លទ្ធផលទទួលបានពីការពិភាក្សាជាក្រុមជាមួយនាយកសាលារៀន បានផ្ដល់នូវព័ត៌មានបន្ថែមយ៉ាងមានតម្លៃ អំពីការអនុវត្តជាក់ស្ដែងដែលបានរួមចំណែកលើកកម្ពស់លទ្ធផលក្នុងកម្មវិធី PISA។ ការពិភាក្សាបានបង្ហាញថា សាលារៀនដែលមានលទ្ធផលល្អ មានការប្ដេជ្ញាចិត្តយ៉ាងមុតមាំរួមគ្នា ចំពោះសមិទ្ធផលសិក្សារបស់សិស្ស ជាពិសេសជោគជ័យក្នុងការប្រឡងសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិ (ថ្នាក់ទី១២) ព្រមទាំងទទួលស្គាល់អំពីសារៈសំខាន់នៃការអភិវឌ្ឍសមត្ថភាពពាក់ព័ន្ធនឹងកម្មវិធី PISA។ ទោះបីជាសាលារៀនសាធារណៈ និងឯកជនមានដំណើរការក្នុងបរិបទកម្រិតធនធានខុសគ្នា និងស្វ័យភាពខុសគ្នាក៏ដោយ នាយកសាលានៃសាលារៀនទាំងពីរប្រភេទបានបង្ហាញអំពីការយកចិត្តទុកដាក់រួមគ្នាលើការអនុវត្តកម្មវិធីសិក្សាប្រកបដោយប្រសិទ្ធភាព ការបង្រៀនមានគុណភាព ការវាយតម្លៃជាប្រចាំ ការគ្រប់គ្រងសាលារៀនហ្មត់ចត់ ម៉ោងសិក្សាគ្រប់គ្រាន់ ការគាំទ្រសិស្ស និងការប្រើប្រាស់ការអប់រំឌីជីថលប្រកបដោយប្រសិទ្ធភាព។

## កម្មវិធីសិក្សា និងម៉ោងបង្រៀន

នាយកសាលារៀនសាធារណៈ បានគូសបញ្ជាក់អំពីសារសំខាន់នៃការអនុវត្តកម្មវិធីសិក្សាជាតិប្រកបដោយប្រសិទ្ធភាព ដោយផ្តោតការយកចិត្តទុកដាក់ខ្លាំងលើមុខវិជ្ជាស្នូល ដូចជា ភាសាខ្មែរ គណិតវិទ្យា រូបវិទ្យា គីមីវិទ្យា ជាដើម។ នាយកសាលាជាច្រើន បានរៀបរាប់អំពីកិច្ចខិតខំប្រឹងប្រែងក្នុងការអនុវត្តការរៀនពេញមួយថ្ងៃ ការបន្ថែមម៉ោងសិក្សា ដើម្បីផ្តល់ពេលបន្ថែមឱ្យសិស្សបានស្ទាត់ជំនាញលើមុខវិជ្ជាទាំងនេះ។ សាលារៀនមួយចំនួនបានរៀបចំការបង្រៀនឱ្យបានប្រមាណ ៣៥ ម៉ោង ក្នុងមួយសប្តាហ៍ ដោយយល់ឃើញថា ការរៀនមួយពេលមិនបានផ្តល់ពេលវេលាគ្រប់គ្រាន់ សម្រាប់ឱ្យសិស្សសម្រេចបាននូវលទ្ធផលសិក្សាដូចការរំពឹងទុកនោះឡើយ។

នាយកសាលារៀន ក៏បានរៀបរាប់អំពីកិច្ចខិតខំប្រឹងប្រែងក្នុងការប្រើប្រាស់ម៉ោងរៀនឱ្យកាន់តែមានប្រសិទ្ធភាព តាមរយៈក្លឹបសិក្សា សកម្មភាពរៀនសូត្របន្ថែម និងការជួយគាំទ្រក្នុងអំឡុងពេលវិស្សមកាលតូច និងវិស្សមកាលធំ។ សាលារៀនមួយចំនួន បានផ្តល់ការរៀនបន្ថែមដល់សិស្សដែលជួបការលំបាកក្នុងការសិក្សា និងបានរៀបចំការប្រឡងឡើងថ្នាក់ ដើម្បីកំណត់ថាតើពួកគេមានសមត្ថភាពគ្រប់គ្រាន់ក្នុងការឡើងទៅកម្រិតថ្នាក់បន្ទាប់ដែរឬទេ។

ចំណុចសំខាន់មួយទៀតដែលនាយកសាលារៀនបានលើកឡើងគឺ ការត្រៀមលក្ខណៈសម្រាប់ PISA ដោយផ្សារភ្ជាប់ទៅនឹងការបង្រៀននៅក្នុងថ្នាក់រៀន។ ពួកគាត់បានកត់សម្គាល់ថា សំណួរតេស្ត PISA មិនមែនសុទ្ធតែលំបាកនោះទេ ប៉ុន្តែគ្រូបង្រៀន និងសិស្សកម្ពុជាភាគច្រើនមិនស៊ាំនឹងប្រភេទសំណួរតេស្តដែលតម្រូវឱ្យសិស្សអនុវត្តចំណេះដឹង បកស្រាយព័ត៌មាន ការផ្តល់ហេតុផល និងដោះស្រាយបញ្ហាក្នុងស្ថានភាពប្លែកៗដែលពួកគេមិនធ្លាប់ជួបប្រទះ។

នាយកសាលារៀនឯកជន បានរៀបរាប់អំពីភាពបត់បែនខ្លាំង ក្នុងការរៀបចំកម្មវិធីសិក្សា និងម៉ោងបង្រៀន។ សាលារៀនមួយចំនួន បានអនុវត្តការរៀនពេញមួយថ្ងៃ ដោយប្រើប្រាស់ទាំងកម្មវិធីសិក្សាជាតិ និងកម្មវិធីសិក្សាអន្តរជាតិ ដែលអនុញ្ញាតឱ្យសិស្សបានរៀនមុខវិជ្ជាលើសពីមួយដង ជាឧទាហរណ៍ មុខវិជ្ជាវិទ្យាសាស្ត្រទាំងជាភាសាខ្មែរ និងភាសាអង់គ្លេស។ ការធ្វើបែបនេះ ផ្តល់នូវផលជះបន្ថែមលើខ្លឹមសារមុខវិជ្ជា បញ្ញត្តិបច្ចេកទេស និងធនធានសិក្សា។ នាយកសាលារៀនក៏បានរៀបរាប់អំពីកិច្ចខិតខំប្រឹងប្រែង ក្នុងការផ្សារភ្ជាប់ការរៀនសូត្រទៅនឹងបញ្ហាសកល និងបរិបទជីវិតជាក់ស្តែង ដែលជួយឱ្យសិស្សយល់ដឹងពីរបៀបយកចំណេះដឹងទៅអនុវត្តក្រៅពីថ្នាក់រៀនផងដែរ។

សាលារៀនឯកជន ក៏បានផ្តល់ការយកចិត្តទុកដាក់យ៉ាងខ្លាំង លើបំណិនអានផងដែរ។ ជំនួសឱ្យការផ្តោតតែលើរឿងព្រេង និងរឿងនិទាន សាលារៀនបានបង្រៀនយ៉ាងច្បាស់លាស់នូវបំណិនផ្សេងៗ ដូចជា ការអានរំលង (Skimming), ការអានស្វែងរកចំណុចសំខាន់ (Scanning), ការអានយល់ន័យ (Comprehension), ការស្រង់ព័ត៌មាន និងការបកស្រាយអត្ថបទចម្រុះប្រភេទ។ សាលារៀនមួយចំនួន បាន

រៀបចំក្លឹបសិក្សារហូតដល់ទៅ ២០ ក្លឹបផ្សេងៗគ្នា ដែលផ្តល់ឱកាសឱ្យសិស្សអាចស្វែងរកការរៀនសូត្របន្ថែម និងអភិវឌ្ឍចំណង់ចំណូលចិត្តរបស់ពួកគេ ក្រៅពីការបង្រៀនតាមម៉ោងសិក្សាធម្មតា។

សាលារៀនឯកជន ក៏បានលើកឡើងផងដែរអំពីការប្រើប្រាស់គម្រោងលម្អិតវិញ្ញាសាប្រឡង (Test Blueprints) និងការបន្សុីសម្ភារសិក្សាឱ្យស្របគ្នាទៅនឹងសៀវភៅសិក្សាគោលនិងស្តង់ដាកម្មវិធីសិក្សា។ នាយកសាលារៀនទាំងអស់បានពន្យល់ថា ដោយសារតែក្របខណ្ឌកម្មវិធីសិក្សាជាតិមានលក្ខណៈទូលំទូលាយ សាលារៀនចាំបាច់ត្រូវបំប្លែងក្របខណ្ឌកម្មវិធីសិក្សានោះ ឱ្យទៅជាវត្ថុបំណងនៃមេរៀន សម្ភារឧបទេស និងការវាយតម្លៃ ដែលកាន់តែច្បាស់លាស់។

## ការបង្រៀន និងការអភិវឌ្ឍវិជ្ជាជីវៈគ្រូបង្រៀន

ការពិភាក្សាជាក្រុមបានបង្ហាញថា សាលារៀនដែលមានលទ្ធផលល្អ ផ្តល់ការយកចិត្តទុកដាក់យ៉ាងខ្លាំងលើកិច្ចសហការរវាងគ្រូបង្រៀននិងគ្រូបង្រៀន និងការអភិវឌ្ឍវិជ្ជាជីវៈ។ នៅក្នុងសាលារៀនសាធារណៈ នាយកសាលារៀនបានរៀបរាប់អំពីការបង្កើតក្រុមបច្ចេកទេស ដែលរៀបចំឡើងតាមជំនាញឯកទេសរបស់គ្រូបង្រៀន។ ក្រុមទាំងនេះ ផ្តល់នូវរចនាសម្ព័ន្ធសម្រាប់ឱ្យគ្រូបង្រៀនជួយគាំទ្រគ្នាទៅវិញទៅមក ពិភាក្សាអំពីបញ្ហាប្រឈមក្នុងការបង្រៀន ចែករំលែកបទពិសោធល្អៗ និងកែលម្អការបង្រៀននៅក្នុងថ្នាក់។ នៅក្នុងសាលារៀនមួយចំនួនក្រុមបច្ចេកទេសជួបប្រជុំគ្នាមួយខែម្តង ដើម្បីចែករំលែកបទពិសោធ និងពិភាក្សាអំពីការរៀនសូត្ររបស់សិស្ស។ នាយកសាលារៀនក៏បានរៀបរាប់អំពីក្លឹបសិក្សាដែលដឹកនាំដោយគ្រូបង្រៀន និងសិស្សរៀនកម្រិតថ្នាក់ខ្ពស់ ដោយជួនកាលមានការចូលរួមដោយស្ម័គ្រចិត្តពីសំណាក់សិស្សរៀនកម្រិតថ្នាក់ខ្ពស់ជាង ដើម្បីជួយគាំទ្រដល់សិស្សរៀនកម្រិតថ្នាក់ទាប។ សកម្មភាពទាំងនេះ ផ្តល់ឱកាសបន្ថែមសម្រាប់ឱ្យសិស្សបានហ្វឹកហាត់ និងទទួលបានការជួយជ្រោមជ្រែង ក្រៅពីម៉ោងសិក្សាធម្មតា។

ការគាំទ្រដល់គ្រូបង្រៀន ក៏ត្រូវបានផ្តល់ជូនតាមរយៈការអភិវឌ្ឍវិជ្ជាជីវៈ និងការរៀនសូត្រពីគ្រូបង្រៀនផ្សេងទៀតផងដែរ។ ជំនួសឱ្យការផ្អែកទាំងស្រុងលើការហ្វឹកហាត់ពីខាងក្រៅ សាលារៀនដែលមានលទ្ធផលល្អ បានប្រើប្រាស់ការអភិវឌ្ឍវិជ្ជាជីវៈនៅតាមសាលារៀន ដោយរួមមាន ការប្រជុំបច្ចេកទេស, ការជួយគាំទ្រពីគ្រូបង្រៀនផ្សេងទៀត, ការសិក្សាស្រាវជ្រាវមេរៀន (Lesson Study) និងសហគមន៍សិក្សាវិជ្ជាជីវៈ (PLCs)។

នៅក្នុងសាលារៀនឯកជន នាយកសាលារៀនបានរៀបរាប់អំពីប្រព័ន្ធអភិវឌ្ឍគ្រូបង្រៀនដែលមានរចនាសម្ព័ន្ធច្បាស់លាស់ជាង។ ប្រព័ន្ធនេះ រួមមាន ការតម្រង់ទិសគ្រូបង្រៀន, ការរៀបចំកិច្ចការបង្រៀន, ការអភិវឌ្ឍវិជ្ជាជីវៈ, ការសង្កេតការបង្រៀនពីគ្រូបង្រៀនផ្សេងទៀត, ការសិក្សាស្រាវជ្រាវមេរៀន, ការវាយតម្លៃគ្រូបង្រៀន, និងសហគមន៍សិក្សាវិជ្ជាជីវៈ (PLCs)។ យន្តការទាំងនេះ អនុញ្ញាតឱ្យថ្នាក់ដឹកនាំសាលារៀនអាចតាមដានគុណភាពនៃការបង្រៀន និងផ្តល់ព័ត៌មានត្រឡប់ (Feedback) ទៅកាន់គ្រូបង្រៀនជាប្រចាំ។

សាលារៀនឯកជនមួយចំនួនក៏បានរៀបចំការគាំទ្រការរៀនសូត្រផ្នែកបញ្ញាសប្បនិម្មិត (AI) ចំនួន ៣ ទៅ ៤ ដង ក្នុងមួយឆ្នាំ ដោយជួយគ្រូបង្រៀនឱ្យស្វែងយល់ពីរបៀបដែលបច្ចេកវិទ្យាថ្មីៗអាចគាំទ្រដល់ការរៀបចំ

កិច្ចតែងការបង្រៀន ការបង្រៀន និងការរៀនសូត្ររបស់សិស្ស។ ការពិភាក្សាជាក្រុមបានបង្ហាញថាការអភិវឌ្ឍវិជ្ជាជីវៈមានប្រសិទ្ធភាពបំផុត នៅពេលដែលវាត្រូវបានភ្ជាប់ដោយផ្ទាល់ទៅនឹងការបង្រៀនជាក់ស្តែងក្នុងថ្នាក់រៀនរបស់គ្រូបង្រៀន និងតម្រូវការរៀនសូត្ររបស់សិស្ស។

## ការវាយតម្លៃ និងការគាំទ្រដល់សិស្សដែលជួបការលំបាកក្នុងការរៀនសូត្រ

រង្វាយតម្លៃត្រូវបានអនុវត្តនៅសាលារៀនដែលមានលទ្ធផលល្អ ដោយមិនត្រឹមតែដើម្បីវាស់វែងលទ្ធផលសិក្សាប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងដើម្បីកំណត់រកចំណុចខ្វះខាតក្នុងការរៀនសូត្រ និងផ្តល់ការជួយជ្រោមជ្រែងឱ្យចំគោលដៅផងដែរ។

នៅក្នុងសាលារៀនសាធារណៈ នាយកសាលារៀនបានរៀបរាប់អំពីកិច្ចខិតខំប្រឹងប្រែងក្នុងការជួយគាំទ្រដល់សិស្សរៀនយឺត។ សាលារៀនមួយចំនួនបានរៀបចំការបង្រៀនបន្ថែមក្នុងអំឡុងពេលវិស្សមកាលតូច និងវិស្សមកាលធំ ហើយបន្ទាប់មកធ្វើការវាយតម្លៃសិស្សដើម្បីកំណត់ថាតើពួកគេទទួលបានសមត្ថភាពចាំបាច់ក្នុងការឡើងទៅកម្រិតថ្នាក់បន្ទាប់ហើយឬនៅ។ នេះឆ្លុះបញ្ចាំងពីកិច្ចខិតខំប្រឹងប្រែង ដើម្បីធានាថាសិស្សមិនគ្រាន់តែឡើងថ្នាក់ ដោយមិនទាន់ចេះស្ទាត់ជំនាញលើចំណេះដឹង និងជំនាញសំខាន់ៗនោះឡើយ។

សាលារៀនក៏បានផ្តល់ឱកាសបន្ថែមដល់សិស្ស ក្នុងការហ្វឹកហាត់ធ្វើសំណួរតេស្តគំរូតាមលំនាំ PISA ផងដែរ។ នាយកសាលារៀនបានគូសបញ្ជាក់ថា សិស្សចាំបាច់ត្រូវស៊ាំនឹងទម្រង់សំណួរតេស្ត និងកម្រិតចំណេះដឹងនៃលំហាត់ទាំងនោះ។ ការហ្វឹកហាត់បន្ថែម ជួយឱ្យសិស្សកាន់តែមានភាពស៊ាំក្នុងការបកស្រាយព័ត៌មាន ការអនុវត្តគោលគំនិត ការប្រើប្រាស់ហេតុផល និងការដោះស្រាយបញ្ហា ជំនួសឱ្យការត្រឹមតែចងចាំទិន្នន័យ ឬហេតុការណ៍តែមួយមុខ។

នៅក្នុងសាលារៀនឯកជន ការវាយតម្លៃមាននិន្នាការរៀបចំឡើងយ៉ាងមានរចនាសម្ព័ន្ធ និងមានស្តង់ដាច្បាស់លាស់ជាង។ នាយកសាលាទាំងអស់បានរៀបរាប់អំពីការប្រើប្រាស់គម្រោងលម្អិតវិញ្ញាសាប្រឡង (Test blueprints) ការធ្វើតេស្តស្តង់ដា ការប្រឡងទៀងទាត់ និងការតាមដានសិស្ស។ ឧបករណ៍ទាំងនេះអនុញ្ញាតឱ្យសាលារៀនអាចស្វែងរកចំណុចខ្វះខាត ឬចំណុចខ្សោយតាមកម្រិតសិស្ស កម្រិតមុខវិជ្ជា និងកម្រិតសាលារៀនទាំងមូល។

សាលារៀនឯកជនមួយចំនួន បានបង្កើតប្រព័ន្ធធានាគុណភាពផ្ទៃក្នុង ដែលផ្តោតជាពិសេសលើលទ្ធផលសិក្សារបស់សិស្ស។ លទ្ធផលនៃការវាយតម្លៃ ត្រូវបានយកមកពិនិត្យឡើងវិញ ដើម្បីកំណត់ថាតើការបង្រៀនកំពុងបង្កើតឱ្យមានការកែលម្អដូចការរំពឹងទុកដែរឬទេ និងដើម្បីដឹងថាតើត្រូវទាមទារឱ្យមានអន្តរាគមន៍បន្ថែមនៅត្រង់ចំណុចណាខ្លះ។

## ការដឹកនាំ និងការគ្រប់គ្រងសាលារៀន

សាលារៀនដែលមានលទ្ធផលល្អបានបង្ហាញពីចំណុចសំខាន់ៗ រួមមាន ការដឹកនាំសាលារៀនប្រកបដោយភាពហ្មត់ចត់ និងសកម្មភាពច្បាស់លាស់។

នាយកសាលារៀនសាធារណៈបានគូសបញ្ជាក់ពីសារៈសំខាន់នៃការធ្វើឱ្យចក្ខុវិស័យសាលារៀនមានភាពច្បាស់លាស់ដល់គ្រូបង្រៀន សិស្ស និងមាតាបិតា។ តួនាទីរបស់នាយកសាលារៀន មិនមែនត្រឹមតែជាការងាររដ្ឋបាលនោះទេ ប៉ុន្តែនាយកសាលារៀនចូលរួមយ៉ាងសកម្មក្នុងការងារអាទិភាពនានា ការរៀបចំគ្រូបង្រៀនឱ្យមានគោលដៅរួម ការតាមដានការអនុវត្ត និងការប្រមូលព័ត៌មានតាមដានលើលទ្ធផលសិក្សារបស់សិស្ស។

នាយកសាលារៀនក៏បានគូសបញ្ជាក់ផងដែរអំពីការយកចិត្តទុកដាក់ខ្ពស់លើការណែនាំរបស់ក្រសួងអប់រំ យុវជន និងកីឡា និងការចូលរួមយ៉ាងសកម្មនៅក្នុងសិក្ខាសាលា និងសកម្មភាពពាក់ព័ន្ធនឹង PISA របស់ក្រសួង។ ការចូលរួមក្នុងសកម្មភាពទាំងនេះអនុញ្ញាតឱ្យនាយកសាលារៀន និងគ្រូបង្រៀនយល់ដឹងពីអាទិភាពកម្រិតជាតិ ព្រមទាំងនាំយកវិធីសាស្ត្រថ្មីៗទៅអនុវត្តនៅក្នុងសាលារៀន។

សាលារៀនសាធារណៈដែលមានលទ្ធផលល្អ ក៏ប្រើប្រាស់ផែនការសាលារៀនច្បាស់លាស់ និងប្រព័ន្ធតាមដាន និងវាយតម្លៃផងដែរ។ នាយកសាលារៀនបានរៀបរាប់អំពីការកំណត់អាទិភាព ការតាមដានការអនុវត្ត និងការពិនិត្យមើលឡើងវិញនូវវឌ្ឍនភាព ជំនួសឱ្យការទុកផែនការសាលារៀនត្រឹមជាឯកសាររដ្ឋបាល។

វត្តមានរបស់សិស្ស និងវិន័យ ត្រូវបានលើកឡើងជាញឹកញាប់ថាជាលក្ខខណ្ឌចាំបាច់សម្រាប់ការសិក្សា។ នាយកសាលារៀនបានរៀបរាប់អំពីការតាមដានវត្តមានយ៉ាងម៉ឺងម៉ាត់ និងការប្រមូលព័ត៌មានពីមាតាបិតា នៅពេលដែលសិស្សអវត្តមាន ឬមកយឺតញឹកញាប់។ នៅតាមសាលារៀនមួយចំនួន ប្រសិនបើសិស្សមកដល់ក្រោយម៉ោង ៧:០០ ព្រឹក ដែលជាម៉ោងចូលរៀន នោះមាតាបិតាត្រូវបានអញ្ជើញមកសាលារៀនដើម្បីពិភាក្សាលើបញ្ហានេះ។ ការអនុវត្តបែបនេះបង្ហាញពីសារសំខាន់ដែលត្រូវបានផ្តល់ឱ្យលើការបង្កើតវប្បធម៌ទៀងពេល ការទទួលខុសត្រូវ និងការចូលរួមក្នុងការរៀនសូត្រជាប្រចាំ។

សាលារៀនសាធារណៈមួយចំនួន ក៏បានប្រើប្រាស់ធនធានសហគមន៍ ដើម្បីទទួលស្គាល់ និងលើកទឹកចិត្តដល់គ្រូបង្រៀនថ្មីមផងដែរ ដែលនេះបង្ហាញពីរបៀបដែលនាយកសាលារៀន និងសហគមន៍អាចធ្វើការរួមគ្នា ដើម្បីលើកទឹកចិត្តគ្រូបង្រៀន ទោះបីជាធនធានរបស់សាលារៀនមានកម្រិតក៏ដោយ។

នៅក្នុងសាលារៀនឯកជន នាយកសាលារៀនបានរៀបរាប់អំពីប្រព័ន្ធគ្រប់គ្រងដែលមានលក្ខណៈផ្លូវការជាង ដោយមានការគាំទ្រពីស្វ័យភាពស្ថាប័នខ្លាំងជាង។ ប្រព័ន្ធទាំងនេះ រួមមាន ការវាយតម្លៃគ្រូបង្រៀន, ការតាមដានសមិទ្ធកម្ម, ការវាយតម្លៃស្តង់ដា, ប្រព័ន្ធគ្រប់គ្រងសិស្ស, ប្រព័ន្ធគ្រប់គ្រងការរៀនសូត្រ (LMS), ការធានាគុណភាពផ្ទៃក្នុង, និងការលើកទឹកចិត្តគ្រូបង្រៀនល្អ។ ការប្រកួតប្រជែងដើម្បីទាក់ទាញសិស្ស និងគ្រូបង្រៀន ក៏បានបង្កើតជាការលើកទឹកចិត្តសម្រាប់សាលារៀន ក្នុងការរក្សាគុណភាពបង្រៀនឱ្យបានរឹងមាំ និងបង្ហាញពីលទ្ធផលនៃការសិក្សាផងដែរ។

## ការអប់រំឌីជីថល

ការអប់រំឌីជីថល កំពុងតែក្លាយជាផ្នែកមួយដ៏មានសារៈសំខាន់កាន់តែខ្លាំង នៅក្នុងការអនុវត្តផ្ទាល់របស់សាលារៀនដែលមានលទ្ធផលល្អ។

នៅក្នុងសាលារៀនសាធារណៈ នាយកសាលារៀនបានរៀបរាប់អំពីការកើនឡើងនៃការប្រើប្រាស់ថ្នាលសិក្សាឌីជីថល និងសម្ភារសិក្សា រួមទាំងប្រភពធនធានដែលគាំទ្រដោយក្រសួងអប់រំ យុវជន និងកីឡាផងដែរ។ ឧបករណ៍ឌីជីថលផ្តល់ឱកាសបន្ថែមដល់សិស្សក្នុងការហ្វឹកហាត់ និងចូលប្រើប្រាស់សម្ភារសិក្សា ក្រៅពីថ្នាក់រៀនធម្មតា។ ឧបករណ៍ទាំងនោះក៏អាចជួយគ្រូបង្រៀនក្នុងការផ្តល់ការគាំទ្របន្ថែមដល់សិស្ស ដែលត្រូវការការហ្វឹកហាត់បន្ថែមទៀតផងដែរ។

នៅក្នុងសាលារៀនឯកជន ការអប់រំឌីជីថលជាទូទៅត្រូវបានអនុវត្តយ៉ាងទូលំទូលាយ និងបានបញ្ចូលទៅក្នុងប្រព័ន្ធគ្រប់គ្រងសាលារៀន និងការបង្រៀន។ សាលារៀនមួយចំនួន ប្រើប្រាស់ប្រព័ន្ធគ្រប់គ្រងការសិក្សា (LMS) ដើម្បីតាមដានវឌ្ឍនភាពរបស់សិស្ស និងផ្តល់ព័ត៌មានអំពីការរៀនសូត្ររបស់សិស្សទៅកាន់គ្រូបង្រៀន និងមាតាបិតា។

សិស្សអាចទទួលបានការសិក្សាថ្នាក់កុំព្យូទ័រពី ២ ទៅ ៤ ម៉ោង ក្នុងមួយសប្តាហ៍ រួមទាំងការសរសេរកូដ (Coding) ផងដែរ។ សាលារៀនក៏បានផ្តល់ឱកាសសម្រាប់សិស្ស ក្នុងការស្វែងយល់ពីប្រភពធនធានរៀនសូត្រឌីជីថល និងសម្ភារសិក្សាដែលពាក់ព័ន្ធនឹងកម្មវិធី PISA។ សាលារៀនមួយចំនួនបានចាប់ផ្តើមផ្តល់ឱកាសដល់គ្រូបង្រៀន និងសិស្សក្នុងស្វែងយល់ពីការរៀនសូត្រដែលគាំទ្រដោយបញ្ញាសិប្បនិម្មិត (AI) ចំនួន ៣ ទៅ ៤ ដង ក្នុងមួយឆ្នាំ។

## ការធានាគុណភាព និងការកែលម្អជាប្រចាំ

ការពិភាក្សាជាក្រុមបានបង្ហាញថា សាលារៀនដែលមានលទ្ធផលល្អ បានបង្កើតនូវវប្បធម៌កែលម្អជាប្រចាំ និងគណនេយ្យភាពចំពោះលទ្ធផលការសិក្សារបស់សិស្ស។

នៅក្នុងសាលារៀនសាធារណៈ វប្បធម៌នេះត្រូវបានកសាងឡើងតាមរយៈផែនការសាលារៀន, ប្រព័ន្ធតាមដាននិងវាយតម្លៃ, ក្រុមបច្ចេកទេស, សហគមន៍សិក្សាវិជ្ជាជីវៈ, ការប្រជុំបច្ចេកទេសប្រចាំខែ, កិច្ចសហការរវាងគ្រូបង្រៀន និងការយកចិត្តទុកដាក់និងអនុវត្តតាមយ៉ាងហ្មត់ចត់ចំពោះការណែនាំរបស់ក្រសួងអប់រំ យុវជន និងកីឡា។ នាយកសាលារៀនប្រើប្រាស់រចនាសម្ព័ន្ធទាំងនេះ ដើម្បីកំណត់រកបញ្ហាប្រឈម និងលើកទឹកចិត្តគ្រូបង្រៀនឱ្យធ្វើការរួមគ្នា ដើម្បីដោះស្រាយបញ្ហា។

នៅក្នុងសាលារៀនឯកជន ការធានាគុណភាពផ្ទៃក្នុងជាទូទៅមានលក្ខណៈផ្លូវការ។ សាលារៀនប្រើប្រាស់ការវាយតម្លៃស្តង់ដា, ការវាយតម្លៃគ្រូបង្រៀន, ការតាមដានវឌ្ឍនភាពសិស្ស, ទិន្នន័យប្រព័ន្ធគ្រប់គ្រងការសិក្សា, និងដំណើរការធានាគុណភាពផ្ទៃក្នុង, ដើម្បីពិនិត្យមើលថាតើការបង្រៀន និងការរៀនកំពុងបង្កើតឱ្យ

មានលទ្ធផលដែលអាចវាស់វែងបានដែរឬទេ។ សាលារៀនមានការទទួលស្គាល់ និងលើកសរសើរដល់គ្រូល្អ និងសិស្សឆ្នើម ដែលជាផ្នែកមួយនៃកិច្ចខិតខំប្រឹងប្រែងរបស់ពួកគេក្នុងការកសាងវប្បធម៌វិជ្ជមាននៃលទ្ធផលសិក្សា។

បទពិសោធន៍ដែលបានចែករំលែកដោយនាយកសាលារៀន បានបង្ហាញថាលទ្ធផលខ្ពស់កើតចេញពីការរួមបញ្ចូលគ្នានៃការអនុវត្តជាក់ស្តែងដែលជួយពង្រឹងគ្នាទៅវិញទៅមក ជំនួសឱ្យការធ្វើអន្តរាគមន៍តែមួយមុខ។ សាលារៀនសាធារណៈបានបង្ហាញឱ្យឃើញពីរបៀបដែលការដឹកនាំប្រកបដោយភាពរឹងមាំ, កិច្ចសហការរបស់គ្រូបង្រៀន, ការចូលរួមជាមួយក្រសួងអប់រំ យុវជន និងកីឡា, ការគាំទ្រពីសហគមន៍, វិន័យសិស្ស, និងការគាំទ្រចំគោលដៅសម្រាប់សិស្សដែលជួបការលំបាកក្នុងការរៀនសូត្រ អាចបង្កើតឱ្យមានការកែលម្អ ទោះបីជាស្ថិតក្នុងលក្ខខណ្ឌដែលធនធានមានកម្រិតក៏ដោយ។ សាលារៀនឯកជនបានបង្ហាញពីអត្ថប្រយោជន៍ដ៏មានសក្តានុពលដែលបត់បែនបានច្រើនជាងមុន, ម៉ោងសិក្សាច្រើន, ការវាយតម្លៃដែលមានរចនាសម្ព័ន្ធច្បាស់លាស់, ការអភិវឌ្ឍគ្រូបង្រៀនយ៉ាងសកម្ម, វិធីសាស្ត្រអានដ៏ទូលំទូលាយ, ប្រព័ន្ធរៀនសូត្រឌីជីថល, និងការធានាគុណភាពផ្ទៃក្នុង។

អ្វីដែលសំខាន់នោះគឺនាយកសាលារៀនមិនបានរៀបរាប់ពីការអនុវត្តទាំងនេះត្រឹមជាកម្មវិធីសិក្សានោះទេ ប៉ុន្តែពួកគាត់បានរៀបរាប់ពីការអនុវត្តទាំងនេះថាជាផ្នែកមួយនៃវប្បធម៌ និងទម្លាប់ប្រចាំថ្ងៃនៃសាលារៀនរបស់ពួកគាត់។ ចំណុចរួមដែលទទួលបានពីការពិភាក្សាជាក្រុមគឺថាសាលារៀនមានការកើនឡើងនូវគុណភាពនៅពេលដែលនាយកសាលារៀននិងគ្រូបង្រៀនមានការផ្តោតអារម្មណ៍យ៉ាងច្បាស់លាស់លើការរៀនសូត្ររបស់សិស្ស ធ្វើការរួមគ្នាជុំវិញតម្រូវការរបស់សិស្ស ប្រើប្រាស់ភស្តុតាងដើម្បីស្វែងរកបញ្ហា និងកែសម្រួលការអនុវត្តរបស់ពួកគេជាប្រចាំ។ សម្រាប់កម្ពុជា បញ្ហាប្រឈមផ្នែកគោលនយោបាយដ៏សំខាន់ គឺការកំណត់ការអនុវត្តសមស្របណាមួយដែលអាចគាំទ្រនិងពង្រីកវិសាលភាពនៅតាមសាលារៀនសាធារណៈបាន ដោយទទួលស្គាល់ថាការអនុវត្តជាក់ស្តែងនឹងត្រូវឆ្លុះបញ្ចាំងពីភាពខុសគ្នានៃស្ថានភាពសាលារៀន ធនធាន សមត្ថភាពដឹកនាំ និងការគាំទ្រពីសហគមន៍។

## ៤.២.២.បទពិសោធន៍របស់គ្រូបង្រៀនវិទ្យាសាស្ត្រ

ផ្អែកលើការពិភាក្សាជាក្រុម ការកើនឡើងនូវលទ្ធផលតេស្ត PISA ឆ្នាំ២០២៥ របស់កម្ពុជាមានការពាក់ព័ន្ធទៅនឹងការផ្លាស់ប្តូរវិធីសាស្ត្របង្រៀនពីការបង្រៀនបែបទន្ទេញចាំមាត់ ទៅរកការបង្រៀនបែបសកម្មការអនុវត្តជាក់ស្តែង និងអនុវត្តគោលវិធីសិស្សមជ្ឈមណ្ឌល។ គ្រូបង្រៀនមុខវិជ្ជាវិទ្យាសាស្ត្រនៅតាមសាលារៀនដែលមានលទ្ធផលល្អទាំង៦ បានបង្ហាញថាពួកគាត់បានជួយពង្រឹងគ្នាទៅវិញទៅមកលើការបង្រៀន។

### វត្ថុបំណងសិក្សាច្បាស់លាស់ និងគោលវិធីសិស្សមជ្ឈមណ្ឌល

គ្រូបង្រៀនបានឡើងអំពីការកំណត់វត្ថុបំណងសិក្សាច្បាស់លាស់ ការកែសម្រួលវិធីសាស្ត្របង្រៀនឱ្យស្របទៅតាមកម្រិតសមត្ថភាពរបស់សិស្ស និងការរៀបចំការរៀនសូត្រជាជំហានៗដោយចេញពីងាយទៅស្មុគស្មាញ។ ពួកគាត់បានភ្ជាប់ចំណេះដឹងវិទ្យាសាស្ត្រទៅនឹងការអនុវត្តជាក់ស្តែង និងជីវភាពរស់នៅប្រចាំថ្ងៃកាន់តែខ្លាំងឡើង ដោយប្រើប្រាស់វិធីសាស្ត្រនានាដូចជា ការរៀនតាមបែបរិះរក (Inquiry-based learning),

វិធីសាស្ត្របង្រៀនតាមគំរូ 5E (5E model), ការរៀនផ្តោតលើការដោះស្រាយបញ្ហា (Problem-based learning), ការពិសោធ, ល្បែងសិក្សា, ការងារជាក្រុម, និងសកម្មភាពអន្តរកម្មផ្សេងៗទៀត។

### ការរៀនសូត្របែបសកម្ម និងការគិតកម្រិតខ្ពស់

ការផ្លាស់ប្តូរដ៏មានសារៈសំខាន់មួយ គឺការឆ្ពោះទៅរកការរៀនសូត្របែបសកម្ម និងការគិតស៊ីជម្រៅ។ គ្រូបង្រៀនបានលើកទឹកចិត្តសិស្សឱ្យពន្យល់ពីហេតុផលរបស់ពួកគេ, បកស្រាយព័ត៌មាន, ដោះស្រាយបញ្ហា, និងអនុវត្តបញ្ញត្តិវិទ្យាសាស្ត្រទៅក្នុងស្ថានភាពជីវិតជាក់ស្តែង ជាជាងការផ្តោតជាសំខាន់លើការរំឭកចំណេះដឹងឡើងវិញ។ វិធីសាស្ត្រទាំងនេះគឺស្របគ្នាទៅនឹងសមត្ថភាពដែលត្រូវវាយតម្លៃនៅក្នុងកម្មវិធី PISA ហើយអាចជួយឱ្យសិស្សឆ្លើយសំណួរតេស្តប្លែកៗ និងសំណួរតេស្តផ្តោតលើបរិបទជាក់ស្តែង បានប្រសើរជាងមុន។

### ការវាយតម្លៃជាប្រចាំ និងការផ្តល់ព័ត៌មានត្រឡប់

វង្វាយតម្លៃតាមដំណាក់កាល (Formative assessment) បានក្លាយជាផ្នែកមួយដ៏មានសារសំខាន់នៃការបង្រៀនផងដែរ។ គ្រូបង្រៀនបានប្រើប្រាស់សំណួរផ្ទាល់មាត់, តេស្តខ្លីៗ, ការធ្វើបទបង្ហាញ, កិច្ចការផ្ទះ និងសន្លឹកកិច្ចការ ដើម្បីតាមដានវឌ្ឍនភាពរបស់សិស្ស និងកែលម្អការបង្រៀន។ លទ្ធផលនៃការវាយតម្លៃបានជួយគ្រូបង្រៀនក្នុងការកំណត់រកគម្លាតនៃការរៀនសូត្រ, កែសម្រួលបញ្ញត្តិពិបាកៗ, ការផ្តល់ព័ត៌មានត្រឡប់ភ្លាមៗ, និងការផ្តល់ការគាំទ្របន្ថែមដល់សិស្សរៀនយឺត។

### ការគាំទ្រសិស្សតាមបែបខុសៗគ្នា

គ្រូបង្រៀនបានគូសបញ្ជាក់ពីសារៈសំខាន់នៃការឆ្លើយតបទៅនឹងតម្រូវការរៀនសូត្រខុសៗគ្នា។ សិស្សដែលជួបប្រទះការលំបាកទទួលបាននូវការពន្យល់បន្ថែម សម្ភារសិក្សា ព្រមទាំងការគាំទ្របន្ថែមជាលក្ខណៈបុគ្គល ឬក្រុមតូចៗ។ វិធីសាស្ត្រនេះអាចជួយកាត់បន្ថយគម្លាតនៃការរៀនសូត្រ និងធានាថាសិស្សរៀនយឺតមិនត្រូវបានបោះបង់ចោលឡើយ។

### បរិយាកាសរៀនសូត្រប្រកបដោយការគាំទ្រ និងការចូលរួម

គ្រូបង្រៀនបានគូសបញ្ជាក់ផងដែរអំពីសារសំខាន់នៃការបង្កើតថ្នាក់រៀនដែលធ្វើឱ្យសិស្សមានអារម្មណ៍ល្អក្នុងការសួរសំណួរ, ការបញ្ចេញមតិយោបល់, និងការកែលម្អកំហុស។ ការងារក្រុម និងការចូលរួមយ៉ាងសកម្មត្រូវបានលើកទឹកចិត្ត ខណៈពេលដែលកំហុសឆ្គងទាំងឡាយត្រូវបានចាត់ទុកជាផ្នែកមួយនៃដំណើរការរៀនសូត្រ។ បរិយាកាសបែបនេះអាចជួយកសាងទំនុកចិត្តរបស់សិស្សក្នុងការគិតពិចារណាស្វែងរកហេតុផល, ការធ្វើពិសោធ និងការដោះស្រាយបញ្ហា។

### ការបង្រៀនឆ្លើយតបនឹងកម្មវិធី PISA

ការអភិវឌ្ឍវិជ្ជាជីវៈពាក់ព័ន្ធនឹងកម្មវិធី PISA ជះឥទ្ធិពលលើការអនុវត្តក្នុងថ្នាក់រៀនផងដែរ។ គ្រូបង្រៀនបានលើកឡើងអំពីការយល់ដឹងកាន់តែច្បាស់អំពីក្របខណ្ឌ PISA ហើយបានបញ្ចូលសំណួរតេស្តផ្តោតលើបរិបទ

ជីវិតជាក់ស្តែង, ការគិតពិចារណាស្វែងរកហេតុផល, ការបកស្រាយ, និងសំណួរតេស្តគំរូតាមបែប PISA ទៅក្នុងការវាយតម្លៃក្នុងថ្នាក់រៀន។ ការធ្វើបែបនេះបានពង្រឹងភាពស៊ីសង្វាក់គ្នារវាងការបង្រៀនក្នុងថ្នាក់រៀន និងសមត្ថភាពដែលត្រូវវាយតម្លៃដោយកម្មវិធី PISA។

សរុបរួមមក បទពិសោធន៍ទាំងនេះបានបង្ហាញពីការផ្លាស់ប្តូរវិធីសាស្ត្របង្រៀនដ៏សំខាន់ពីការបង្រៀនដែលផ្តោតលើការទទួលបានចំណេះដឹង និងការរំឭកឡើងវិញ ទៅរកការបង្រៀនដើម្បីការយល់ដឹង, ការអនុវត្ត, ការគិតពិចារណាស្វែងរកហេតុផល, និងការដោះស្រាយបញ្ហា។ ការជួយពង្រឹងបន្ថែមដោយការធ្វើវង្វាយតម្លៃជាប្រចាំ, គាំទ្រសិស្សចំគោលដៅ, កិច្ចសហការរបស់គ្រូបង្រៀន, និងការអភិវឌ្ឍវិជ្ជាជីវៈបានរួមចំណែកធ្វើឱ្យលទ្ធផល PISA ឆ្នាំ២០២៥ ល្អប្រសើរជាងមុន តែទោះជាយ៉ាងនេះក្តី ភស្តុតាងពីការពិភាក្សាជាក្រុមនេះតែមួយមុខ មិនទាន់អាចទាញជាសេចក្តីសន្និដ្ឋានពីទំនាក់ទំនងហេតុនិងផលទាំងស្រុងបានឡើយ។

## ៤.២.៣. បទពិសោធន៍របស់សិស្ស

ការពិភាក្សាជាក្រុមជាមួយសិស្សចំនួន ១៣ នាក់ មកពីសាលារៀនដែលមានលទ្ធផលល្អចំនួនពីរ បានបង្ហាញថាសិស្សបានរៀនសូត្រច្រើនជាងមុន ដូចជាបង្រៀនបានទៀងទាត់, ទទួលបានចំណេះដឹងទូលំទូលាយ, ការផ្តល់ព័ត៌មានត្រឡប់ជាប្រចាំ, ការរៀនសូត្របែបសហការ, ការគាំទ្របន្ថែម និងបរិយាកាសរៀនសូត្រប្រកបដោយវិជ្ជមាន។ ក្រៅពីនោះពួកគេបានរៀនសូត្រតាមរយៈប្រភពធនធានឌីជីថល ការរៀនក្រៅម៉ោងសិក្សា និងរៀននៅផ្ទះបន្ថែម។

### ការពន្យល់យ៉ាងច្បាស់លាស់ និងការហ្វឹកហាត់យ៉ាងទូលំទូលាយ

គ្រូបង្រៀនបានពន្យល់យ៉ាងលម្អិត និងតាមលំដាប់លំដោយជាជំហានៗ ជាពិសេសបានបញ្ជាក់ច្បាស់ពីបញ្ញត្តិពិបាកៗនីមួយៗ។ គ្រូបង្រៀនបានប្រើប្រាស់សំណួរជាញឹកញាប់ ដើម្បីជួយសិស្សឱ្យផ្តោតលើចំណុចសំខាន់ៗ និងបានផ្តល់នូវឧទាហរណ៍ជាក់ស្តែងដែលពាក់ព័ន្ធនឹងប្រធានបទដែលកំពុងសិក្សា។ ចំពោះមុខវិជ្ជាវិទ្យាសាស្ត្រ គ្រូបានឱ្យសិស្សរំឭកឡើងវិញនូវរូបមន្ត និងបញ្ញត្តិនានា ការសិក្សាពីបាតុភូតពាក់ព័ន្ធ ហើយបន្ទាប់មកធ្វើលំហាត់អនុវត្តន៍ ដើម្បីពង្រឹងការយល់ដឹងរបស់ពួកគេ។

ការដោះស្រាយលំហាត់ ជួយជំរុញឱ្យសិស្សរៀនសូត្រឱ្យកាន់តែពូកែ។ ចំពោះមុខវិជ្ជាវិទ្យាសាស្ត្រ និងគណិតវិទ្យា គ្រូបានឱ្យសិស្សធ្វើលំហាត់ ដោយដកស្រង់ចេញពីសៀវភៅសិក្សាគោល និងពីប្រភពផ្សេងៗទៀត។ ការរួមបញ្ចូលគ្នានៃការពន្យល់ ការហ្វឹកហាត់ដោយមានការណែនាំ និងការអនុវត្តឡើងវិញជាប្រចាំនេះ អាចជួយសិស្សក្នុងការរៀបចំចំណេះដឹងគ្រឹះឱ្យបានរឹងមាំ មុននឹងឈានទៅដោះស្រាយកិច្ចការដែលកាន់តែស្មុគស្មាញ។

### ការរៀនសូត្រតាមរយៈការអនុវត្តជាក់ស្តែង និងការពិសោធន៍

សិស្សបានអនុវត្តជាក់ស្តែងលើមុខវិជ្ជាវិទ្យាសាស្ត្រ ដូចជាការធ្វើពិសោធន៍ងាយៗនៅបន្ទប់ពិសោធន៍ក្រោមការណែនាំរបស់គ្រូបង្រៀន។ តាមរយៈការពិសោធន៍នេះ បានផ្សារភ្ជាប់នូវបញ្ញត្តិវិទ្យាសាស្ត្រទៅនឹងការអនុវត្តជាក់ស្តែង។

សិស្សបានលើកឡើងថាបានរៀនសូត្រពីឧទាហរណ៍ និងបាតុភូតដែលពាក់ព័ន្ធនឹងជីវភាពរស់នៅប្រចាំថ្ងៃ។ កត្តានេះមានភាពស៊ីសង្វាក់គ្នាយ៉ាងខ្លាំងទៅនឹងការរៀបរាប់របស់គ្រូបង្រៀន អំពីកិច្ចខិតខំប្រឹងប្រែងក្នុងការភ្ជាប់ទ្រឹស្តីទៅនឹងបរិបទអនុវត្តជាក់ស្តែង ហើយវាអាចមានទំនាក់ទំនងយ៉ាងសំខាន់ទៅនឹង PISA ដែលទាមទារឱ្យសិស្សអនុវត្តចំណេះដឹងទៅក្នុងស្ថានភាពរស់នៅជាក់ស្តែង ជាជាងត្រឹមតែការចម្លង ឬបង្កើតព័ត៌មានដែលបានរៀននៅក្នុងថ្នាក់ឡើងវិញ។

### ការរៀនសូត្របែបសហការ និងការចូលរួមរបស់សិស្ស

សិស្សបានចូលរួមជាទៀងទាត់ នៅក្នុងការពិភាក្សា និងការចែករំលែកគំនិតយោបល់ជាមួយមិត្តរួមថ្នាក់។ សកម្មភាពក្រុមបានផ្តល់ឱកាសឱ្យសិស្សពន្យល់ពីការគិតរបស់ពួកគេ ប្រៀបធៀបវិធីសាស្ត្រផ្សេងៗគ្នា និងរៀនសូត្រពីមិត្តភក្តិ។ គ្រូបង្រៀនបានតម្រូវឱ្យក្រុមនីមួយៗពិភាក្សាលើកិច្ចការ រួចហើយធ្វើបទបង្ហាញ និងពន្យល់ពីគំនិតរបស់ពួកគេទៅកាន់ថ្នាក់ទាំងមូល។

ការអនុវត្តជាក់ស្តែងបែបនេះ បានបង្ហាញពីបរិយាកាសរៀនសូត្រមួយ ដែលរំពឹងទុកឱ្យសិស្សចូលរួមយ៉ាងសកម្ម ជាជាងត្រឹមតែអង្គុយស្តាប់គ្រូបង្រៀន។ ការរៀនសូត្របែបសហការ ក៏អាចជួយពង្រឹងការទំនាក់ទំនង ការគិតពិចារណាស្វែងរកហេតុផល និងទំនុកចិត្តក្នុងការពន្យល់ពីគំនិតយោបល់ផងដែរ ដែលសមត្ថភាពទាំងនេះ មានទំនាក់ទំនងយ៉ាងសំខាន់ទៅនឹងតម្រូវការនៃសំណួរតេស្តទម្រង់បើក និងសំណួរតេស្តផ្តោតលើបរិបទជាក់ស្តែងរបស់ PISA។

### ការវាយតម្លៃជាប្រចាំ និងការផ្តល់ព័ត៌មានត្រឡប់ភ្លាមៗ

គ្រូបានប្រើប្រាស់សំណួរ និងដាក់លំហាត់ឱ្យសិស្សធ្វើជាទៀងទាត់ ដើម្បីដឹងថាសិស្សយល់មេរៀនដែរឬទេ។ នៅពេលដែលសិស្សជួបប្រទះការលំបាក គ្រូបង្រៀនបានផ្តល់លំហាត់ស្រដៀងៗគ្នា និងបានពន្យល់ពីវិធីដោះស្រាយឱ្យកាន់តែលម្អិត និងតាមលំដាប់លំដោយជាជំហានៗ។

ការផ្តល់ព័ត៌មានត្រឡប់បន្ទាប់ពីដាក់លំហាត់ឱ្យសិស្សធ្វើជាការកិច្ចចម្បងដើម្បីឱ្យសិស្សបានដឹងពីកំហុសភ្លាមៗ និងត្រូវពន្យល់ពីចំណុចខុសឆ្គងដល់សិស្សដើម្បីកែលម្អ។ សិស្សបានចាត់ទុកកត្តានេះថាមានប្រយោជន៍ ចំពោះការជួយពួកគេឱ្យស្វែងរកចំណុចខ្វះខាត និងយល់ដឹងពីរបៀបកែលម្អ។ កិច្ចការនេះអាចធ្វើទៅបានតាមរយៈការវាយតម្លៃតាមដំណាក់កាល មិនត្រឹមតែដើម្បីវាយតម្លៃលទ្ធផលសិក្សានោះទេ ប៉ុន្តែគឺដើម្បីគាំទ្រដល់ការរៀនសូត្រ ក្នុងអំឡុងពេលនៃដំណើរការបង្រៀនតែម្តង។

## ការគាំទ្រចំគោលដៅសម្រាប់សិស្សដែលជួបការលំបាក

គ្រូបង្រៀនបានជួយគាំទ្របន្ថែមដល់សិស្សដែលជួបការលំបាកក្នុងការរៀនសូត្រ រួមបញ្ចូលទាំងកម្មវិធីសិស្សជួយសិស្ស និងការបង្រៀនបន្ថែមក្រៅម៉ោងរៀនរាល់ថ្ងៃ។ សិស្សបានរៀបរាប់ថាពួកគេបានជួបជាមួយគ្រូបង្រៀន ឬបុគ្គលិកសាលា ដើម្បីទទួលការពន្យល់ និងការណែនាំបន្ថែម។

សាលារៀនដែលមានលទ្ធផលល្អមិនពឹងផ្អែកតែលើការបង្រៀនក្នុងថ្នាក់រៀនធម្មតាតែប៉ុណ្ណោះទេ ប៉ុន្តែបានចំណាយពេលយ៉ាងច្រើន ដើម្បីជួយសិស្សជួបការលំបាក។

## បរិយាកាសរៀនសូត្រប្រកបដោយការគាំទ្រ និងការលើកទឹកចិត្ត

សិស្សបានឱ្យដឹងថាគ្រូបង្រៀនបានបើកឱកាសពេញលេញដល់សិស្សដើម្បីសាកសួរសំណួរ និងពន្យល់បន្ថែម នៅពេលពួកគេមិនយល់មេរៀន។ ជាបន្ថែម គ្រូបង្រៀនបានលើកទឹកចិត្តពួកគេឱ្យខិតខំប្រឹងប្រែងរៀនសូត្របន្ថែមទៀត ផ្តោតលើចំណុចខ្វះខាតរបស់ខ្លួន និងបន្តស្វែងរកដំណោះស្រាយ នៅពេលជួបប្រទះនូវកិច្ចការលំបាកៗ។ សាលារៀនមួយចំនួនបានប្រើប្រាស់ការប្រកួតប្រជែងក្នុងការធ្វើលំហាត់ និងការកំណត់ចំណាត់ថ្នាក់សិស្ស ដើម្បីលើកទឹកចិត្តសិស្ស។ ការអនុវត្តទាំងនេះបានបង្កើតជាវប្បធម៌ផ្តល់តម្លៃលើការខិតខំប្រឹងប្រែង ការជម្នះអត់ធ្មត់ និងការកែលម្អខ្លួនជាប្រចាំ។

## ការរៀនសូត្របន្ថែមក្រៅម៉ោងធម្មតាតាមរយៈប្រភពធនធានឌីជីថល

សិស្សបានលើកឡើង ពីការរៀនសូត្រដោយខ្លួនឯងប្រកបដោយភាពម្ចាស់ការក្រៅពីម៉ោងសិក្សាធម្មតា ដូចជា ចំពោះមុខវិជ្ជាគណិតវិទ្យា និងវិទ្យាសាស្ត្រ សិស្សបានស្វែងរកលំហាត់អនុវត្តន៍ និងការពន្យល់បន្ថែម រីឯមុខវិជ្ជាភាសាខ្មែរ ពួកគេបានប្រើប្រាស់ប្រភពធនធានអនឡាញ ដើម្បីចូលមើលមេរៀនសង្ខេប ការពន្យល់ជាសំឡេង និងឧទាហរណ៍នៃតែងសេចក្តី ដោយប្រើប្រាស់អ៊ីនធឺណិត និង YouTube។

ចំណុចនេះបង្ហាញថា ប្រភពធនធានឌីជីថល បានពង្រីកឱកាសនៃការរៀនសូត្របន្ថែមទៀតក្រៅពីម៉ោងសិក្សាផ្លូវការ។ សិស្សមិនពឹងផ្អែកតែលើគ្រូបង្រៀន និងសៀវភៅសិក្សាគោលតែមួយមុខទៀតនោះទេ ប៉ុន្តែបានចាប់ផ្តើមប្រើប្រាស់ប្រភពធនធានអនឡាញ ដើម្បីសិក្សាពីបញ្ញត្តិពិបាកៗ និងហ្វឹកហាត់ដោយខ្លួនឯងប្រកបដោយម្ចាស់ការ។ ទោះជាយ៉ាងណាក៏ដោយ ប្រសិទ្ធភាពនៃវិធីសាស្ត្រនេះអាស្រ័យលើសមត្ថភាពរបស់សិស្សក្នុងការស្វែងរក និងជ្រើសរើសសម្ភារសិក្សាដែលសមស្រប និងមានភាពជឿជាក់បាន។

# ៥. កត្តានានាដែលនាំឱ្យមានការកើនឡើងនៃលទ្ធផល PISA ឆ្នាំ ២០២៥ សម្រាប់កម្ពុជា

## ៥.១. កំណែទម្រង់ជាប្រព័ន្ធធ្វើឱ្យទទួលបានលទ្ធផលការសិក្សាកាន់តែប្រសើរ

ការកើនឡើងលទ្ធផលការសិក្សារបស់សិស្សកម្ពុជារវាងឆ្នាំ២០១៨ និងឆ្នាំ២០២៥ ឆ្លុះបញ្ចាំងពីលទ្ធផលកំណែទម្រង់ជាប្រព័ន្ធក្នុងប្រព័ន្ធអប់រំអស់រយៈពេលមួយទសវត្សរ៍ ដោយចាប់ផ្ដើមចេញពីការកែទម្រង់នៅឆ្នាំ២០១៤ ហើយបានពន្លឿនរហូតដល់ឆ្នាំ២០២៥។ កំណែទម្រង់នេះ បានផ្លាស់ប្ដូរប្រព័ន្ធអប់រំបន្តិចម្ដងៗ ចេញពីការគ្រាន់តែពង្រីកការទទួលបានការសិក្សាជាមូលដ្ឋាន ទៅរកការកែលម្អគុណភាពនៃការរៀនសូត្រ វឌ្ឍនភាពរបស់សិស្ស ប្រសិទ្ធភាពសាលារៀន សមធម៌ និងសមត្ថភាពដែលត្រូវការសម្រាប់ថ្ងៃអនាគត។

កត្តាជំរុញដ៏សំខាន់មួយ គឺការប្រមូលសិស្ស និងការរៀបចំប្រព័ន្ធអប់រំប្រកបដោយចីរភាព។ ចន្លោះឆ្នាំ ២០១៤-២០១៥ និងឆ្នាំ២០២៥-២០២៦ ការចូលរៀនរបស់កុមារអាយុពី ៣ ដល់ ៥ ឆ្នាំ បានកើនឡើងពី ៣១០ ០០០ នាក់ ដល់ ៤៤០ ០០០ នាក់ ខណៈដែលការចូលរៀនរបស់កុមារអាយុ ៥ ឆ្នាំ បានកើនឡើងពី ៦១.៤% ដល់ ៧៧.៩%។ នៅកម្រិតបឋមសិក្សា អត្រាពិតនៃការចូលរៀនបានកើនឡើងពី ៩៧.៩% ដល់ ១០១.៦% អត្រាឡើងថ្នាក់ កើនឡើងពី ៨៦.៥% ដល់ ៩០.៥% និងអត្រាបោះបង់ការសិក្សា បានថយចុះពី ៦.២% មកត្រឹម ៤.៤%។ នៅកម្រិតមធ្យមសិក្សាការចូលរៀននៅអនុវិទ្យាល័យបានកើនឡើងពី ៥៥.១% ដល់ ៧៩.០% ដោយអត្រាបញ្ចប់ការសិក្សា កើនឡើងពី ៤២.០% ដល់ ៦៣.៦%។ ចំណែកការចូលរៀននៅវិទ្យាល័យ បានកើនឡើងពី ២៥.៣% ដល់ ៤៦.៦% ដោយអត្រាបញ្ចប់ការសិក្សា កើនឡើងពី ២០.៩% ដល់ ៤១.៧%។ ការផ្លាស់ប្ដូរទាំងនេះ មានន័យថាសិស្សកាន់តែច្រើនបានចូលរៀន នៅបន្តការសិក្សាក្នុងសាលារៀនបានយូរជាងមុន និងឈានដល់អាយុដែលកម្មវិធី PISA ធ្វើការវាយតម្លៃលើសមត្ថភាពរបស់ពួកគេ។

ការកែលម្អរចនាសម្ព័ន្ធដ៏មានសារៈសំខាន់មួយ គឺសិស្សរៀនត្រឹមត្រូវតាមអាយុ។ ភាគរយសិស្សអាយុ ១៥ ឆ្នាំ ដែលរៀននៅថ្នាក់ទី១០ បានកើនឡើងពី ៣៧.៨% ក្នុងឆ្នាំ២០១៨ ដល់ ៤៦.៥% ក្នុងឆ្នាំ២០២៥ ខណៈដែលសិស្សអាយុ ១៥ ឆ្នាំ ដែលរៀននៅថ្នាក់ទី៩ បានកើនឡើងពី ២២.៧% ដល់ ២៩.៤%។ ក្នុងពេលជាមួយគ្នានេះ ភាគរយសិស្សអាយុ ១៥ ឆ្នាំ ដែលរៀននៅថ្នាក់ទី៧ បានថយចុះពី ៥.៧% មកត្រឹម ៣.២%។ ប្រការនេះបង្ហាញថា សិស្សកាន់តែច្រើនបានឡើងថ្នាក់ត្រឹមត្រូវតាមអាយុ ដែលឆ្លុះបញ្ចាំងពីការកែលម្អលើការរក្សាសិស្សឱ្យនៅរៀន និងកាត់បន្ថយការត្រួតថ្នាក់។

ជាមួយនឹងការកើនឡើងចំនួនសិស្សអាយុ ១៥ ឆ្នាំនៅប្រព័ន្ធអប់រំ ពី ២៨.១% ក្នុងឆ្នាំ២០១៨ ដល់ ៣៦.៣% ក្នុងឆ្នាំ២០២២ និងប្រមាណ ៤៣.៨% ក្នុងឆ្នាំ២០២៥ កម្មវិធី PISA ឆ្នាំ២០២៥ បានផ្តល់នូវរូបភាពកាន់តែច្បាស់លាស់ និងរឹងមាំអំពីលទ្ធផលការសិក្សាក្នុងកម្រិតប្រព័ន្ធអប់រំទាំងមូល។

ការកែលម្អនេះបានកើតលើគ្រប់កម្រិតស្ថានភាពសេដ្ឋកិច្ច-សង្គម និងមានភាពធន់កាន់តែខ្លាំងឡើង។ រវាងឆ្នាំ២០១៨ និងឆ្នាំ២០២៥ ក្រុមសិស្សមានជីវភាពទាបបានកើន ៥៨ពិន្ទុ លើមុខវិជ្ជាវិទ្យាសាស្ត្រ, ៣៤ ពិន្ទុ លើផ្នែកអំណាន និង ៥៤ ពិន្ទុលើមុខវិជ្ជាគណិតវិទ្យា ចំណែកឯក្រុមសិស្សមានជីវភាពខ្ពស់កើនបាន ៧០ ពិន្ទុ, ៣៧ ពិន្ទុ និង ៥៤ ពិន្ទុ រៀងគ្នា។ ភាគរយសិស្សដែលមានភាពធន់នឹងការសិក្សា ក៏បានកើនឡើងផងដែរ ពី ១៥.៩% ដល់ ២២.៤% លើមុខវិជ្ជាវិទ្យាសាស្ត្រ, ពី ១៤.៩% ដល់ ២១.៣% លើផ្នែកអំណាន និងពី ១៣.០% ដល់ ១៨.៧% លើមុខវិជ្ជាគណិតវិទ្យា។ និន្នាការទាំងនេះបានបង្ហាញថាសិស្សមានជីវភាពទាប កំពុងមានសមត្ថភាពកាន់តែខ្លាំងក្នុងការជម្នះរបាំងស្ថានភាពសេដ្ឋកិច្ច-សង្គម និងទទួលបានជោគជ័យក្នុងការសិក្សា ទោះបីជាគម្លាតស្ថានភាពសេដ្ឋកិច្ច-សង្គមនៅតែបន្តមានក៏ដោយ។

ពីឆ្នាំ២០១៨ ដល់ឆ្នាំ២០២៥ ពិន្ទុរបស់សាលារៀនសាធារណៈបានកើន ២៥ លើផ្នែកអំណាន, ៣៩ ពិន្ទុលើមុខវិជ្ជាគណិតវិទ្យា និង ៤៩ ពិន្ទុលើមុខវិជ្ជាវិទ្យាសាស្ត្រ ដោយមានការកើនឡើងយ៉ាងខ្លាំងរវាងឆ្នាំ ២០២២ និងឆ្នាំ២០២៥។ គម្លាតរវាងសាលារៀនសាធារណៈ និងសាលារៀនឯកជនលើផ្នែកអំណាន បានរួមតូចពី ៥៩ ពិន្ទុក្នុងឆ្នាំ២០១៨ មកត្រឹម ៣៣ ពិន្ទុក្នុងឆ្នាំ២០២៥ ខណៈដែលគម្លាតលើមុខវិជ្ជាគណិតវិទ្យាបានកាត់បន្ថយយ៉ាងច្រើនរវាងឆ្នាំ២០២២ និងឆ្នាំ២០២៥។ កត្តានេះបង្ហាញថាប្រព័ន្ធអប់រំសាធារណៈត្រូវបានកែលម្អយ៉ាងខ្លាំង។

ការកែលម្អការសិក្សានៅកម្រិតបឋមសិក្សា គឺជាកត្តារួមចំណែកដ៏សមហេតុផលមួយទៀត ដល់លទ្ធផល PISA។ ពិន្ទុ SEA-PLM បានកើនឡើងពី ២៩០ ដល់ ២៩៦ លើអំណាន និងពី ២៨៩ ដល់ ៣០១ លើមុខវិជ្ជាគណិតវិទ្យា រវាងឆ្នាំ២០១៩ និងឆ្នាំ២០២៤។ អ្វីដែលកាន់តែសំខាន់នោះគឺ ភាគរយសិស្សដែលមានលទ្ធផលសិក្សាកម្រិតខ្ពស់បានកើនឡើង ចំណែកឯភាគរយសិស្សដែលមានលទ្ធផលសិក្សាកម្រិតទាបបានថយចុះ។ ការកែលម្អនេះមានភាពលេចធ្លោជាពិសេសលើមុខវិជ្ជាគណិតវិទ្យា ដែលក្នុងនោះក្រុមសិស្សមានលទ្ធផលខ្ពស់ បានកើនឡើងពី ១៧% ដល់ ៤០% ខណៈដែលក្រុមសិស្សមានលទ្ធផលទាប បានថយចុះពី ៣៦% មកត្រឹម ២០%។ កត្តានេះបង្ហាញថា ការកែលម្អនេះ មិនមែនគ្រាន់តែជាការកើនឡើងនៃពិន្ទុមធ្យមភាគប៉ុណ្ណោះទេ ប៉ុន្តែគឺជាការកែលម្អមូលដ្ឋានគ្រឹះនៃការសិក្សាជាលក្ខណៈប្រព័ន្ធ។

## ៥.២. ការកែទម្រង់វិស័យអប់រំប្រកបដោយចីរភាព

កំណើនលទ្ធផលសិក្សាជាប្រព័ន្ធនេះ ភាគច្រើនជាលទ្ធផលកើតចេញពីកំណែទម្រង់សាលារៀន កំណែទម្រង់គ្រូបង្រៀន ការធ្វើទំនើបកម្មកម្មវិធីសិក្សា ការពង្រឹងមូលដ្ឋានគ្រឹះនៃការសិក្សា និងការធ្វើសុខដុមនីយកម្មអន្តរាគមន៍ក្នុងវិស័យអប់រំ ជាបន្តបន្ទាប់រយៈពេលជាច្រើនទសវត្សរ៍។ សកម្មភាពរួមគ្នាតាំងពីដើមមកទាំងនេះ បានធ្វើការសម្របសម្រួលកាន់តែស៊ីសង្វាក់គ្នានូវគោលនយោបាយ, ធនធាន, គ្រូបង្រៀន, កម្មវិធីសិក្សា, វង្វាយតម្លៃ, និងការគាំទ្រនៅកម្រិតសាលារៀន។

## ៥.២.១. កំណែទម្រង់សាលារៀន

*សាលារៀនជំនាន់ថ្មី*

នៅឆ្នាំសិក្សា២០១៤-២០១៥ ក្រសួងបានបង្កើត និងអនុវត្តកម្មវិធីសាលារៀនជំនាន់ថ្មី (NGS) ដោយផ្តោតលើការផ្តល់ស្វ័យភាពកាន់តែច្រើនដល់សាលារៀន ក្នុងការអនុវត្តកម្មវិធីសិក្សា ដើម្បីអភិវឌ្ឍសមត្ថភាពសិស្សក្នុងបរិបទអប់រំសតវត្សរ៍ទី២១។ ការកែទម្រង់នេះបានពង្រឹងសមត្ថភាពនៅកម្រិតសាលារៀនលើ៖

- បទដ្ឋានសីលធម៌ និងស្តង់ដាវិជ្ជាជីវៈខ្ពស់ ក្នុងចំណោមថ្នាក់ដឹកនាំសាលារៀន និងគ្រូបង្រៀន
- គណនេយ្យភាព និងនវានុវត្តន៍ក្នុងការគ្រប់គ្រងសាលារៀន និងការបង្រៀន
- ការប្រើប្រាស់បច្ចេកវិទ្យាព័ត៌មានប្រកបដោយប្រសិទ្ធភាពក្នុងការរៀន និងបង្រៀន និង
- ការអនុវត្តវិធីសាស្ត្របង្រៀនថ្មីៗ។

កំណែទម្រង់នេះផ្តើមចេញពីរបៀបដឹកនាំតាមបែបមជ្ឈការ ទៅការផ្តល់ស្វ័យភាពកាន់តែច្រើនដល់សាលារៀន គណនេយ្យភាពវិជ្ជាជីវៈ នវានុវត្តន៍ ការប្រើប្រាស់បច្ចេកវិទ្យា និងគរុកោសល្យទំនើប ដែលទាំងអស់នេះមានគោលបំណងកែលម្អការបង្រៀន និងការរៀនដោយផ្ទាល់នៅកម្រិតសាលារៀន។

សាលារៀនជំនាន់ថ្មីបានអនុវត្តវិធីសាស្ត្របង្រៀនថ្មីៗ និងប្រកបដោយនវានុវត្តន៍ រួមមាន ការរៀនតាមបែបស្ថាបនានិយម (Constructivist learning), ការរៀនផ្តោតលើគម្រោង (Project-based learning), ការប្រើប្រាស់បច្ចេកវិទ្យា, ការវាយតម្លៃផ្អែកលើកម្រិតពុទ្ធិតាមទ្រឹស្តី Bloom (Bloom's Taxonomy), ការអភិវឌ្ឍបំណិន និងការគ្រប់គ្រងបណ្ណាល័យសតវត្សរ៍ទី២១ ព្រមទាំងពង្រឹងសហគមន៍អនុវត្តន៍វិជ្ជាជីវៈ (Community of Practice - CoP) ផងដែរ។

*សាលារៀនគំរូ*

ក្រសួងក៏បានចាប់ផ្តើមអនុវត្តសាកល្បងនូវការកែទម្រង់ និងនវានុវត្តន៍ជាច្រើននៅកម្រិតសាលារៀន ដើម្បីស្វែងរកវិធីសាស្ត្រប្រកបដោយប្រសិទ្ធភាពក្នុងការកែលម្អគុណភាពសាលារៀន និងការរៀនសូត្ររបស់សិស្ស។ សកម្មភាពទាំងនេះ រួមមាន សាលារៀនអនុវត្តការគ្រប់គ្រងតាមសាលារៀន (School-Based Management) ចំនួន ១០០ ដែលបានផ្តល់ផលជះ ទៅកាន់សាលារៀនប្រមាណ ៥០០ បន្ថែមទៀត ព្រមទាំងសាលាមធ្យមសិក្សាធនធានចំនួន ៦៧ ដែលត្រូវបានបង្កើតឡើងនៅគ្រប់រាជធានី-ខេត្ត ដើម្បីលើកកម្ពស់ការអប់រំផ្នែកវិទ្យាសាស្ត្រ បច្ចេកវិទ្យា និងស្ទែម (STEM)។ សាលាមធ្យមសិក្សាធនធាននីមួយៗ ក៏បានជួយគាំទ្រសាលារៀនបណ្តាញប្រមាណពី ៣ ដល់ ៩ សាលាផងដែរ ដែលបង្កើតបានជាយន្តការសម្រាប់ចែករំលែកបទពិសោធន៍ ការអភិវឌ្ឍវិជ្ជាជីវៈ និងការអនុវត្តនវានុវត្តន៍នានា។

ក្រសួងបានពង្រីកវិសាលភាពនៃគំនិតផ្តួចផ្តើមសាលារៀនគំរូជាបន្តបន្ទាប់ ដែលជាផ្នែកមួយនៃរបៀបវារៈកំណែទម្រង់សាលារៀនគ្រប់ជ្រុងជ្រោយ ក្នុងគោលបំណងប្រែក្លាយការអនុវត្តសាលារៀនប្រកបដោយប្រសិទ្

ភាព និងពង្រឹងគុណភាពសាលារៀននៅទូទាំងប្រទេស។ ចាប់តាំងពីឆ្នាំ២០២៣ ស្តង់ដាសាលារៀនគំរូបានផ្តល់នូវក្របខណ្ឌជាប្រព័ន្ធសម្រាប់ការកំណែទម្រង់សាលារៀន ជុំវិញវិស័យអាទិភាពសំខាន់ៗចំនួន ៥ គឺ លទ្ធផលសិក្សារបស់សិស្ស, ការបង្រៀននិងការរៀន, ការចូលរួមរបស់សហគមន៍, ដំណើរប្រតិបត្តិការនិងរដ្ឋបាលសាលារៀន, និងគណនេយ្យភាពរបស់សាលារៀន។ រហូតមកដល់បច្ចុប្បន្ន សាលារៀនចំនួន ៤៣៤ បានសម្រេចបាននូវស្តង់ដាសាលារៀនគំរូ ក្នុងនោះរួមមាន សាលាមត្តេយ្យធនធាន ចំនួន ៤៩, សាលាបឋមសិក្សាសាធារណៈ ចំនួន ១៧៣ (រួមទាំង ៤១ សាលា ស្ថិតក្រោមគំនិតផ្តួចផ្តើមបណ្តុំសាលារៀន) និង, សាលាមធ្យមសិក្សាសាធារណៈ ចំនួន ២០៥ (រួមមាន អនុវិទ្យាល័យ ៣២ និងវិទ្យាល័យ ១៧៣)។ ការពង្រីកវិសាលភាពនេះបង្ហាញពីការផ្លាស់ប្តូរយ៉ាងច្បាស់លាស់ ចេញពីការអនុវត្តសាកល្បងនូវវិធីសាស្ត្រប្រកបដោយនវានុវត្តន៍ ទៅរកការពង្រីកទូទាំងប្រទេស និងការប្រែក្លាយការអនុវត្តប្រកបដោយប្រសិទ្ធភាពនៅកម្រិតសាលារៀន ដើម្បីបង្កើតបានជាក្របខណ្ឌរួមមួយសម្រាប់ការកែលម្អគុណភាពសាលារៀន ចាប់តាំងពីការអប់រំកុមារតូច រហូតដល់កម្រិតមធ្យមសិក្សា។

នៅកម្រិតសាលារៀន ក្រសួងកំពុងពង្រឹងអភិបាលកិច្ច, ភាពជាអ្នកដឹកនាំ, គណនេយ្យភាព, និងលទ្ធផលការងាររបស់សាលារៀន តាមរយៈស្តង់ដាសាលារៀនគំរូ, ការធ្វើស្វ័យវាយតម្លៃខ្លួនឯងរបស់សាលារៀន, ការធ្វើអធិការកិច្ចអចិន្ត្រៃយ៍, និងការរៀបចំផែនការកែលម្អសាលារៀន។ សាលារៀនត្រូវប្រើប្រាស់ភស្តុតាងចេញពីលទ្ធផលនៃការរៀនសូត្ររបស់សិស្ស ដើម្បីស្វែងរកចំណុចខ្វះខាត និងរៀបចំវិធានការកែលម្អដែលចំគោលដៅ។ ជាមួយគ្នានេះដែរ កិច្ចខិតខំប្រឹងប្រែងនានាក៏កំពុងត្រូវបានធ្វើឡើង ដើម្បីពង្រឹងការចូលរួមរបស់សហគមន៍ និងកាត់បន្ថយគម្លាតរវាងសាលារៀននៅប្រជុំជន និងជនបទ។

ក្រសួងក៏កំពុងពង្រឹងប្រព័ន្ធវាយតម្លៃ និងអធិការកិច្ចផងដែរ ដើម្បីឱ្យការវាយតម្លៃមិនត្រឹមតែត្រូវបានប្រើប្រាស់សម្រាប់វាស់វែងការរៀនសូត្រប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងសម្រាប់កែលម្អការបង្រៀន និងលទ្ធផលការងាររបស់សាលារៀនទៀតផង។ វាយតម្លៃថ្នាក់ជាតិ និងវាយតម្លៃកម្រិតសាលារៀន ត្រូវបានបន្ស៊ីគ្នាឱ្យស្របទៅនឹងការសិក្សាផ្តោតលើសមត្ថភាព (Competency-based learning) និងវាយតម្លៃកម្រិតអន្តរជាតិដូចជា SEA-PLM និង PISA ជាដើម។ វិធីសាស្ត្រអធិការកិច្ចសាលារៀនបែបថ្មីមួយកំពុងត្រូវបានអភិវឌ្ឍ ដែលក្នុងនោះសាលារៀនត្រូវធ្វើស្វ័យវាយតម្លៃខ្លួនឯងធៀបនឹងស្តង់ដាសាលារៀនគំរូ។

## ៥.២.២. កំណែទម្រង់គ្រូបង្រៀន

### *កំណែទម្រង់គ្រឹះស្ថានបណ្តុះបណ្តាលគ្រូ*

ក្រសួងបានពង្រឹងគុណភាពគ្រូបង្រៀន, ការបណ្តុះបណ្តាលគ្រូបង្រៀន, និងស្តង់ដាវិជ្ជាជីវៈគ្រូបង្រៀនដែលជាសសរស្តម្ភដ៏សំខាន់នៃកំណែទម្រង់វិស័យអប់រំ។ ការបណ្តុះបណ្តាលគ្រូបង្រៀនបានវិវត្តជាបន្តបន្ទាប់ ពីកម្មវិធីបណ្តុះបណ្តាលគ្រូបង្រៀនកម្រិតមូលដ្ឋាន ១២+២ ទៅការបណ្តុះបណ្តាលកម្រិត ១២+៤ និងកម្រិតបរិញ្ញាបត្រ ចំណែកឯក្របខណ្ឌបរិញ្ញាបត្រ+២ (BA+2) សម្រាប់ការបណ្តុះបណ្តាលគ្រូបង្រៀនកម្រិតឧត្តម ក៏

ត្រូវបានអនុម័តផងដែរ។ កម្មវិធីបណ្តុះបណ្តាលគ្រូបង្រៀនបានបញ្ចូលវិធីសាស្រ្តបង្រៀនអំណានថ្នាក់ដំបូង និងគណិតវិទ្យាថ្នាក់ដំបូង, វិធីសាស្រ្តបង្រៀនទំនើបៗ, ការគ្រប់គ្រងថ្នាក់រៀន, និងគរុកោសល្យសម្រាប់សតវត្សរ៍ទី២១។

ក្រសួងក៏បានពង្រឹងគ្រឹះស្ថានបណ្តុះបណ្តាលគ្រូបង្រៀនផងដែរ។ វិទ្យាស្ថានគរុកោសល្យរាជធានីភ្នំពេញ (PTEC) និងវិទ្យាស្ថានគរុកោសល្យខេត្តបាត់ដំបង (BTEC) ត្រូវបានបង្កើតឡើង ដើម្បីផ្តល់ការបណ្តុះបណ្តាលគ្រូបង្រៀនកម្រិត ១២+៤ ខណៈដែលមជ្ឈមណ្ឌលគរុកោសល្យភូមិភាគចំនួន ៤ កំពុងត្រូវបានប្រែក្លាយទៅជាវិទ្យាស្ថានគរុកោសល្យ។

គ្រឹះស្ថានចំនួន ៥ ត្រូវបានទទួលស្គាល់ជាគ្រឹះស្ថានបណ្តុះបណ្តាលគ្រូបង្រៀនគំរូ៖

- វិទ្យាស្ថានជាតិអប់រំ (NIE)
- វិទ្យាស្ថានគរុកោសល្យរាជធានីភ្នំពេញ (PTEC)
- វិទ្យាស្ថានគរុកោសល្យខេត្តបាត់ដំបង (BTEC)
- មហាវិទ្យាល័យអប់រំនៃសាកលវិទ្យាល័យភូមិន្ទភ្នំពេញ (FoE/RUPP)
- សាលាគរុកោសល្យ និងវិក្រឹតការខេត្តសៀមរាប

ការអភិវឌ្ឍវិជ្ជាជីវៈត្រូវបានបញ្ចូលទៅក្នុងការបណ្តុះបណ្តាលគ្រូ តាមរយៈការអនុវត្តសហគមន៍សិក្សាវិជ្ជាជីវៈ (PLCs) និងការអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំ (CPD)។ គ្រឹះស្ថានចំនួន ៥ ត្រូវបានទទួលស្គាល់ជាគ្រឹះស្ថានផ្តល់ការអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំ (CPD providers) និងបានបើកវគ្គសិក្សាចំនួន ៤៨ ដែលគ្របដណ្តប់លើផ្នែកផ្សេងៗគ្នា។ ក្រសួងក៏បានជ្រើសរើសគ្រូឧទ្ទេសឆ្នើមចំនួន ៥ រូប ដោយផ្អែកលើការវាយតម្លៃខ្លួនឯង , ភស្តុតាង និងវីដេអូនៃការបង្រៀន ព្រមទាំងកំពុងរៀបចំគោលការណ៍សម្រាប់ការវាយតម្លៃ និងការទទួលស្គាល់គន្លងវិជ្ជាជីវៈគ្រូបង្រៀន ព្រមទាំងកម្មវិធីសិក្សាឯកទេសអប់រំកម្រិតបរិញ្ញាបត្រជាន់ខ្ពស់សម្រាប់គ្រូឧទ្ទេសផងដែរ។

ជាមួយគ្នានេះដែរ ក្រសួងកំពុងធ្វើការលើកកម្ពស់ហេដ្ឋារចនាសម្ព័ន្ធអប់រំគ្រូបង្រៀន និងធនធានសិក្សារួមទាំងបណ្ណាល័យឌីជីថល ព្រមទាំងពង្រឹងទំនាក់ទំនងរវាងគ្រឹះស្ថានបណ្តុះបណ្តាលគ្រូបង្រៀន សាលារៀនជំនាន់ថ្មី (NGS) និងសាលារៀនគំរូ។ ការផ្តល់អាហារូបករណ៍ដែលមានតម្លៃសមមូលនឹង ៧០% នៃប្រាក់បៀវត្សរ៍មូលដ្ឋានរបស់គ្រូបង្រៀន បានជួយទាក់ទាញបេក្ខជនដែលប្រឡងជាប់បាននិទ្ទេស A, B និង C កាន់តែច្រើនឱ្យចូលបម្រើការជាគ្រូបង្រៀន។

### *ការអភិវឌ្ឍគ្រូបង្រៀន*

ក្រសួងកំពុងពង្រឹងគុណភាពគ្រូបង្រៀន ការអភិវឌ្ឍវិជ្ជាជីវៈ និងការគ្រប់គ្រងគ្រូបង្រៀនតាមបែបយុទ្ធសាស្រ្ត ជាសសរស្តម្ភដ៏សំខាន់នៃការកែទម្រង់វិស័យអប់រំ។

ការអភិវឌ្ឍវិជ្ជាជីវៈគ្រូបង្រៀន កំពុងត្រូវបានពង្រឹងតាមរយៈថ្នាលអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំ (CPD platform) ដែលតភ្ជាប់ទៅនឹងកម្មវិធី TQU និងកម្មវិធី HRCPD ដែលអនុញ្ញាតឱ្យបុគ្គលិកអប់រំចូលរួមការបណ្តុះបណ្តាល និងសន្សំក្រេឌីត។

ក្រសួងក៏កំពុងដោះស្រាយបញ្ហាខ្វះគ្រូ និងការបែងចែកគ្រូបង្រៀនមិនសមមាត្រផងដែរ ជាពិសេសនៅតាមសាលារៀនជនបទ និងតំបន់ជួបការលំបាក ខណៈពេលដែលកំពុងពង្រឹងគន្លងអាជីពគ្រូបង្រៀន និងការអភិវឌ្ឍវិជ្ជាជីវៈ ដើម្បីលើកកម្ពស់ការលើកទឹកចិត្ត លទ្ធផលបំពេញការងារ និងការរក្សាទុកគ្រូបង្រៀនក្នុងប្រព័ន្ធ។ នៅក្នុងឆ្នាំ២០២៥ គ្រូបង្រៀនបឋមសិក្សា និងអនុវិទ្យាល័យចំនួន ១ ៣៥១ នាក់ បានបញ្ចប់ការបណ្តុះបណ្តាល និងត្រូវបានចាត់តាំងឱ្យទៅបម្រើការនៅតាមសាលារៀនគោលដៅ ខណៈដែលគ្រូបង្រៀនជាប់កិច្ចសន្យាចំនួន ៤ ៩៤៦ នាក់ ត្រូវបានជ្រើសរើសសម្រាប់ខេត្តគោលដៅ។ ចាប់ពីឆ្នាំ២០២៤-២០២៥ គរុសិស្ស និងគរុនិស្សិត ក៏ទទួលបានប្រាក់ឧបត្ថម្ភពីរាជរដ្ឋាភិបាល ដែលមានតម្លៃនឹង ៧០% នៃប្រាក់បៀវត្សរ៍របស់គ្រូបង្រៀនក្នុងក្របខណ្ឌពាក់ព័ន្ធផងដែរ។ សរុបរួមមក វិធានការនេះ បានបង្ហាញពីការលើកកម្ពស់វិជ្ជាជីវៈគ្រូបង្រៀន ដោយទទួលបានការគាំទ្រល្អប្រសើរជាងមុន ការដាក់វិធានការផ្តែកលើភស្តុតាងច្បាស់លាស់ ដែលជាកត្តាចាំបាច់សម្រាប់ការរក្សា និងពន្លឿនការកែលម្អលទ្ធផលសិក្សារបស់សិស្សកម្ពុជា។

### ៥.២.៣. កំណែទម្រង់កម្មវិធីសិក្សា

ក្រសួងបានពង្រឹងការអនុវត្តកម្មវិធីសិក្សា មិនត្រឹមតែកែលម្អឡើងវិញនូវខ្លឹមសារ ប៉ុន្តែបានបង្កើនម៉ោងរៀនប្រកបដោយប្រសិទ្ធភាព ការកាត់បន្ថយការបាត់ម៉ោងសិក្សា ការដោះស្រាយគម្លាតនៃការរៀនសូត្រ និងការផ្តល់ឱកាសបន្ថែមសម្រាប់សិស្សក្នុងការអនុវត្ត និងប្រើប្រាស់ចំណេះដឹង។

ការអនុវត្តស្តង់ដាសាលារៀនគំរូ យុទ្ធសាស្ត្រសហគមន៍សាលារៀន សាលារៀនបង្រៀនពេញមួយថ្ងៃ សាលារៀនជំនាន់ថ្មី បានកាត់បន្ថយការបាត់ម៉ោងសិក្សា និងធានាថាម៉ោងបង្រៀនត្រូវបានអនុវត្តប្រកបដោយប្រសិទ្ធភាពសម្រាប់ការបង្រៀន និងការរៀន។ កិច្ចខិតខំប្រឹងប្រែងនេះ ត្រូវបានបំពេញបន្ថែមដោយការវិនិយោគក្រោមគម្រោង SEIP, GEIP និងបន្តទៅ BEIP ដើម្បីជួយគាំទ្រដល់សិស្សដែលរៀនយឺត។

សាលារៀនមួយចំនួនកំពុងប្រើប្រាស់ម៉ោងសិក្សាបន្ថែម ដើម្បីពង្រឹងមុខវិជ្ជាភាសាខ្មែរ គណិតវិទ្យា និងវិទ្យាសាស្ត្រ ខណៈដែលសាលារៀនផ្សេងទៀតកំពុងបង្កើតក្លឹបសិក្សា ដែលផ្តល់ឱកាសបន្ថែមសម្រាប់សិស្សក្នុងការអាន ការអនុវត្តលំហាត់គណិតវិទ្យា ការធ្វើសកម្មភាពវិទ្យាសាស្ត្រ និងស្វ័យសិក្សា។

បច្ចេកវិទ្យាឌីជីថល ក៏កំពុងត្រូវបានប្រើប្រាស់ផងដែរ ដើម្បីពង្រីកការរៀនសូត្រក្រៅម៉ោងសិក្សាធម្មតានៅក្នុងថ្នាក់រៀន។ ប្រព័ន្ធបច្ចេកវិទ្យានានា ដូចជា ថ្នាលបឋម (Primary Learning Platform - PLP), សាលាឌីជីថល (Sala Digital), ថ្នាលមធ្យមសិក្សា (MoEYS EdTech) និង ប្រព័ន្ធរៀនពីចម្ងាយ MoEYS eLearning បានផ្តល់នូវសម្ភារសិក្សាបន្ថែម លំហាត់អនុវត្ត និងកិច្ចការសាលា ដែលសិស្សអាចប្រើប្រាស់បាននៅសាលារៀន ឬស្វ័យសិក្សានៅផ្ទះ។

### ៥.២.៤. កំណែទម្រង់វាយតម្លៃការសិក្សារបស់សិស្ស

ក្រសួងកំពុងពង្រឹងប្រព័ន្ធវាយតម្លៃការសិក្សារបស់សិស្ស និងការសិក្សាតាមប្រព័ន្ធឌីជីថល តាមរយៈថ្នាលបឋម (PLP) ។ ថ្នាលទាំងនេះគាំទ្រដល់ការធ្វើតេស្តប្រចាំខែ និងតេស្តស្តង់ដាប្រចាំឆមាស រួមទាំងការវាយតម្លៃដែលមានសំណួរតេស្តប្រហែល ៤០ សំណួរ ស្របតាមក្របខណ្ឌកម្រិតសមត្ថភាពសកល (Global Proficiency Framework) ដែលអនុញ្ញាតឱ្យមានការតាមដានការសិក្សា របស់សិស្ស និងការកំណត់រកគម្លាតនៃការសិក្សាបានទៀងទាត់ជាងមុន។ ក្រសួងក៏កំពុងផលិតធនាគារសំណួរតេស្ត ដែលមានលំហាត់តាមលំនាំសំណួរតេស្ត PISA ដើម្បីពង្រឹងសមត្ថភាពរបស់សិស្សក្នុងការប្រើប្រាស់ចំណេះដឹង ការបកស្រាយព័ត៌មាន ការផ្តល់ហេតុផល និងការដោះស្រាយបញ្ហា ដោយផ្លាស់ប្តូរចេញពីការផ្អែកលើការទន្ទេញចាំមាត់តែមួយមុខ។

ជាមួយគ្នានេះដែរ ក្រសួងកំពុងពង្រីកការសិក្សាផ្តោតលើសមត្ថភាព និងការសិក្សាដែលយកសិស្សជាគោល តាមរយៈការសិក្សាផ្តោតលើគម្រោង (Project-based learning) ការសិក្សាដោយខ្លួនឯង ជំនាញស្រាវជ្រាវ និងជំនាញឌីជីថល តាមរយៈការអនុវត្តក្របខណ្ឌអប់រំស្វែមកម្រិតសាលារៀន (SLSF) និងវាយតម្លៃផ្តោតលើសមត្ថភាព (CBA) ជាពិសេសនៅក្នុងសាលារៀនជំនាន់ថ្មី (NGS) សាលារៀនគំរូ (Model Schools) និងគ្រឹះស្ថានបណ្តុះបណ្តាលគ្រូបង្រៀន រួមមាន វិទ្យាស្ថានជាតិអប់រំ (NIE) វិទ្យាស្ថានគរុកោសល្យរាជធានីភ្នំពេញ (PTEC) និងវិទ្យាស្ថានគរុកោសល្យខេត្តបាត់ដំបង (BTEC)។ នៅតាមវិទ្យាល័យធនធាន វាយតម្លៃផ្តោតលើសមត្ថភាពលើមុខវិជ្ជាវិទ្យាសាស្ត្រ ក៏កំពុងត្រូវបានពង្រឹងផងដែរ ដើម្បីលើកកម្ពស់ការរិះរកលើផ្នែកវិទ្យាសាស្ត្រ, ការពិសោធន៍, ការដោះស្រាយបញ្ហា និងការអនុវត្តជាក់ស្តែងលើចំណេះដឹងវិទ្យាសាស្ត្រ។

សរុបរួមមក កំណែទម្រង់ទាំងនេះបង្ហាញពីការផ្លាស់ប្តូរពីការវាយតម្លៃដែលគ្រាន់តែជា "ការវាស់វែងលើការសិក្សា" ទៅជា "មធ្យោបាយសម្រាប់កែលម្អការរៀនសូត្រ"។ តាមរយៈការរួមបញ្ចូលគ្នានូវកត្តាសំខាន់ៗ ដែលទាក់ទងនឹងលទ្ធផលសិក្សារបស់សិស្សរួមមាន ប្រព័ន្ធបច្ចេកវិទ្យាឌីជីថល, វាយតម្លៃផ្តោតលើសមត្ថភាព, និងលំហាត់តាមលំនាំ PISA កម្ពុជាកំពុងបង្កើតប្រព័ន្ធរៀនសូត្រផ្អែកលើទិន្នន័យកាន់តែរឹងមាំ ដែលមានសមត្ថភាពកំណត់រកគម្លាតនៃការរៀនសូត្របានលឿនជាងមុន និងគាំទ្រដល់ការកែលម្អការបង្រៀន និងលទ្ធផលសិក្សារបស់សិស្សបានចំគោលដៅជាងមុន។

### ៥.២.៥. ការពង្រឹងប្រព័ន្ធអេកូឡូស៊ីនៃការសិក្សា

ក្រសួងកំពុងអនុវត្តនូវកំណែទម្រង់គ្រប់ជ្រុងជ្រោយ ដើម្បីកែលម្អលទ្ធផលសិក្សារបស់សិស្ស ដែលគ្របដណ្តប់លើការអប់រំកុមារតូច, មូលដ្ឋានគ្រឹះនៃការសិក្សា, កម្មវិធីសិក្សា, ការបង្រៀននិងរៀន, ការអប់រំមធ្យមសិក្សា, គ្រូបង្រៀន, សាលារៀន, វាយតម្លៃការសិក្សា, ការសិក្សាតាមប្រព័ន្ធឌីជីថល និងសមធម៌។ ការកែទម្រង់ទាំងនេះឆ្លើយតបដោយផ្ទាល់ទៅនឹងភស្តុតាងទទួលបានពី SEA-PLM និង PISA ស្របនឹងការបន្តពង្រឹងលើការកែទម្រង់ជាប្រព័ន្ធ ដែលបានអនុវត្តក្នុងពេលមួយទសវត្សរ៍កន្លងមកនេះ។

នៅកម្រិតការអប់រំកុមារតូច ក្រសួងកំពុងពង្រីកការទទួលបានការអប់រំ តាមរយៈសហគមន៍, រដ្ឋ, ឯកជន និងដៃគូផ្តល់សេវាផ្សេងទៀត ដើម្បីពង្រឹងការត្រៀមខ្លួនរបស់កុមារក្នុងការចូលរៀននៅបឋមសិក្សា ដោយផ្តល់ការយកចិត្តទុកដាក់កាន់តែខ្លាំងលើការចូលរៀននៅមត្តេយ្យសិក្សា និងការពង្រឹងសមត្ថភាពគ្រូមត្តេយ្យក្នុងការបង្រៀនតាមបែបលេង និងការថែទាំកុមារ។

នៅកម្រិតបឋមសិក្សា ក្រសួងកំពុងពង្រឹងមូលដ្ឋានគ្រឹះនៃការសិក្សា តាមរយៈអំណានថ្នាក់ដំបូង និងគណិតវិទ្យាថ្នាក់ដំបូង។ កិច្ចការទាំងនេះរួមមាន ការអភិវឌ្ឍកញ្ចប់សម្ភារអំណាន និងគណិតវិទ្យាថ្នាក់ ដូចជាសៀវភៅណែនាំគ្រូ សៀវភៅជំនួយសិស្ស សៀវភៅហ្វឹកហាត់អានសរសេរ និងធ្វើលំហាត់ និងសៀវភៅរឿងខ្លីៗជាដើម។ ទន្ទឹមនឹងនេះគ្រូបង្រៀនថ្នាក់ទី១ ដល់ទី៣ ទទួលបានការបណ្តុះបណ្តាលស្តីការអនុវត្តកញ្ចប់អំណាន និងគណិតវិទ្យាដំបូង ដោយមានការគាំទ្រពីទីប្រឹក្សាគរុកោសល្យក្នុងពេលអនុវត្តនៅតាមថ្នាក់រៀន។ ដើម្បីធានានិរន្តរភាព ក្រសួងបានដាក់បញ្ចូលការអនុវត្តកញ្ចប់អំណាន និងគណិតវិទ្យាដំបូងទៅក្នុងកម្មវិធីបណ្តុះបណ្តាលគ្រូបង្រៀន ១២+២ និង ១២+៤ ។ បន្ថែមលើសពីនេះ ក្រសួងបានអនុវត្តកម្មវិធីបង្រៀនសម្របតាមសមត្ថភាពសិស្ស (PTOM) ដើម្បីផ្តល់ការគាំទ្រដល់សិស្សរៀនយឺត។

ក្រសួងក៏កំពុងពង្រឹងប្រព័ន្ធអេកូឡូស៊ីនៃការសិក្សា ក្រៅពីការសិក្សាក្នុងថ្នាក់រៀន តាមរយៈការលើកកម្ពស់ការអានសៀវភៅរឿង ការអានឡើងវិញ បណ្ណាល័យ សម្ភារសិក្សា និងការណែនាំអំពីវិធីសាស្ត្រអំណានប្រកបដោយប្រសិទ្ធភាព។ ដោយទទួលស្គាល់ថាបំណិនមូលដ្ឋានតម្រូវឱ្យមានការអនុវត្ត និងពង្រឹងជាប្រចាំ ក្រសួងកំពុងវិនិយោគលើសៀវភៅណែនាំគ្រូ ការគាំទ្របច្ចេកទេសនៅកម្រិតសាលារៀន និងការប្រឹក្សាគរុកោសល្យជាប្រចាំ រួមទាំងនៅតំបន់ដាច់ស្រយាលផងដែរ។ វិធានការទាំងនេះបង្កើតឱកាសកាន់តែច្រើនសម្រាប់សិស្សក្នុងការអនុវត្ត និងពង្រឹងបំណិនគ្រឹះទាំងនៅក្នុង និងក្រៅថ្នាក់រៀន។

ក្រសួងកំពុងពង្រឹងកម្មវិធីសិក្សា ម៉ោងសិក្សា និងការអនុវត្តក្នុងថ្នាក់រៀន រួមទាំងពង្រីកការបង្រៀនពេញមួយថ្ងៃ និងការបង្កើនម៉ោងសិក្សាលើមុខវិជ្ជាភាសាខ្មែរ គណិតវិទ្យា និងវិទ្យាសាស្ត្រ។ ក្លឹបសិក្សា និងប្រព័ន្ធបច្ចេកវិទ្យាឌីជីថលបានផ្តល់ឱកាសបន្ថែមសម្រាប់ការរៀនសូត្រដោយខ្លួនឯង។

នៅកម្រិតមធ្យមសិក្សា ក្រសួងកំពុងពង្រឹងការអប់រំផ្តោតលើសមត្ថភាព និងបន្សុីកម្មវិធីសិក្សា ព្រមទាំងការអនុវត្តក្នុងថ្នាក់រៀនឱ្យកាន់តែប្រកៀកទៅនឹងសមត្ថភាពដែលត្រូវបានវាស់វែងដោយកម្មវិធី PISA។ ការសិក្សាផ្តោតលើគម្រោង (Project-based), ការសិក្សាបែបរិះរក (Inquiry-based), និងដោះស្រាយបញ្ហា (Problem-solving) កំពុងត្រូវបានលើកកម្ពស់ ខណៈដែលការអប់រំវិទ្យាសាស្ត្រត្រូវបានពង្រឹងតាមរយៈការពិសោធន៍ ការបកស្រាយទិន្នន័យ ការផ្តល់ហេតុផល និងការអនុវត្តក្នុងជីវិតជាក់ស្តែង។ ម៉ោងសិក្សាបន្ថែម ការគាំទ្រអំណាន និងបំប៉នបន្ថែម ក៏កំពុងត្រូវបានពង្រីកសម្រាប់សិស្សដែលត្រូវការការគាំទ្របន្ថែមផងដែរ។

កម្ពុជាបានពង្រីកការវិនិយោគជាបន្តបន្ទាប់លើការអប់រំស្ទែម (STEM) តាមរយៈគម្រោង USESDP-II, STEP UP, SE4HC និង GEIP/GEIP-AF ដោយផ្លាស់ប្តូរពីការផ្តល់ហេដ្ឋារចនាសម្ព័ន្ធ ទៅរកគំរូរួមបញ្ចូលគ្នា

កាន់តែទូលំទូលាយ ដែលប្លុកបញ្ចូលនូវសមត្ថភាពគ្រូបង្រៀន ការអនុវត្តនៅកម្រិតសាលារៀន ធនធានសិក្សា និងវង្វាយតម្លៃផ្តោតលើសមត្ថភាព។

គម្រោង USESDP-II បានបង្កើតវិទ្យាល័យធនធានដំបូងចំនួន ៥០ និងសាលារៀនបណ្តាញចំនួន ៨៧។ វិទ្យាល័យធនធាននីមួយៗទទួលបានបន្ទប់បច្ចេកវិទ្យាព័ត៌មាននិងសារគមនាគមន៍ (ICT) ចំនួន ២ ដោយមានកុំព្យូទ័រចំនួន ៥០គ្រឿង និងថេប្លេត (tablet) ចំនួន ៦៤គ្រឿង។ គម្រោងនេះបានរៀបចំបណ្ណាល័យចំនួន ៥០ និងបានកែប្រែបន្ទប់រៀនទៅជាបណ្ណាល័យនៅក្នុងសាលារៀនចំនួន ៨៧ ព្រមទាំងបានផ្តល់បន្ទប់ពិសោធន៍វិទ្យាសាស្ត្រចំនួន ២ នៅក្នុងវិទ្យាល័យធនធាននីមួយៗក្នុងចំណោម ៥០ និងបរិក្ខារបន្ទប់ពិសោធន៍នៅក្នុងសាលារៀនបណ្តាញចំនួន ៨៧។ លើសពីនេះ គម្រោងក៏បានបណ្តុះបណ្តាលគ្រូបង្រៀនវិទ្យាសាស្ត្រចំនួន ១៩៨នាក់, គ្រូបង្រៀន និងគណៈគ្រប់គ្រងសាលារៀនចំនួន ២ ០២២នាក់ នៅតាមសាលារៀនធនធាន, និងគ្រូបង្រៀនចំនួន ៣ ៣៤០នាក់ នៅតាមសាលារៀនបណ្តាញអំពីវិធីសាស្ត្រពាក់ព័ន្ធនឹងការអប់រំស្ទែម (STEM) ផងដែរ។

គម្រោង STEP UP បានពង្រីកហេដ្ឋារចនាសម្ព័ន្ធស្ទែម (STEM) ទៅកាន់សាលារៀនចំនួន ១១៨ ដោយសាលារៀននីមួយៗទទួលបានបន្ទប់ពិសោធន៍វិទ្យាសាស្ត្រចំនួន ២, កែប្រែបន្ទប់ឱ្យក្លាយជាបន្ទប់ ICT ចំនួន ៣៧០ នៅក្នុងសាលារៀនចំនួន ១៥៧ និងបានផ្តល់ថេប្លេតចំនួន ១៥០គ្រឿង សម្រាប់ការវាយតម្លៃតាមប្រព័ន្ធឌីជីថល។ គម្រោងនេះបានដំឡើងប្រព័ន្ធថាមពលព្រះអាទិត្យនៅក្នុងសាលារៀនចំនួន ១០២ ដាក់ឱ្យប្រើប្រាស់កញ្ចប់បរិក្ខារថ្នាក់រៀនវៃឆ្លាត (Smart Classroom) នៅតាមសាលារៀនធនធានចំនួន ៥០ សាលារៀនបណ្តាញចំនួន ១០២ និងសាលាមធ្យមសិក្សាទូទៅចំនួន ១០៣ ព្រមទាំងបានគាំទ្រសាលារៀនចំនួន ១១៨ ជាមួយនឹងបណ្ណាល័យសតវត្សរ៍ទី២១ និងសាលារៀនធនធានចំនួន ២៥ ជាមួយនឹងបន្ទប់ពហុបំណង។ លើសពីនេះ គម្រោងក៏បានអភិវឌ្ឍឯកសារណែនាំសម្រាប់បន្ទប់ពិសោធន៍វិទ្យាសាស្ត្រចំនួន ២៨ និងវីដេអូពិសោធន៍ចំនួន ៧២ ដោយគ្របដណ្តប់ ១៨វីដេអូ លើមុខវិជ្ជានីមួយៗរួមមាន រូបវិទ្យា គីមីវិទ្យា ជីវវិទ្យា និងផែនដីវិទ្យា។

ជាសំខាន់ គម្រោង STEP UP បានដាក់ឱ្យប្រើប្រាស់នូវក្របខណ្ឌការអប់រំស្ទែមកម្រិតសាលារៀន (SLSF) នៅក្នុងឆ្នាំ២០២៥ និងឯកសារណែនាំស្តីពីវង្វាយតម្លៃផ្តោតលើសមត្ថភាព (CBA) នៅក្នុងឆ្នាំ២០២៦ ដោយផ្លាស់ប្តូរការយកចិត្តទុកដាក់ពីការផ្តល់ធាតុចូលស្ទែម ទៅរករបៀបដែលសាលារៀនរៀបចំការរៀនសូត្រស្ទែម និងវង្វាយតម្លៃផ្តោតលើសមត្ថភាព។ ក្របខណ្ឌ SLSF និង CBA នេះ ត្រូវបានដាក់ឱ្យអនុវត្តសាកល្បងដំបូងនៅក្នុងវិទ្យាល័យចំនួន ៣០ ហើយបច្ចុប្បន្នកំពុងត្រូវបានពង្រីកទៅកាន់វិទ្យាល័យចំនួន ១៥០ ដែលផ្តល់នូវក្របខណ្ឌសម្រាប់ការចាត់ចែងពង្រីកវិសាលភាពនៃវិធីសាស្ត្រអប់រំស្ទែម និងការអប់រំផ្អែកលើសមត្ថភាពឱ្យកាន់តែមានប្រព័ន្ធសង្គតិភាព និងចីរភាព។

ក្រសួងបានផ្លាស់ប្តូរទិសដៅនៃកំណែទម្រង់វិស័យអប់រំ ពីការផ្តោតលើការចូលរៀនទៅរកគុណភាព និងសមត្ថភាពស្ថាប័ន ដោយទទួលបានការគាំទ្រពីគម្រោង SEIP, GEIP/GEIP-AF និង BEIP។ គម្រោង

GEIP/GEIP-AF ផ្ដោតសំខាន់លើការគ្រប់គ្រងតាមសាលារៀន (SBM) ការធ្វើទំនើបកម្មកម្មវិធីសិក្សា ការអភិវឌ្ឍវិជ្ជាជីវៈគ្រូបង្រៀននិងគណៈគ្រប់គ្រងសាលារៀន និងការវាយតម្លៃសិស្សតាមស្តង់ដា។

គម្រោង GEIP/GEIP-AF បានពង្រីកវិសាលភាពនៅទូទាំងប្រទេសទៅកាន់សាលារៀនចំនួន ៣ ២១៣ (មត្តេយ្យសិក្សា ២៩៣, បឋមសិក្សា ២ ០០០, និងមធ្យមសិក្សា ៩២០) ជាមួយនឹងថវិកា ១៥០,៣៥ លានដុល្លារអាមេរិក។ ក្របខណ្ឌរបស់គម្រោងនេះបានវិវត្តពី 3As (ការវាយតម្លៃ/Assessment, ស្វ័យភាព/Autonomy, គណនេយ្យភាព/Accountability) ទៅជា 3As+3 ដោយបន្ថែមនូវការអភិវឌ្ឍគ្រូបង្រៀន ការរៀនសូត្រនិងចែករំលែកបទពិសោធន៍ទៅវិញទៅមក និងការអប់រំកុមារតូច។

សរុបមក ការវិនិយោគទាំងនេះកំពុងបង្កើតនូវមូលដ្ឋានគ្រឹះសម្រាប់ប្រព័ន្ធអេកូឡូស៊ីស្ទែមនៅកម្រិតសាលារៀន។ ឱកាសសំខាន់គឺការភ្ជាប់ទំនាក់ទំនងរវាងហេដ្ឋារចនាសម្ព័ន្ធ រួមមាន៖ បន្ទប់ពិសោធន៍ បណ្ណាល័យ បន្ទប់ ICT ថ្នាក់រៀនវៃឆ្លាត និងធនធានឌីជីថល ទៅនឹងការបង្រៀនប្រកបដោយប្រសិទ្ធភាព តាមរយៈក្របខណ្ឌការអប់រំស្ទែមកម្រិតសាលារៀន (SLSF) និងការប្រើប្រាស់ការវាយតម្លៃផ្ដោតលើសមត្ថភាព (CBA) ដើម្បីផ្លាស់ប្ដូរការវាយតម្លៃទៅរកការរិះរក ការអនុវត្ត ការផ្ដល់ហេតុផល និងការដោះស្រាយបញ្ហា។ អាទិភាពនាពេលនេះ មិនមែនត្រឹមតែជាការផ្ដល់ជាតុចូលបន្ថែមទៀតនោះទេ ប៉ុន្តែគឺការធានាថាការវិនិយោគដ៏ច្រើនសន្ធឹកសន្ធាប់ទាំងនេះត្រូវបានប្រើប្រាស់ជាប្រចាំ និងមានប្រសិទ្ធភាព ដើម្បីកែលម្អការបង្រៀនមុខវិជ្ជាស្ទែម និងការរៀនសូត្ររបស់សិស្ស។

ក្រសួងក៏កំពុងពង្រីកការអប់រំឌីជីថល និងបច្ចេកវិទ្យាសម្រាប់ការសិក្សា តាមរយៈមាតិកាឌីជីថល ជំនាញឌីជីថល ថ្នាលសិក្សា និងកម្មវិធីផ្សេងៗ ដែលគាំទ្រដល់ការបង្រៀន, ការរៀន, ការវាយតម្លៃ, និងការស្វ័យសិក្សា។ ថ្នាលបឋម (PLP) និងថ្នាលមធ្យមសិក្សា (SLP) ដែលមានស្រាប់ កំពុងត្រូវបានធ្វើទំនើបកម្ម ដើម្បីផ្ដល់នូវការគាំទ្រការរៀនសូត្រ និងការវាយតម្លៃតាមប្រព័ន្ធឌីជីថលកាន់តែរឹងមាំ ព្រមទាំងពង្រីកឱកាសនៃការរៀនសូត្រក្រៅម៉ោងរៀនក្នុងថ្នាក់។

## ៥.២.៦. ការពង្រឹងបរិយាកាសសិក្សា និងសុខុមាលភាពសិស្ស

ក្រសួងកំពុងពង្រឹងបរិស្ថានសិក្សា និងហេដ្ឋារចនាសម្ព័ន្ធរូបវន្ត តាមរយៈការវិនិយោគធំៗលើវិស័យអប់រំ រួមទាំងការសាងសង់ទារកដ្ឋាន សាលាមត្តេយ្យសិក្សា សាលាបឋមសិក្សា និងសាលាមធ្យមសិក្សា ដើម្បីដោះស្រាយបញ្ហាចំនួនសិស្សច្រើនក្នុងមួយថ្នាក់ និងពង្រីកការទទួលបានទីកន្លែងរៀនសូត្រសមរម្យ។

គិតត្រឹមឆ្នាំ២០២៤ អគារសិក្សាចំនួន ៤ ៥៨២អគារ ស្មើនឹង ៣០ ១៣៥បន្ទប់ ត្រូវបានសាងសង់ឡើងតាមរយៈការចូលរួមឧបត្ថម្ភពី **សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**, **សម្ដេចកិត្តិព្រឹទ្ធបណ្ឌិត ប៊ុន រ៉ានី ហ៊ុន សែន**, និង **សម្ដេចមហាបវរធិបតី ហ៊ុន ម៉ាណែត**។ ក្នុងរយៈពេលមួយទសវត្សរ៍ចុងក្រោយនេះ ថវិការាជរដ្ឋាភិបាល និងដៃគូអភិវឌ្ឍន៍ ក៏បានគាំទ្រដល់ការសាងសង់អគារសិក្សាថ្មីចំនួន ១ ២៦២អគារ (៥ ០៦៥ បន្ទប់), ការជួសជុលអគារឡើងវិញចំនួន ៤៣៦អគារ (១ ៧៥៤បន្ទប់), ផ្ទះគ្រូបង្រៀនចំនួន ១៣១,

អន្តេវាសិកដ្ឋានសិស្សចំនួន ៩, អគាររដ្ឋបាលចំនួន ២១, បណ្ណាល័យចំនួន ២, និងបង្គន់អនាម័យថ្មីចំនួន ៣៧១ កន្លែង (១ ៨៩៥បន្ទប់)។ បន្ថែមលើនេះ សាលារៀនចំនួន ១ ១០០ បានទទួលឧបករណ៍សម្ភាររដ្ឋបាលចាំបាច់នានា រួមមាន៖ កុំព្យូទ័រ ម៉ាស៊ីនបោះពុម្ព (Printer) ម៉ាស៊ីនថតចម្លង (Photocopier) ម៉ាស៊ីនបញ្ចាំង (Projector) និងទូរក្សាទុកឯកសារគ្រូ។

ក្រសួងក៏កំពុងលើកកម្ពស់គុណភាពអប់រំ និងសមធម៌នៃបរិយាកាសសិក្សាផងដែរតាមរយៈការកែលម្អបណ្ណាល័យ ការរៀបចំបណ្ណាល័យអេឡិចត្រូនិក និងការផ្តល់ជូននូវបច្ចេកវិទ្យាឌីជីថល ព្រមទាំងសម្ភារបង្រៀន និងរៀន។ ការវិនិយោគលើហេដ្ឋារចនាសម្ព័ន្ធកំពុងត្រូវបានតម្រង់ទិសកាន់តែខ្លាំងទៅលើតម្រូវការរបស់សិស្ស និងគម្លាតនៃការសិក្សា ដោយផ្តល់អាទិភាពដល់តំបន់ជួបការលំបាក តំបន់មិនទាន់ទទួលបានសេវាគ្របដណ្តប់ពេញលេញ និងហេដ្ឋារចនាសម្ព័ន្ធទាំងឡាយដែលមានទំនាក់ទំនងផ្ទាល់ទៅនឹងការរៀនសូត្រ រួមមាន បន្ទប់រៀន, បន្ទប់ពិសោធន៍វិទ្យាសាស្ត្រ, បណ្ណាល័យ, ហេដ្ឋារចនាសម្ព័ន្ធ, ICT, ព្រមទាំងបរិក្ខារសម្រាប់មុខវិជ្ជាស្ទែម (STEM) និងការអនុវត្តរៀនសូត្រជាក់ស្តែង។

ទន្ទឹមនឹងនេះ ក្រសួងកំពុងពង្រឹងសុខុមាលភាព វត្តមាន ការរក្សាសិស្សឱ្យស្ថិតក្នុងប្រព័ន្ធអប់រំ និងសមធម៌របស់សិស្ស តាមរយៈកម្មវិធីផ្តល់អាហារតាមសាលារៀន អាហារូបករណ៍ កម្មវិធីសុខភាពនិងអាហារូបត្ថម្ភ ទឹកស្អាតនិងអនាម័យ ការអប់រំបរិយាបន្ន កម្មវិធីពន្លឿនការសិក្សា និងការគាំទ្រចំគោលដៅសម្រាប់សិស្សងាយរងគ្រោះនិងជួបការលំបាក។ ជាពិសេស កម្មវិធីផ្តល់អាហារតាមសាលារៀនបានជួយកាត់បន្ថយការមករៀនមិនទៀងទាត់ ជួយដោះស្រាយបញ្ហាសិស្សមករៀនយឺត និងអវត្តមាន។ ក្រសួងក៏កំពុងពង្រឹងការចូលរួមរបស់មាតាបិតានិងសហគមន៍ ដោយលើកទឹកចិត្តគ្រួសារឱ្យជួយគាំទ្រការរៀនសូត្ររបស់កូននៅផ្ទះ និងចូលរួមក្នុងការងារអភិវឌ្ឍន៍សាលារៀនផងដែរ។

សរុបមក ការវិនិយោគទាំងនេះកំពុងបង្កើតនូវបរិស្ថានសិក្សាដែលមានសុវត្ថិភាពជាងមុន មានបរិយាបន្ន និងមានលក្ខណៈអំណោយផលជាងមុន ព្រមទាំងជួយដោះស្រាយទាំងឧបសគ្គផ្នែករូបវន្ត និងផ្នែកសេដ្ឋកិច្ច-សង្គម ដែលអាចជួយសិស្សមកសាលារៀនទៀងទាត់ រៀនប្រកបដោយប្រសិទ្ធភាព និងមានសុខភាពល្អ។

# ៦. ការឆ្លុះបញ្ចាំង និងមេរៀនពិសោធន៍

## ៦.១. ការឆ្លុះបញ្ចាំងលើលទ្ធផល PISA ឆ្នាំ ២០២៥ របស់កម្ពុជា

### ១. ការកើនឡើងនៃលទ្ធផល PISA របស់កម្ពុជា

លទ្ធផល PISA របស់កម្ពុជាបង្ហាញថា យុទ្ធសាស្ត្រកំណែទម្រង់វិស័យអប់រំកំពុងដើរលើផ្លូវដ៏ត្រឹមត្រូវ។ កំណែទម្រង់សំខាន់ៗ រួមមាន ការពង្រីកការអប់រំកុមារតូច និងមត្តេយ្យសិក្សា, ការពង្រឹងមូលដ្ឋានគ្រឹះនៃការសិក្សា ជាពិសេសអំណាន និងគណិតវិទ្យាថ្នាក់ដំបូង, កំណែទម្រង់សាលារៀន, ការបង្កើតសាលារៀនជំនាន់ថ្មី, សាលារៀនគំរូ, កំណែទម្រង់គ្រូបង្រៀន តាមរយៈការលើកកម្ពស់គុណវុឌ្ឍិគ្រូបង្រៀនតាមប្រព័ន្ធបណ្តុះបណ្តាលគ្រូ ១២+៤ និងការបង្កើនប្រាក់បៀវត្សរ៍គ្រូបង្រៀន។

### ២. ការរីកចម្រើនគួរឱ្យស្ញប់ស្ញែង

ការកើនឡើងលទ្ធផល PISA របស់កម្ពុជា បង្ហាញពី "ការរីកចម្រើនគួរឱ្យស្ញប់ស្ញែង" ជាពិសេសនៅពេលដែលលទ្ធផលរបស់ប្រព័ន្ធអប់រំជាច្រើនជុំវិញពិភពលោកមានការធ្លាក់ចុះ។

- កម្ពុជាទទួលបានការកើនឡើងយ៉ាងខ្លាំងជាពិសេសលើមុខវិជ្ជាវិទ្យាសាស្ត្រ និងការរីកចម្រើនគួរឱ្យកត់សម្គាល់លើផ្នែកអំណាន
- អំណាននៅតែជាបំណិនគ្រឹះដ៏សំខាន់ ពីព្រោះ "អំណានជាមាតានៃបំណិនទាំងអស់"។ អំណានកាន់តែល្អ ជួយទ្រទ្រង់ដល់ការរៀនសូត្រលើមុខវិជ្ជាផ្សេងៗទៀត
- ទោះជាយ៉ាងណាក៏ដោយ ការកើនឡើងនៃការប្រើប្រាស់បច្ចេកវិទ្យាក្នុងចំណោមសិស្ស ក៏កំពុងចោទជាបញ្ហាប្រឈម និងរំលេចបន្ថែមអំពីតម្រូវការក្នុងការបន្តពង្រឹងបំណិនមូលដ្ឋានគ្រឹះជាប្រចាំ
- ការរីកចម្រើននាពេលថ្មីៗនេះរបស់កម្ពុជា ស្មើនឹងការសិក្សាប្រមាណពីរឆ្នាំ។

### ៣. ប្រព័ន្ធអប់រំដែលកំពុងផ្លាស់ប្តូរ និងអភិវឌ្ឍ

កំណែទម្រង់វិស័យអប់រំ មិនមែនគ្រាន់តែជាការបង្កើនការចំណាយនោះទេ ប៉ុន្តែវាគឺជាការវិនិយោគលើអនាគតរបស់ប្រទេសកម្ពុជា។ ប្រព័ន្ធអប់រំត្រូវតែរៀបចំយុវជនឱ្យក្លាយជាពលករដែលមានជំនាញខ្ពស់, អ្នកស្រាវជ្រាវ, សហគ្រិនដែលមានគំនិតច្នៃប្រឌិត និងជាពលរដ្ឋដែលមានការទទួលខុសត្រូវ។

ចាប់តាំងពីឆ្នាំ ២០១៧–២០១៨ កម្ពុជាបានដាក់ឱ្យអនុវត្ត និងសាកល្បងនូវកំណែទម្រង់សាលារៀនសំខាន់ៗ រួមមាន៖

- ការគ្រប់គ្រងតាមសាលារៀន (SBM)
- យុទ្ធសាស្ត្រសហគមន៍សាលារៀន
- សាលារៀនគំរូ
- សាលារៀនជំនាន់ថ្មី (NGS)

## ៤. កំណែទម្រង់ការបណ្តុះបណ្តាល និងវិក្រឹតការគ្រូបង្រៀន

គុណភាពគ្រូបង្រៀន នៅតែជាចំណុចស្នូល នៃការកែលម្អវិស័យអប់រំ។

- កម្ពុជាកំពុងពង្រឹងការបណ្តុះបណ្តាល និងវិក្រឹតការគ្រូបង្រៀន
- ការវិនិយោគយ៉ាងច្រើនសន្ធឹកសន្ធាប់កំពុងត្រូវបានធ្វើឡើងលើគ្រឹះស្ថានបណ្តុះបណ្តាលគ្រូបង្រៀន រួមមាន ការបង្កើតវិទ្យាស្ថានគរុកោសល្យថ្មីៗ និងការធ្វើទំនើបកម្មគ្រឹះស្ថានដែលមានស្រាប់
- ការបន្តវិនិយោគលើការបណ្តុះបណ្តាលនិងអភិវឌ្ឍគុណវុឌ្ឍិគ្រូបង្រៀន ជាកត្តាចាំបាច់បំផុត ពីព្រោះគ្រូបង្រៀនដែលមានសមត្ថភាពកាន់តែខ្លាំងមានឥទ្ធិពលដោយផ្ទាល់លើលទ្ធផលសិក្សារបស់សិស្ស
- ថវិកាប្រមាណ ១០ លានដុល្លារអាមេរិក ត្រូវបានវិនិយោគលើកម្មវិធីផ្សេងៗសម្រាប់ផលិតឯកសារជំនួយ និងការអភិវឌ្ឍសមត្ថភាពគ្រូបង្រៀន និងភាពជាអ្នកដឹកនាំសាលារៀន
- គ្រូបង្រៀន និងគណៈគ្រប់គ្រងសាលារៀនប្រមាណ ៦ ០០០ នាក់ បានបញ្ចប់ការបណ្តុះបណ្តាលតាមរយៈកម្មវិធីអភិវឌ្ឍន៍វិជ្ជាជីវៈផ្អែកលើប្រព័ន្ធក្រេឌីត
- មេរៀនពិសោធន៍ដ៏សំខាន់មួយគឺការបណ្តុះបណ្តាលមិនមែនត្រឹមតែផ្ទេរចំណេះដឹងប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងតម្រូវឱ្យគ្រូបង្រៀនយកអ្វីដែលបានរៀនទៅអនុវត្តជាក់ស្តែងនៅក្នុងការបង្រៀនប្រចាំថ្ងៃ
- ការវិភាគទិន្នន័យ PISA បង្ហាញថា សាលារៀនសាធារណៈដែលបានចូលរួមក្នុងកម្មវិធីកំណែទម្រង់ការអប់រំ ជាទូទៅទទួលបានលទ្ធផលល្អប្រសើរជាងសាលារៀនផ្សេងទៀត ហើយសាលារៀនមួយចំនួនថែមទាំងទទួលបានលទ្ធផលល្អជាងសាលារៀនឯកជនទៀតផង។

## ៥. ការលើកកម្ពស់គុណភាពត្រូវតែដើរទន្ទឹមគ្នាជាមួយនឹងសមធម៌

ការលើកកម្ពស់លទ្ធផលសិក្សាតែមួយមុខ គឺមិនទាន់គ្រប់គ្រាន់នោះទេ។ កំណែទម្រង់វិស័យអប់រំ ក៏ត្រូវតែជួយកាត់បន្ថយគម្លាតវិសមភាពផងដែរ។

- កម្ពុជាវិនិយោគថវិកាប្រមាណ ៩ លានដុល្លារអាមេរិកប្រចាំឆ្នាំ លើកម្មវិធីផ្តល់អាហារតាមសាលារៀន
- ថវិកាប្រមាណ ៣០ លានដុល្លារអាមេរិក ត្រូវបានវិនិយោគលើកម្មវិធីអាហារូបករណ៍
- ការរៀនសូត្ររបស់សិស្សរងឥទ្ធិពលពីជីវភាពគ្រួសារ, ស្ថានភាពសេដ្ឋកិច្ច និងសង្គម, កម្រិតវប្បធម៌ ឬការអប់រំរបស់ឪពុកម្តាយ, បរិស្ថានរស់នៅឯផ្ទះ និងឱកាសទទួលបានការសិក្សា
- លទ្ធផល PISA បង្ហាញថា គម្លាតនៃការរៀនសូត្ររវាងសិស្សដែលមានជីវភាពខ្ពស់ និងសិស្សដែលមានជីវភាពទាប អាចស្មើនឹងរយៈពេលសិក្សានៅសាលារៀនប្រមាណពី ២ ទៅ ៣ ឆ្នាំសិក្សា

## ៦. សាលារៀនឆ្នើមមានទាំងនៅតំបន់ប្រជុំជន និងជនបទ

លក្ខណៈពិសេសមួយនៃការសម្រេចបានលទ្ធផលរបស់កម្ពុជា គឺគម្លាតរវាងសាលារៀននៅប្រជុំជន និងសាលារៀននៅជនបទមានកម្រិតតូច (តិចតួច) នៅពេលដែលសាលារៀនទាំងនោះទទួលបានអត្ថប្រយោជន៍ពីកំណែទម្រង់ដែលមានប្រសិទ្ធភាព។

- សាលារៀននៅជនបទ និងតំបន់ព្រំដែនមួយចំនួនអាចសម្រេចបានលទ្ធផលប្រហាក់ប្រហែលគ្នាទៅនឹងសាលារៀននៅប្រជុំជន និងសាលារៀនឯកជន
- សាលារៀននៅតាមខេត្តមួយចំនួនធ្វើបានល្អក្នុងកម្រិតប្រហាក់ប្រហែលទៅនឹងសាលារៀននៅតាមទីក្រុងធំៗដែរ
- សាលារៀនដែលមិនទាន់ទទួលបានអន្តរាគមន៍ ហើយគណៈគ្រប់គ្រងសាលាមិនទាន់ទទួលបានការអភិវឌ្ឍសមត្ថភាពភាពជាអ្នកដឹកនាំ តែងតែមានលទ្ធផលទាបជាង
- ការកែលម្អសាលារៀន, ការបណ្តុះបណ្តាលគ្រូបង្រៀន និងនាយកសាលា, ការគ្រប់គ្រងកាន់តែរឹងមាំ, ការវិនិយោគលើបន្ទប់ពិសោធន៍ និងបន្ទប់កុំព្យូទ័រ ព្រមទាំងការចូលរួមកាន់តែច្រើនពីសំណាក់មាតាបិតា និងសហគមន៍ សុទ្ធតែរួមចំណែកដល់ការលើកកម្ពស់លទ្ធផលការសិក្សា។

## ៧. កំណែទម្រង់សាលារៀនអាចបង្កើតនូវឧត្តមភាពជាប្រព័ន្ធទូទាំងប្រទេស

កំណែទម្រង់សាលារៀន អាចលើកកម្ពស់គុណភាពអប់រំដល់ប្រព័ន្ធអប់រំទាំងមូល មិនមែនផ្តល់អត្ថប្រយោជន៍ត្រឹមតែសាលារៀនមួយចំនួនតូចនោះទេ។

- ប្រាក់បៀវត្សរ៍គ្រូបង្រៀនកម្រិតមធ្យមសិក្សាទុតិយភូមិ និងបឋមភូមិ ត្រូវបានដំឡើងជិតពីរដងខណៈដែលប្រាក់បៀវត្សរ៍គ្រូបឋមសិក្សា បានកើនឡើងប្រមាណបីដង។
- អាហារូបករណ៍ដែលមានតម្លៃស្មើនឹង ៧០% នៃបៀវត្សរ៍មូលដ្ឋាន បានជួយទាក់ទាញសិស្សពូកែរួមទាំងសិស្សដែលប្រឡងជាប់និទ្ទេស A, B និង C ឱ្យចូលរៀនគរុកោសល្យ។
- គរុនិស្សិត និងគរុសិស្សប្រមាណ ៧៥% មកពីក្រុមសិស្សដែលមានលទ្ធផលសិក្សាខ្ពស់ទាំងនេះដែលជួយពង្រឹងកម្លាំងពលកម្មគ្រូបង្រៀននាពេលអនាគត។

## ៨. ប្រសិទ្ធភាពនៃការវិនិយោគគឺជាកត្តាសំខាន់

ទោះបីជាថវិកាផ្នែកអប់រំរបស់កម្ពុជាមានការកើនឡើងជាលំដាប់យ៉ាងណាក៏ដោយ ក៏ការចំណាយលើវិស័យនេះនៅតែតិចជាងប្រទេសសមាជិក OECD ដែរ ដោយសារតែប្រាក់ចំណូលមធ្យមរបស់កម្ពុជានៅមានកម្រិតទាបនៅឡើយ។

- ផលិតផលក្នុងស្រុកសរុប (GDP) សម្រាប់មនុស្សម្នាក់ៗរបស់កម្ពុជា មានប្រមាណ ៣,០០០ ដុល្លារអាមេរិក បើប្រៀបធៀបទៅនឹងប្រទេសជាសមាជិក OECD ដែលមានប្រាក់ចំណូលខ្ពស់មានប្រមាណ ៤០,០០០ ដុល្លារអាមេរិក។
- ទោះបីជាមានគម្លាតខុសគ្នាបែបនេះក៏ដោយ ក៏គម្លាតលទ្ធផលសិក្សាមានកម្រិតតូចជាងគម្លាតនៃប្រាក់ចំណូលឆ្ងាយណាស់។
- សាលារៀនកម្ពុជាដែលមានលទ្ធផលខ្ពស់មួយចំនួន បានសម្រេចលទ្ធផលប្រហាក់ប្រហែលទៅនឹងកម្រិតមធ្យមរបស់បណ្តាប្រទេស OECD រួចទៅហើយ។

- ការបន្តកែលម្អក្នុងរយៈពេលប្រមាណ ១២ ឆ្នាំ (ឬប្រហែល ៣ វដ្តនៃកម្មវិធី PISA) អាចនឹងជួយឱ្យកម្ពុជាខិតជិតទៅដល់កម្រិតសមត្ថភាពរបស់ប្រទេសសមាជិក OECD បាន។

## ៩. បន្តកំណែទម្រង់គ្រឹះស្ថានបណ្តុះបណ្តាលគ្រូបង្រៀន

កម្ពុជាបន្តពង្រឹងប្រព័ន្ធបណ្តុះបណ្តាលគ្រូបង្រៀន ១២+៤ ឱ្យក្លាយជាកំណែទម្រង់គុណភាពជាចម្បងមួយ។

- ការវិនិយោគលើការអភិវឌ្ឍគ្រូបង្រៀនដែលមានគុណភាពខ្ពស់នាពេលបច្ចុប្បន្ន នឹងទ្រទ្រង់ដល់ប្រព័ន្ធអប់រំសម្រាប់រាប់ទសវត្សរ៍ខាងមុខ
- ទោះបីជាគុណភាពរបស់សិស្សជាបញ្ហាសំខាន់ក៏ដោយ ប៉ុន្តែគុណភាពរបស់គ្រូបង្រៀនគឺរឹតតែសំខាន់ ដើម្បីរក្សាបាននូវការកែលម្អវិស័យអប់រំក្នុងរយៈពេលវែង
- ការសន្សំសំចៃថវិកាក្នុងរយៈពេលខ្លីមិនប៉ះពាល់ដល់គុណភាព និងគ្រឹះមូលដ្ឋានរបស់គ្រូបង្រៀននាពេលអនាគតនោះឡើយ
- ការកាត់បន្ថយចំណាយទោះជាក្នុងរយៈពេលខ្លីក៏ដោយ មិនគួរប៉ះពាល់ដល់ការវិនិយោគលើគុណភាព និងមូលដ្ឋានគ្រឹះរបស់គ្រូបង្រៀននាពេលអនាគតនោះឡើយ។

## ១០. ពង្រឹងកំណែទម្រង់សាលារៀនទាំងមូល

កំណែទម្រង់សាលារៀនទាំងមូលត្រូវតែបន្តរក្សាជាយុទ្ធសាស្ត្រស្នូល។

សកម្មភាពសំខាន់ៗ រួមមាន៖

- ការបង្កើតសហគមន៍សិក្សាវិជ្ជាជីវៈ (PLCs)
- ការពង្រីកថ្នាក់រៀនបំប៉ន និងការបន្ថែមម៉ោងសិក្សា
- ការដោះស្រាយបញ្ហាម៉ោងសិក្សាតិច និងការសិក្សាតែមួយពេល។
- ការពង្រឹងការចូលរួមរបស់មាតាបិតា និងអ្នកអាណាព្យាបាល។
- ការលើកកម្ពស់វិជ្ជាជីវៈបង្រៀនជាវិជ្ជាជីវៈសហការ ដែលគ្រូរៀនសូត្រពីគ្នាទៅវិញទៅមកជាប្រចាំ។

## ១១. ការប្រើប្រាស់បច្ចេកវិទ្យា និងបញ្ញាសិប្បនិម្មិត (AI) ប្រកបដោយការទទួលខុសត្រូវ

បច្ចេកវិទ្យា និងបញ្ញាសិប្បនិម្មិត (AI) នឹងដើរតួនាទីកាន់តែសំខាន់ក្នុងវិស័យអប់រំ ប៉ុន្តែបច្ចេកវិទ្យានិងបញ្ញាសិប្បនិម្មិតក៏បាននាំមកនូវទាំងឱកាស និងហានិភ័យទន្ទឹមគ្នាផងដែរ។

- បញ្ញាសិប្បនិម្មិតអាចជួយគាំទ្រដល់ការរៀន និងការបង្រៀនបានយ៉ាងល្អ ប្រសិនបើប្រើប្រាស់ឱ្យមានប្រសិទ្ធភាព ប៉ុន្តែការប្រើប្រាស់មិនបានត្រឹមត្រូវអាចជះឥទ្ធិពលអវិជ្ជមានដល់ការសិក្សា
- សាលារៀន និងគ្រួសារចាំបាច់ត្រូវណែនាំ និងតាមដានការប្រើប្រាស់បច្ចេកវិទ្យារបស់សិស្សានុសិស្ស
- កម្ពុជាគប្បីអភិវឌ្ឍថ្នាលមធ្យមសិក្សា ដើម្បីពង្រឹងការអប់រំកម្រិតមធ្យមសិក្សា

- បញ្ញាសិប្បនិម្មិតអាចជួយគ្រូបង្រៀនក្នុងការបង្កើនប្រសិទ្ធភាពបង្រៀនឱ្យកាន់តែប្រសើរឡើង
- លទ្ធផល PISA និង SEA-PLM ក៏បានបង្ហាញពីគម្លាតយេនឌ័រនៅក្នុងលទ្ធផលនៃការសិក្សាផងដែរ ដែលទាមទារឱ្យមានការយកចិត្តទុកដាក់លើគោលនយោបាយសមស្រប និងការប្រើប្រាស់បច្ចេកវិទ្យាដោយទទួលខុសត្រូវ។

## ១២. វឌ្ឍនភាពរបស់កម្ពុជាបង្ហាញឱ្យឃើញពីប្រសិទ្ធភាពខ្ពស់នៃការវិនិយោគលើការអប់រំ

ចំណាត់ថ្នាក់ទាបរបស់កម្ពុជានៅក្នុងកម្មវិធី PISA នាពេលកន្លងមក គប្បីត្រូវបានបកស្រាយដោយផ្អែកលើបរិបទនៃការអភិវឌ្ឍរបស់ប្រទេស។

- កម្ពុជាចំណាយលើសិស្សម្នាក់ៗតិចជាងឆ្ងាយណាស់ បើប្រៀបធៀបទៅនឹងបណ្តាប្រទេសដែលមានប្រាក់ចំណូលខ្ពស់
- ទោះបីជាការចំណាយលើវិស័យអប់រំមានការកើនឡើងយ៉ាងខ្លាំងក៏ដោយ ប៉ុន្តែចំនួនថវិកាជាក់ស្តែងនៅតែមានកម្រិតទាបជាងកម្រិតនៃបណ្តាប្រទេសសមាជិក OECD នៅឡើយ
- ទោះជាយ៉ាងណាក៏ដោយ លទ្ធផលរបស់កម្ពុជាបានបង្ហាញថា ការវិនិយោគលើវិស័យអប់រំរបស់ខ្លួនកំពុងបង្កើតបាននូវលទ្ធផលយ៉ាងល្អប្រសើរ ធៀបនឹងថវិកាដែលបានចំណាយ
- នេះឆ្លុះបញ្ចាំងពីកិច្ចសហការយ៉ាងមានប្រសិទ្ធភាពរវាងក្រសួងអប់រំ យុវជន និងកីឡា និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

## ១៣. កម្ពុជាបានធ្វើការសម្រេចចិត្តយ៉ាងឆ្លាតវៃ និងប្រកបដោយយុទ្ធសាស្ត្រ

ការរីកចម្រើននៃវិស័យអប់រំរបស់កម្ពុជា ឆ្លុះបញ្ចាំងឱ្យឃើញពីជម្រើសគោលនយោបាយជាយុទ្ធសាស្ត្រសំខាន់ៗមួយចំនួនៈ

- ការដំឡើងប្រាក់បៀវត្សរ៍សម្រាប់គ្រូបង្រៀន និងនាយកសាលារៀន
- ការពង្រឹងគុណភាពបង្រៀន ជាពិសេសលើបំណិនអំណាន និងគណិតវិទ្យាថ្នាក់ដំបូង
- ការកែលម្អគុណភាពសាលារៀន និងការពង្រីកការចូលរៀន
- ការផ្តល់អាទិភាពលើការវិនិយោគលើវិស័យអប់រំ ទោះបីជាស្ថិតនៅក្នុងកាលៈទេសៈខ្វះខាតធនធានក៏ដោយ។

## ១៤. ពង្រីកការអនុវត្តស្តង់ដាសាលារៀនគំរូ

ជំហានបន្ទាប់គប្បីផ្តោតលើការពង្រីកវិសាលភាពនៃការអនុវត្តស្តង់ដាសាលារៀនគំរូ។

សកម្មភាពអាទិភាព រួមមានៈ

១. បន្តលើកទឹកចិត្ត និងគាំទ្រគ្រូបង្រៀន ដើម្បីកែលម្អគុណភាពនៃការបង្រៀន

២. ពង្រឹងការចូលរួមរបស់មាតាបិតា និងសហគមន៍ តាមរយៈគណៈកម្មការគ្រប់គ្រងសាលារៀន

៣. បន្តអនុវត្តកម្មវិធីអំណាន និងគណិតវិទ្យាថ្នាក់ដំបូង, បណ្ណាល័យស្តង់ដា ព្រមទាំងការបង្វឹកនិងការប្រឹក្សាគរុកោសល្យ
៤. ពង្រីកគោលវិធីសាលារៀនជំនាន់ថ្មី ដែលអភិវឌ្ឍបំណិនសតវត្សរ៍ទី ២១ រួមមាន ការគិតបែបស៊ីជម្រៅ ការដោះស្រាយបញ្ហា និងការធ្វើការជាក្រុម
៥. រៀបចំសៀវភៅណែនាំគ្រូសម្រាប់មុខវិជ្ជាស្នែម និងបន្តចងក្រងឧត្តមានុវត្តន៍
៦. ពិនិត្យឡើងវិញ និងធ្វើទំនើបកម្មសៀវភៅសិក្សាគោល រួមទាំងមុខវិជ្ជាវិទ្យាសាស្ត្រ និងសិក្សាសង្គម ដោយបន្ស៊ីទៅនឹងស្តង់ដាច្បាស់លាស់ និងវិធីសាស្ត្រកម្រិតអន្តរជាតិ
៧. អភិវឌ្ឍថ្នាលមធ្យមសិក្សា ដោយប្រើប្រាស់បច្ចេកវិទ្យាឌីជីថល និងបញ្ញាសិប្បនិម្មិត ដែលអាចប្រើប្រាស់តាមទូរស័ព្ទឆ្លាតវៃ
៨. ពង្រឹងការគ្រប់គ្រងសាលារៀន រួមទាំងវិន័យរបស់គ្រូបង្រៀន និងសិស្ស ព្រមទាំងការតាមដានវត្តមានរបស់គ្រូបង្រៀននិងសិស្ស។

ការកើនឡើងលទ្ធផលនៃកម្មវិធី PISA របស់កម្ពុជា គឺជាផ្លែផ្កានៃកិច្ចខិតខំប្រឹងប្រែងរួមគ្នា និងជាបន្តបន្ទាប់ ដែលចូលរួមដោយក្រសួងអប់រំ យុវជន និងកីឡា, ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ, ដៃគូអភិវឌ្ឍន៍ និងគម្រោងអប់រំនានា។ បទពិសោធន៍នេះបានបង្ហាញយ៉ាងច្បាស់ថាការវិនិយោគប្រកបដោយចីរភាពលើការសិក្សាថ្នាក់ដំបូង គ្រូបង្រៀន កំណែទម្រង់សាលារៀន សមធម៌ ហេដ្ឋារចនាសម្ព័ន្ធ និងនុវានុវត្តន៍ អាចបង្កើតឱ្យមានការកែលម្អយ៉ាងពិតប្រាកដ។ ជំហានបន្ទាប់គឺត្រូវពង្រឹងកំណែទម្រង់ទាំងនេះឱ្យកាន់តែរឹងមាំ ពង្រីកការអនុវត្តដែលទទួលបានជោគជ័យឱ្យកាន់តែទូលំទូលាយ និងធានាឱ្យបានថាក្រុមសិស្ស និងសាលារៀនទាំងអស់នៅទូទាំងប្រទេស ទទួលបាននូវការកែលម្អការសិក្សានេះដូចៗគ្នា។

## ៦.២. ឧត្តមានុវត្តន៍

ការកើនឡើងនៃលទ្ធផល PISA របស់កម្ពុជា បានផ្តល់នូវមេរៀនសំខាន់ៗជាច្រើនសម្រាប់កំណែទម្រង់វិស័យអប់រំនានា នាពេលអនាគត។ បទពិសោធន៍នេះបង្ហាញថា ការរីកចម្រើនយ៉ាងច្បាស់លើលទ្ធផលសិក្សាអាចសម្រេចទៅបាន សូម្បីតែនៅក្នុងប្រព័ន្ធអប់រំដែលមានធនធាននៅមានកម្រិតក៏ដោយ ប្រសិនបើកំណែទម្រង់ទាំងនោះ ត្រូវបានធ្វើឡើងប្រកបដោយចីរភាព មានភាពប្រទាក់ក្រឡា ជួយគាំទ្រគ្នាទៅវិញទៅមក និងផ្តោតសំខាន់លើការកែលម្អការបង្រៀន និងការរៀន។

**កំណែទម្រង់ប្រកបដោយចីរភាពអាចបង្កើតឱ្យមានការកែលម្អយ៉ាងប្រាកដប្រជាលើលទ្ធផលសិក្សា**

បទពិសោធរបស់ប្រទេសកម្ពុជាបានបង្ហាញថា ការកែលម្អវិស័យអប់រំទាមទារឱ្យមានកិច្ចខិតខំប្រឹងប្រែងប្រកបដោយចីរភាព ជាជាងការអន្តរាគមន៍ ឬធ្វើសកម្មភាពម្តងម្កាលដាច់ដោយឡែកពីគ្នា។ ការវិនិយោគលើការអប់រំកុមារតូច មូលដ្ឋានគ្រឹះនៃការសិក្សា ការអភិវឌ្ឍសមត្ថភាពគ្រូបង្រៀន កំណែទម្រង់សាលារៀន និងធនធានបង្រៀននិងរៀន កំពុងត្រូវធ្វើជាបន្តបន្ទាប់ ហើយបានបំប្លែងទៅជាកំណើនលទ្ធផលសិក្សារបស់សិស្ស

ប្រកបដោយភាពច្បាស់លាស់។ ទំហំនៃការកើនឡើងនៃលទ្ធផល PISA របស់កម្ពុជានាពេលថ្មីៗនេះ បង្ហាញឱ្យឃើញថាវឌ្ឍនភាពយ៉ាងឆាប់រហ័សគឺអាចសម្រេចទៅបាន នៅពេលដែលកំណែទម្រង់ទាំងឡាយត្រូវបានអនុវត្តប្រកបដោយភាពស៊ីសង្វាក់គ្នា និងជាប់លាប់។

## ការកែលម្អគុណភាពនៃការបង្រៀនជាកត្តាស្នូលធ្វើឱ្យលទ្ធផលសិក្សារបស់សិស្សកាន់តែប្រសើរឡើង

គុណភាពរបស់គ្រូបង្រៀន នៅតែជាកត្តាកំណត់ដ៏សំខាន់បំផុតមួយលើលទ្ធផលសិក្សារបស់សិស្ស។ កំណែទម្រង់របស់កម្ពុជាលើការបណ្តុះបណ្តាលគ្រូ ការអភិវឌ្ឍវិជ្ជាជីវៈ ការបង្កើនប្រាក់បៀវត្សរ៍ និងការដំឡើងកម្រិតគុណវុឌ្ឍិគ្រូបង្រៀន បានបង្ហាញឱ្យឃើញពីសារៈសំខាន់នៃការវិនិយោគលើវិជ្ជាជីវៈបង្រៀន។ ទោះជាយ៉ាងណាក៏ដោយ ការបណ្តុះបណ្តាលតែមួយមុខគឺមិនទាន់គ្រប់គ្រាន់នោះទេ ប៉ុន្តែមេរៀនពិសោធន៍គន្លឹះបានបង្ហាញថា ការអភិវឌ្ឍវិជ្ជាជីវៈត្រូវតែបានប្រើប្រាស់ដើម្បីធ្វើឱ្យមានការប្រែប្រួលនៅក្នុងថ្នាក់រៀន។

## កំណែទម្រង់កម្រិតសាលារៀនមានសារៈសំខាន់ខ្លាំងណាស់ក្នុងការបំប្លែងគោលនយោបាយឱ្យទៅជាការរៀនសូត្ររបស់សិស្ស

គោលនយោបាយ និងការវិនិយោគថ្នាក់ជាតិបង្កើតផលជះលើការសិក្សាតាមរយៈសាលារៀន។ កំណែទម្រង់នានា ដូចជាការគ្រប់គ្រងតាមសាលារៀន សាលារៀនគំរូ និងសាលារៀនជំនាន់ថ្មី បានបង្ហាញឱ្យឃើញពីសារៈសំខាន់នៃភាពជាអ្នកដឹកនាំសាលារៀនដ៏រឹងមាំ កិច្ចសហការរវាងគ្រូបង្រៀននិងគ្រូបង្រៀន គណនេយ្យភាព ព្រមទាំងការយកចិត្តទុកដាក់លើការរៀនសូត្ររបស់សិស្សជាចម្បង។ សាលារៀនដែលមានលទ្ធផលល្អ បានបង្ហាញថា ការបំពេញការងារប្រកបដោយប្រសិទ្ធភាពនៅកម្រិតសាលារៀន អាចបង្កើតឱ្យមានការប្រែប្រួលជាវិជ្ជមានយ៉ាងខ្លាំងដោយមិនប្រកាន់ទីតាំង ឬទំហំសាលារៀននោះឡើយ។

## លទ្ធផលល្អប្រសើរអាចកើតមាននៅតំបន់ក្រៅពីទីប្រជុំជនធំៗផងដែរ

បទពិសោធន៍របស់សាលារៀនដែលមានលទ្ធផលល្អ បានបង្ហាញឱ្យឃើញថាទីតាំងភូមិសាស្ត្រមិនមែនជាកត្តាកំណត់ជោគជ័យនៃការអប់រំនោះឡើយ។ សាលារៀននៅតាមបណ្តាខេត្ត និងតំបន់ជនបទ អាចសម្រេចបាននូវលទ្ធផលប្រហាក់ប្រហែលគ្នានឹងសាលារៀននៅរាជធានីភ្នំពេញ និងទីប្រជុំជនផ្សេងទៀតដែរ ប្រសិនបើសាលារៀនមានការថ្នាក់ដឹកនាំប្រកបដោយប្រសិទ្ធភាព គ្រូបង្រៀនមានសមត្ថភាពខ្ពស់ ម៉ោងសិក្សាគ្រប់គ្រាន់ ការគាំទ្រសិស្សគ្រប់រូបភាព និងលទ្ធភាពចូលប្រើប្រាស់ធនធានសិក្សាដែលមានគុណភាព។ នេះផ្តល់នូវមេរៀនយ៉ាងសំខាន់ សម្រាប់ការកាត់បន្ថយគម្លាតរវាងតំបន់ជនបទ និងប្រជុំជន។

## ការកែលម្អគុណភាព និងសមធម៌ត្រូវដើរទន្ទឹមគ្នា

លទ្ធផលការសិក្សារងឥទ្ធិពលយ៉ាងខ្លាំងពីស្ថានភាពសេដ្ឋកិច្ច-សង្គម និងបរិយាកាសគ្រួសាររបស់សិស្ស។ ហេតុនេះ ការវិនិយោគលើកម្មវិធីផ្តល់អាហារតាមសាលារៀន អាហារូបករណ៍ និងការជួយគាំទ្រចំគោលដៅគឺជាផ្នែកមួយជួយបំពេញបន្ថែមយ៉ាងសំខាន់ដល់ការវិនិយោគលើការបង្រៀន និងហេដ្ឋារចនាសម្ព័ន្ធ។ បទពិសោធន៍

របស់កម្ពុជាបង្ហាញថា ការបង្កើនត្រឹមតែមធ្យមភាគពិន្ទុតែមួយមុខគឺមិនទាន់គ្រប់គ្រាន់ទេ កំណែទម្រង់ទាំងឡាយក៏ត្រូវតែដោះស្រាយលើគម្លាតការសិក្សាដ៏ធំរវាងសិស្សដែលមានជីវភាពខ្ពស់ និងសិស្សដែលមានជីវភាពទាបផងដែរ។

**ការអនុវត្តកំណែទម្រង់សាលារៀនគ្រប់ជ្រុងជ្រោយ មានប្រសិទ្ធភាពជាងសកម្មភាពអន្តរាគមន៍ដាច់ដោយឡែកពីគ្នា**

សាលារៀន និងកម្មវិធីកំណែទម្រង់ដែលទទួលបានជោគជ័យ ភាគច្រើនតែងតែរួមបញ្ចូលគ្នានូវអន្តរាគមន៍គ្រប់ផ្នែក៖ ការអភិវឌ្ឍសមត្ថភាពការងារដឹកនាំ ការអភិវឌ្ឍវិជ្ជាជីវៈគ្រូបង្រៀន រង្វាយតម្លៃជាប្រចាំ ការគាំទ្របន្ថែម ការចូលរួមពីមាតាបិតា ធនធានសិក្សា និងការប្រើប្រាស់ពេលវេលាបង្រៀនឱ្យមានប្រសិទ្ធភាព។ នេះបង្ហាញថាសកម្មភាពអន្តរាគមន៍ដាច់ដោយឡែកពីគ្នាមានលទ្ធភាពតិចតួចណាស់ក្នុងការបង្កើតឱ្យមានការកែលម្អប្រកបដោយចីរភាព បើប្រៀបធៀបទៅនឹងវិធីសាស្ត្ររួមទូទាំងសាលារៀន ដែលមានភាពប្រទាក់ក្រឡាស៊ីសង្វាក់គ្នា។

**កិច្ចសហការវិជ្ជាជីវៈជួយរក្សាការកែលម្អការបង្រៀនឱ្យមានចីរភាព**

ការបង្រៀនគឺជាវិជ្ជាជីវៈបែបសហការ។ សហគមន៍សិក្សាវិជ្ជាជីវៈ, ការរៀនសូត្រពីគ្នាទៅវិញទៅមក, ការប្រឹក្សាគរុកោសល្យ, និងការរួមគ្នាកែលម្អវិធីសាស្ត្របង្រៀន ជួយឱ្យគ្រូបង្រៀនអាចកែលម្អការបង្រៀនជាក់ស្តែងជាបន្តបន្ទាប់។ បទពិសោធន៍របស់កម្ពុជាបង្ហាញថា ការបង្កើតឱកាសឱ្យគ្រូបង្រៀនបានរៀនសូត្រពីគ្នាទៅវិញទៅមក គឺពិតជាមានសារៈសំខាន់ខ្លាំងណាស់ក្នុងការរក្សានិងបន្តកំណែទម្រង់នានាឱ្យមានចីរភាពជាងកម្មវិធីបណ្តុះបណ្តាលមួយគ្រាៗ។

**ហេដ្ឋារចនាសម្ព័ន្ធត្រូវបានផ្សារភ្ជាប់ជាមួយនឹងគរុកោសល្យ**

ការវិនិយោគលើបន្ទប់ពិសោធន៍, បណ្ណាល័យ, បរិក្ខារ ICT, និងធនធានឌីជីថល អាចជួយកែលម្អការសិក្សា ប៉ុន្តែហេដ្ឋារចនាសម្ព័ន្ធតែមួយមុខ មិនអាចធានាបង្កើតលទ្ធផលសិក្សាបានល្អប្រសើរនោះទេ។ មេរៀនពិសោធន៍បង្ហាញថា ធនធានទាំងនោះត្រូវតែបម្រើដល់ដំណើរការបង្រៀន។ បន្ទប់ពិសោធន៍វិទ្យាសាស្ត្រគប្បីគាំទ្រដល់ការធ្វើពិសោធន៍ និងការស្វែងយល់, បណ្ណាល័យត្រូវលើកកម្ពស់ការអាន និងការស្រាវជ្រាវ, ចំណែកឯបច្ចេកវិទ្យាគប្បីពង្រឹង (មិនមែនជំនួស) ដល់ការបង្រៀននិងរៀនដោយខ្លួនឯង។

**ការវាយតម្លៃអាចជំរុញឱ្យមានការកែលម្អលើការបង្រៀន និងការរៀន**

ការផ្តោតលើរង្វាយតម្លៃតាមដំណាក់កាល និងរង្វាយតម្លៃផ្តោតលើសមត្ថភាព កំពុងផ្តល់ឱកាសយ៉ាងច្រើនក្នុងការផ្លាស់ប្តូរវិធីសាស្ត្របង្រៀន ចេញពីការទន្ទេញចាំមាត់ ទៅជាការយល់ដឹង ការអនុវត្ត ការត្រិះរិះពិចារណា និងការដោះស្រាយបញ្ហាវិញ។ រង្វាយតម្លៃកម្រិតអន្តរជាតិ ដូចជា PISA ជាដើម បានផ្តល់ធាតុចូលយ៉ាងជាក់លាក់ ដើម្បីដឹងថា តើសិស្សអាចយកចំណេះដឹងទៅអនុវត្តក្នុងបរិបទថ្មីៗ និងជីវិតជាក់ស្តែងបានដែរឬទេ។ ហេតុនេះកំណែទម្រង់លើរង្វាយតម្លៃ គួរតែត្រូវបានផ្សារភ្ជាប់ទៅនឹងកំណែទម្រង់កម្មវិធីសិក្សា និងកំណែទម្រង់គរុកោសល្យ។

**ប្រសិទ្ធភាពនៃការវិនិយោគមានសារៈសំខាន់ជាងទំហំនៃការវិនិយោគ**

កម្ពុជាសម្រេចបាននូវការរីកចម្រើនគួរឱ្យកត់សម្គាល់ ទោះបីជាមានធនធានតិចជាងប្រព័ន្ធអប់រំនៃប្រទេសដែលមានប្រាក់ចំណូលខ្ពស់ជាច្រើនយ៉ាងណាក៏ដោយ។ នេះបង្ហាញថា ការកំណត់គោលដៅប្រកបដោយយុទ្ធសាស្ត្រ និងការអនុវត្តប្រកបដោយប្រសិទ្ធភាព អាចបង្កើតឱ្យមានលទ្ធផលល្អប្រសើរយ៉ាងច្រើន។ មេរៀនពិសោធន៍បង្ហាញថា ការវិនិយោគបន្ថែមមិនមែនមិនចាំបាច់ទេ ប៉ុន្តែការវិនិយោគនាពេលអនាគតគប្បីផ្តោតលើអន្តរាគមន៍ទាំងឡាយណាដែលផ្តល់នូវផលជះជាវិជ្ជមានធំធេងដល់ការបង្រៀន និងការរៀន។

**មូលដ្ឋានគ្រឹះនៃការសិក្សាដ៏រឹងមាំ នៅតែជាកត្តាសំខាន់បំផុតនៅក្នុងយុគសម័យបច្ចេកវិទ្យា និងបញ្ញាសិប្បនិម្មិត**

បច្ចេកវិទ្យាឌីជីថល និងបញ្ញាសិប្បនិម្មិត (AI) បានផ្តល់ឱកាសថ្មីៗជាច្រើនសម្រាប់ការអប់រំ ជាមួយគ្នានេះ បច្ចេកវិទ្យាទាំងនេះក៏បានពង្រឹងលើសារៈសំខាន់នៃបំណិនជាមូលដ្ឋានឱ្យបានរឹងមាំផងដែរ។ សិស្សចាំបាច់ត្រូវតែមានសមត្ថភាពក្នុងការអាន, គិតបែបស៊ីជម្រៅ, ផ្តល់ហេតុផលដោយខ្លួនឯង, និងដោះស្រាយបញ្ហាជាមុនសិន ទើបពួកគេអាចទាញយកផលប្រយោជន៍ពីបច្ចេកវិទ្យាជឿនលឿនទាំងនោះប្រកបដោយប្រសិទ្ធភាព។ ដូច្នេះ បច្ចេកវិទ្យាជាឧបករណ៍ជួយបំពេញបន្ថែម ជាជាងការជំនួសឱ្យមូលដ្ឋានគ្រឹះនៃការសិក្សា។

**កំណែទម្រង់ដែលទទួលបានជោគជ័យត្រូវតែពង្រីកវិសាលភាពជាលក្ខណៈប្រព័ន្ធ**

បច្ចុប្បន្ន កម្ពុជាមានសាលារៀនដែលមានលទ្ធផលល្អ កម្មវិធីកំណែទម្រង់ដែលមានប្រសិទ្ធភាព និងការបង្រៀនប្រកបដោយសក្តានុពលជាច្រើន។ កិច្ចការបន្ទាប់គឺការកំណត់អន្តរាគមន៍ទាំងឡាយណាដែលមានប្រសិទ្ធភាព ហើយធ្វើការសម្របសម្រួលការអនុវត្តទាំងនោះទៅតាមបរិបទផ្សេងៗគ្នា និងពង្រីកវិសាលភាពអនុវត្តឱ្យបានជាប្រព័ន្ធ។ កិច្ចការនេះទាមទារឱ្យមានក្របខណ្ឌអនុវត្តច្បាស់លាស់ ការផ្តល់ហិរញ្ញប្បទានប្រកបដោយចីរភាព ការគាំទ្រដល់គ្រូបង្រៀន ការពិនិត្យតាមដាន និងការសិក្សាស្រាវជ្រាវជាបន្តបន្ទាប់។

មេរៀនពិសោធន៍គន្លឹះចេញពីវឌ្ឍនភាពនាពេលថ្មីៗនេះរបស់កម្ពុជាគឺថា ការកែលម្អវិស័យអប់រំមិនមែនកើតចេញពីកំណែទម្រង់ទោល នោះទេ។ វាកើតចេញពីអន្តរកម្មនៃការវិនិយោគជាច្រើនផ្នែក ដូចជាការវិនិយោគលើគ្រូបង្រៀន ភាពជាអ្នកដឹកនាំសាលារៀន មូលដ្ឋានគ្រឹះនៃការសិក្សា សមធម៌ ហេដ្ឋារចនាសម្ព័ន្ធ វង្វាយតម្លៃការសិក្សា និងនវានុវត្តន៍។

បទពិសោធន៍របស់កម្ពុជាបង្ហាញថា ទោះបីជាមានធនធាននៅមានកម្រិតក៏ដោយ ក៏យុទ្ធសាស្ត្រកំណែទម្រង់ដែលមានភាពប្រទាក់ក្រឡាស៊ីសង្វាក់គ្នា និងប្រកបដោយចីរភាព អាចបង្កើតឱ្យមានការកែលម្អយ៉ាងប្រាកដលើលទ្ធផលនៃការសិក្សា។ ផែនការបន្ទាប់គឺការពង្រឹងសមិទ្ធផលទាំងនេះ ដោះស្រាយបញ្ហាវិសមភាពដែលនៅតែបន្តកើតមាន និងពង្រីកវិសាលភាពនៃការអនុវត្តជោគជ័យទាំងនោះឱ្យដល់គ្រប់សាលារៀនទាំងអស់ មិនមែនត្រឹមតែសាលារៀនដែលមានលទ្ធផលល្អមួយចំនួនតូចនោះទេ ដែលអាចផ្តល់ដល់សិស្សនូវចំណេះដឹង បំណិន និងសមត្ថភាពដែលចាំបាច់សម្រាប់អនាគត។

## ៧. សកម្មភាពគោលនយោបាយ

ដោយផ្អែកលើលទ្ធផល PISA ឆ្នាំ២០២៥ របស់កម្ពុជា ផ្នែកនេះបានបង្ហាញពីសកម្មភាពគោលនយោបាយ ដើម្បីរក្សានិងបន្តបង្កើនលទ្ធផលសិក្សាឱ្យមានចីរភាព តាមរយៈកំណែទម្រង់សាលារៀន ការអភិវឌ្ឍសមត្ថភាពគ្រូបង្រៀន កំណែទម្រង់កម្មវិធីសិក្សានិងវង្វាយតម្លៃ ការពង្រឹងមូលដ្ឋានគ្រឹះនៃការសិក្សា បច្ចេកវិទ្យាឌីជីថល និងសមធម៌។ សកម្មភាពទាំងនេះមានគោលបំណងពង្រីកវិសាលភាពនៃការអនុវត្តដ៏មានប្រសិទ្ធភាព ព្រមទាំងផ្តល់ការគាំទ្រចំគោលដៅដល់សាលារៀនដែលមានលទ្ធផលទាប ដើម្បីបំប្លែងសមិទ្ធផលថ្មីៗនេះឱ្យទៅជាការកែលម្អការរៀនសូត្ររបស់សិស្សប្រកបដោយចីរភាពក្នុងប្រព័ន្ធអប់រំទាំងមូល។

### ១. សិក្សាអំពីសាលារៀន PISA ដែលមានលទ្ធផលខ្ពស់ និងពង្រីកចំនួនសាលារៀនមានប្រសិទ្ធភាព

ក្រសួងនឹងសិក្សាស្រាវជ្រាវលើសាលារៀនដែលទទួលបានពិន្ទុ PISA ខ្ពស់ ដើម្បីកំណត់រកកត្តាដ៏មានប្រសិទ្ធភាពក្នុងការបង្រៀន ការវាយតម្លៃ ការដឹកនាំ ការជួយសិស្ស និងការគ្រប់គ្រងសាលារៀន ហើយយកការអនុវត្តល្អៗទាំងនោះធ្វើជាគំរូ ដើម្បីពង្រឹង និងកែលម្អសាលារៀនជាបន្តបន្ទាប់។

ក្រសួងនឹងបន្តពង្រីកវិសាលភាព សាលារៀនគំរូ និងសាលារៀនជំនាន់ថ្មី ដោយពង្រឹងការគ្រប់គ្រងតាមសាលារៀន, ភាពជាអ្នកដឹកនាំផ្តោតលើការបង្រៀន, គណនេយ្យភាព, ការចូលរួមរបស់សហគមន៍, ការអប់រំស្នេម, និងការសិក្សាផ្តោតលើបំណិនសតវត្សរ៍ទី២១ ព្រមទាំងប្រែក្លាយសាលារៀនទាំងនោះឱ្យក្លាយទៅជាមជ្ឈមណ្ឌលចែករំលែកនិងផ្សព្វផ្សាយវិធីសាស្ត្រដែលមានប្រសិទ្ធភាពទៅកាន់សាលារៀននៅជុំវិញនោះ។

### ២. បង្កើនការចុះឈ្មោះចូលរៀន និងការសិក្សានៅកម្រិតមធ្យមសិក្សា

ក្រសួងនឹងបន្តពង្រីកការចុះឈ្មោះចូលរៀន និងរក្សាសិស្សឱ្យនៅរៀននៅកម្រិតមធ្យមសិក្សា ដោយមានមហិច្ឆតាឱ្យដល់កម្រិតតំបន់ រួមទាំងការសម្រេចបានអត្រាចូលរៀននៅកម្រិតមធ្យមសិក្សាទុតិយភូមិពី ៦០% ទៅ ៧០%។

ក្រសួងនឹងបង្កើនឱកាសការសិក្សាតាមរយៈកម្មវិធីសិក្សាពេញមួយថ្ងៃ និងកម្មវិធីសិក្សាបន្ថែម ពង្រឹងការបំប៉នសិស្ស និងការគាំទ្រចំគោលដៅសម្រាប់សិស្សជួបការលំបាក និងសិស្សរៀនយឺត ព្រមទាំងកាត់បន្ថយការរៀនត្រួតថ្នាក់ ការបោះបង់ការសិក្សា តាមរយៈការកំណត់រកគម្លាតចំណេះដឹងបានទាន់ពេលវេលា និងជួយអន្តរាគមន៍បានឆាប់រហ័ស។ កិច្ចខិតខំប្រឹងប្រែងទាំងនេះនឹងជួយឱ្យសិស្សកាន់តែច្រើនអាចរៀនសូត្រនៅកម្រិតដែលស្របតាមអាយុ, បញ្ចប់ការសិក្សាកម្រិតមធ្យមសិក្សាដោយជោគជ័យ ព្រមទាំងត្រៀមខ្លួនរួចជាស្រេចសម្រាប់វង្វាយតម្លៃ PISA នៅវដ្តបន្ទាប់ និងការសិក្សាបន្តទៀត។

## ៣. កែលម្អសាលារៀន និងបរិយាកាសសិក្សា

ក្រសួងនឹងពង្រីកសាលារៀន និងកែលម្អបរិយាកាសសិក្សា ជាពិសេសនៅតាមតំបន់មិនទាន់មានសេវាអប់រំគ្រប់គ្រាន់ តាមរយៈការសាងសង់បន្ទប់រៀនបន្ថែម បន្ទប់ពិសោធន៍ បណ្ណាល័យ ហេដ្ឋារចនាសម្ព័ន្ធឌីជីថល និងទីកន្លែងសិក្សាផ្សេងទៀត តាមរយៈគម្រោង BEIP និង GEIP។

ក្រសួងនឹងធានាថាការវិនិយោគទាំងនេះនឹងជួយកែលម្អការបង្រៀន និងការរៀនដោយផ្ទាល់ តាមរយៈការពង្រឹងបន្ទប់ពិសោធន៍វិទ្យាសាស្ត្រ បណ្ណាល័យ សេវាឌីជីថល និងធនធានសិក្សា ព្រមទាំងផ្តល់ការគាំទ្របន្ថែមដល់សាលារៀននៅជនបទ និងសាលារៀនដែលមានការខ្វះខាត ដើម្បីលើកកម្ពស់សមធម៌ឱ្យកាន់តែប្រសើរឡើង។

## ៤. ប្រើប្រាស់បញ្ញាសិប្បនិម្មិត (AI) និងបច្ចេកវិទ្យាឌីជីថលដើម្បីបង្កើនឱកាសសិក្សា

ក្រសួងនឹងប្រើប្រាស់បញ្ញាសិប្បនិម្មិត (AI) និងបច្ចេកវិទ្យាឌីជីថល ដើម្បីពង្រីកការរៀនសូត្រ ដោយបង្កើនម៉ោងសិក្សាបន្ថែម, ការធ្វើស្វ័យសិក្សា, ការរៀនអនុវត្តដោយខ្លួនឯង, ការផ្តល់មតិកែលម្អ និងការគាំទ្រសិស្សដែលត្រូវការជំនួយ។

ក្រសួងនឹងពង្រីកការប្រើប្រាស់ថ្នាលបឋម (PLP) និងថ្នាលមធ្យមសិក្សា (SLP) រួមទាំង ធនធានឌីជីថល និងវង្វាយតម្លៃស្របតាមកម្មវិធីសិក្សា ព្រមទាំងប្រើប្រាស់បច្ចេកវិទ្យាដើម្បីតាមដានគម្លាតនៃការរៀនសូត្រ និងពង្រឹងការអប់រំស្នែម, បញ្ចូលបញ្ញាសិប្បនិម្មិត (AI) ទៅក្នុងសាលារៀន និងការបណ្តុះបណ្តាលគ្រូបង្រៀនជាបណ្តើរៗ ព្រមទាំងផ្សារភ្ជាប់រវាងសាលារៀននៅជនបទជាមួយសាកលវិទ្យាល័យ និងសាលារៀនដែលមានលទ្ធផលខ្ពស់ តាមរយៈការរៀនសូត្រ និងកិច្ចសហប្រតិបត្តិការបែបឌីជីថល។

## ៥. អនុវត្តកំណែទម្រង់សាលារៀនគ្រប់ជ្រុងជ្រោយ

ក្រសួងនឹងអនុវត្តកំណែទម្រង់សាលារៀនគ្រប់ជ្រុងជ្រោយ ចាប់ពីកម្រិតមត្តេយ្យសិក្សា រហូតដល់មធ្យមសិក្សា ដោយបង្កើតប្រព័ន្ធអប់រំដែលស៊ីសង្វាក់គ្នា ដូចជា ការអប់រំតាមរយៈការលេងសម្រាប់កុមារនៅមត្តេយ្យសិក្សា ការផ្តោតលើអំណាននិងគណិតវិទ្យាថ្នាក់ដំបូង និងការជួយសិស្សរៀនយឺត (PTOM) នៅកម្រិតបឋមសិក្សា ព្រមទាំងការលើកកម្ពស់វិធីសាស្ត្របង្រៀនថ្មីដែលផ្តោតលើស្នែមនៅកម្រិតមធ្យមសិក្សា។

ក្រសួងនឹងពង្រឹងមូលដ្ឋានគ្រឹះអំណាន និងគណិតវិទ្យា, បង្កើតស្តង់ដាសមត្ថភាព និងលំដាប់លំដោយនៃការរៀនសូត្រឱ្យបានច្បាស់លាស់ ប្រើប្រាស់វង្វាយតម្លៃបែបវិនិច្ឆ័យ ដើម្បីដោះស្រាយគម្លាតសិក្សាបានឆាប់រហ័ស ព្រមទាំងពង្រីកការអាន, ការអប់រំស្នែម, ថ្នាក់រៀនបំប៉ន, កម្មវិធីសិក្សាបន្ថែម, ការរៀនសូត្រពីគ្នាទៅវិញទៅមក និងឱកាសពង្រឹងសមត្ថភាពបន្ថែម។

## ៦. ពង្រឹងការអនុវត្តគន្លងអប់រំថ្មី និងការតម្រង់ទិសអាជីព

ក្រសួងនឹងពង្រឹងការអនុវត្តគន្លងអប់រំថ្មី ដើម្បីរក្សាសិស្សឱ្យនៅរៀននៅក្នុងសាលារៀន និងតម្រង់ទិសសិស្សឱ្យជ្រើសរើសគន្លងអប់រំ និងអាជីពត្រឹមត្រូវ ស្របតាមចំណាប់អារម្មណ៍ សមត្ថភាព លទ្ធផលសិក្សា និងសេចក្តីប្រាថ្នារបស់ពួកគេ។

ក្រសួងនឹងពង្រឹងការប្រឹក្សាអំពីការសិក្សា និងអាជីព, ណែនាំសិស្សឱ្យយល់ច្បាស់ពីគន្លងអប់រំថ្មី រួមមានគន្លងវិទ្យាសាស្ត្រ គន្លងវិទ្យាសាស្ត្រសង្គម និងគន្លងវិជ្ជាជីវៈ ព្រមទាំងប្រើប្រាស់ទិន្នន័យនៃការសិក្សា ដើម្បីជួយគាំទ្រដល់ការឡើងថ្នាក់ កាត់បន្ថយការបោះបង់ការសិក្សានិងការរៀនត្រួតថ្នាក់ និងរៀបចំសិស្សឱ្យទទួលបានការអភិវឌ្ឍជំនាញ ការសិក្សាបន្តទៅមុខទៀត និងការស្វែងរកការងារធ្វើ។

## ៧. ធ្វើទំនើបកម្មកម្មវិធីសិក្សា និងសៀវភៅសិក្សាគោល

ក្រសួងនឹងបន្តធ្វើទំនើបកម្មសៀវភៅសិក្សាគោលចាប់ពីកម្រិតបឋមសិក្សា ដល់មធ្យមសិក្សា ដើម្បីពង្រឹងការយល់ដឹងអំពីបញ្ញត្តិ ការអនុវត្តចំណេះដឹង ការត្រិះរិះពិចារណា ការដោះស្រាយបញ្ហា ការផ្តល់ហេតុផលបែបវិទ្យាសាស្ត្រ និងសមត្ថភាពជាសកល។ ក្រសួងនឹងបន្តយកចិត្តទុកដាក់កាន់តែខ្លាំងលើអំណានគណិតវិទ្យា វិទ្យាសាស្ត្រ ការអប់រំស្នែម និងជំនាញចាំបាច់នានា ដើម្បីឱ្យសិស្សទទួលបានជោគជ័យក្នុងបរិបទដែលពិភពលោកកំពុងផ្លាស់ប្តូរយ៉ាងឆាប់រហ័ស។

ក្រសួងនឹងបន្សុីកម្មវិធីសិក្សា សៀវភៅសិក្សាគោល វិធីសាស្ត្របង្រៀន និងវង្វាយតម្លៃ ឱ្យស្របទៅតាមស្តង់ដាសមត្ថភាពច្បាស់លាស់, លំដាប់លំដោយនៃការរៀនសូត្រ, កម្មវិធី PISA, និងក្របខណ្ឌអន្តរជាតិ។ សៀវភៅសិក្សាគោល និងសម្ភារសិក្សានឹងលើកកម្ពស់ការរៀនសូត្រឱ្យកាន់តែស៊ីជម្រៅ តាមរយៈការដោះស្រាយបញ្ហាក្នុងជីវភាពជាក់ស្តែង និងផ្អែកលើបរិបទជាក់ស្តែង ការរិះរក ការត្រិះរិះពិចារណា ការបកស្រាយទិន្នន័យ ការពិសោធ ការសិក្សាផ្តោតលើគម្រោង និងលំហាត់ផ្តោតលើសមត្ថភាព ដែលជួយឱ្យសិស្សអាចយកអ្វីដែលបានរៀនទៅអនុវត្តនៅក្នុងបរិបទផ្សេងៗគ្នាបាន។

## ៨. កែសម្រួលប្រព័ន្ធបណ្តុះបណ្តាលគ្រូ និងពង្រឹងគុណភាពគ្រូបង្រៀន

ក្រសួងនឹងបន្តកែលម្អការបណ្តុះបណ្តាលគ្រូបង្រៀន និងពង្រឹងគុណភាពគ្រូបង្រៀន តាមរយៈការអនុវត្តរូបមន្ត ១២+៤, បរិញ្ញាបត្រ+១, និងបរិញ្ញាបត្រ+២ ព្រមទាំងទាក់ទាញ អភិវឌ្ឍវិជ្ជាជីវៈជាប្រចាំ និងរក្សាទុកគ្រូបង្រៀនដែលមានសមត្ថភាពខ្ពស់។ គ្រឹះស្ថានបណ្តុះបណ្តាលគ្រូត្រូវពង្រឹង ដោយផ្តោតលើស្តង់ដាវិជ្ជាជីវៈ និងសមត្ថភាពច្បាស់លាស់ ព្រមទាំងយកចិត្តទុកដាក់លើការជ្រើសរើសបេក្ខជនដែលមានសមត្ថភាព និងពង្រឹងសមត្ថភាពដល់ពួលគាត់សម្រាប់ការបង្រៀនក្នុងថ្នាក់រៀនបែបទំនើប។

ក្រសួងនឹងពង្រឹងគន្លងអាជីពគ្រូបង្រៀន ការលើកទឹកចិត្ត និងការអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំ ព្រមទាំងបំប៉នគ្រូបង្រៀននូវវិធីសាស្ត្របង្រៀនបែបទំនើប, វង្វាយតម្លៃផ្តោតលើសមត្ថភាព, ភាសាបរទេស, សមត្ថភាពឌីជីថលនិងបញ្ញាសិប្បនិម្មិត, ការស្រាវជ្រាវ, និងជំនាញទិន្នន័យ។ ការជួយគាំទ្រវិជ្ជាជីវៈនឹងត្រូវពង្រីកតាមរយៈ

សហគមន៍សិក្សាវិជ្ជាជីវៈ, ការប្រឹក្សាគរុកោសល្យ, ការបង្វឹក, ការសង្កេតការបង្រៀន, និងថ្នាក់និទស្សន៍ ដោយមានការផ្សារភ្ជាប់គ្នារវាងការអភិវឌ្ឍសមត្ថភាពគ្រូ, ការបង្រៀន និងលទ្ធផលសិក្សារបស់សិស្ស។

### ៩. ពង្រឹងគណនេយ្យភាព និងលទ្ធផលការងាររបស់សាលារៀន

ក្រសួងនឹងពង្រឹងការធ្វើអធិការកិច្ចសាលារៀនដោយផ្តោតលើសមិទ្ធផលការងារ និងគណនេយ្យភាព ដោយប្រើប្រាស់ស្វ័យវាយតម្លៃសាលារៀន លទ្ធផលសិក្សារបស់សិស្ស គុណភាពបង្រៀន ភាពជាអ្នកដឹកនាំរបស់សាលារៀន និងស្តង់ដាសាលារៀនគំរូ។

ក្រសួងនឹងប្រើប្រាស់ទិន្នន័យអធិការកិច្ច និងសមិទ្ធផលការងារ ដើម្បីកំណត់តម្រូវការដែលត្រូវកែលម្អ ពង្រឹងគណនេយ្យភាព និងការគាំទ្រចំគោលដៅ ពិនិត្យតាមដានលើទិដ្ឋភាពសំខាន់ៗនៃលទ្ធផលការងាររបស់សាលារៀន ការអនុវត្តមានប្រសិទ្ធភាព និងលើកកម្ពស់កិច្ចសហការរវាងសាលារៀននិងសាលារៀន មាតាបិតា សហគមន៍ សាកលវិទ្យាល័យ និងវិស័យឯកជន។

### ១០. ពង្រឹងវង្វាយតម្លៃតាមបែប PISA និងវង្វាយតម្លៃផ្តោតលើសមត្ថភាព

ក្រសួងនឹងពង្រឹងការវាយតម្លៃតាមបែប PISA ស្របជាមួយការពង្រឹងវង្វាយតម្លៃតាមដំណាក់កាល រួមទាំងការបង្កើតធនាគារសំណួរ សម្រាប់វាយតម្លៃបំណិនត្រិះរិះពិចារណា ការដោះស្រាយបញ្ហា ការផ្តល់ហេតុផលបែបវិទ្យាសាស្ត្រ ការអនុវត្តចំណេះដឹង និងសមត្ថភាពជាសកល។

ក្រសួងនឹងផ្លាស់ប្តូរវិធីសាស្ត្រវាយតម្លៃជាបណ្តើរៗ ពីការចងចាំខ្លឹមសារមេរៀន ទៅជាការអនុវត្តចំណេះដឹង ការវិភាគ ការផ្តល់ហេតុផល និងការដោះស្រាយបញ្ហាក្នុងជីវភាពជាក់ស្តែង។ ក្រសួងនឹងពង្រឹងការវាយតម្លៃជាប្រចាំតាមរយៈការធ្វើគម្រោង ការពិសោធន៍ ការធ្វើបទបង្ហាញ និងការស្រាវជ្រាវ ព្រមទាំងអភិវឌ្ឍប្រព័ន្ធវង្វាយតម្លៃផ្តោតលើគម្រោង និងធនាគារសំណួរចាប់ពីថ្នាក់ទី៤ ដល់ថ្នាក់ទី១២ ហើយប្រើប្រាស់លទ្ធផលពីវង្វាយតម្លៃ និងប្រព័ន្ធឌីជីថល ដើម្បីតាមដានវឌ្ឍនភាពនៃការសិក្សា កំណត់គម្លាតការសិក្សា កែលម្អការបង្រៀននិងរៀន និងផ្តល់ការគាំទ្រចំគោលដៅ។

OECD

BETTER POLICIES FOR BETTER LIVES

PISA

អំណាន

គណិតវិទ្យា

វិទ្យាសាស្ត្រ

